

# 1 លានហេតុផល

# 1,000,000

# ដើម្បីអបអរសាទរ

2014 របាយការណ៍ប្រចាំឆ្នាំ

VisionFund CAMBODIA

# មាតិកា

4. មួយលានអរគុណពី វីសិនហ្វាន់ ក្នុងការជួយធ្វើឲ្យជីវិតកុមារមានភាពប្រសើរឡើង

## អំពី វីសិនហ្វាន់

7. ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល
8. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ
10. ប្រវត្តិសង្ខេប វីសិនហ្វាន់
12. សារពីលោក ស្កត់ ប្រោន
14. សារពីលោក ជេសិន អ៊ីវេនស៍
16. សារពីលោក ឈី ឈិនហូ អគ្គនាយកប្រតិបត្តិ វីសិនហ្វាន់ ខេមបូឌា
20. ក្រុមប្រឹក្សាភិបាល
24. អំពីគណៈគ្រប់គ្រង
27. តួលេខសំខាន់ៗ
28. ស្ថាប័នដែលមានភាពលេចធ្លោក្នុងឆាកអន្តរជាតិ
30. រចនាសម្ព័ន្ធ វីសិនហ្វាន់
32. សាច់រឿងអតិថិជន
34. អំពីផលិតផល
39. ដៃគូសហការ

## សមិទ្ធផលសង្គម

44. សមិទ្ធផលសង្គម
64. ព័ត៌មានរបស់ វីសិនហ្វាន់ ប្រចាំឆ្នាំ
68. វីសិនហ្វាន់ ផ្តល់ជូនកម្មវិធីអាហារូបករណ៍ដល់កូនៗរបស់អតិថិជន
70. ទិន្នន័យស្តីពីបរិស្ថាន និងទិន្នន័យបុគ្គលិក
71. តំបន់ប្រតិបត្តិការ

## ហិរញ្ញវត្ថុ

74. និន្នាការកំណើន
77. របាយការណ៍របស់សវនករឯករាជ្យ
78. តារាងតុល្យការ
79. របាយការណ៍លទ្ធផល
80. របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
81. របាយការណ៍លំហូរទឹកប្រាក់
82. បណ្តាញវីសិនហ្វាន់ អន្តរជាតិ

# មួយលានអរគុណ ពី វីសិនហ្វាន់ ក្នុងការជួយធ្វើឲ្យជីវិតកុមារមានភាពប្រសើរឡើង

ឆ្នាំ2014 បានបង្ហាញពីជោគជ័យដ៏អស្ចារ្យរបស់ វីសិនហ្វាន់ ខេមបូឌា ក្នុងការបម្រើដល់អតិថិជននៅតាមសហគមន៍ឈានដល់ចំនួនជាង 228,000 នាក់ ដែលជាផ្នែកមួយនៃការសម្រេចជោគជ័យក្នុងការបម្រើដល់អតិថិជននៅតាមសហគមន៍ចំនួនរហូតដល់ 1លាននាក់ របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ទូទាំងសកលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ អង្គការទស្សនៈពិភពលោក។

ជាលទ្ធផល កុមារចំនួនជាង 3,5លាននាក់ អាចមានជីវិតប្រសើរឡើង និង មានលទ្ធភាពទទួលបានសម្ភារៈសិក្សា អាហារមានជីវជាតិ កន្លែងស្នាក់នៅ និងសម្លៀកបំពាក់សមរម្យ ។

ចំនួនអតិថិជនរបស់ វីសិនហ្វាន់ ខេមបូឌា បានកើនឡើង10ដងក្នុងរយៈពេលជាង10ឆ្នាំកន្លងមកនេះ។ គិតត្រឹមដំណាច់ខែ ធ្នូ ឆ្នាំ2014 សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់គឺ ផលប័ត្រឥណទានសរុបបានកើនឡើងរហូតដល់ជាង 90លានដុល្លារអាមេរិក និងផ្តល់ផលប៉ះពាល់ដល់កុមារកម្ពុជាចំនួនជាង 7សែន5ម៉ឺននាក់ឲ្យមានជីវិតប្រសើរឡើង។

យើងសូមសរសើរដល់ព្រះជាម្ចាស់ សម្រាប់ការជោគជ័យដ៏ល្អប្រសើរនេះ និង សូមអរគុណដល់ អតិថិជននៅតាមសហគមន៍ទាំងអស់សម្រាប់ការប្រើប្រាស់កម្ចីចំគោលដៅប្រកបដោយភាពវៃឆ្លាតដែលអាចពង្រីកអាជីវកម្មរបស់ពួកគេ និងមានលទ្ធភាពឲ្យកូនៗទទួលបានជីវិតដែលប្រសើរឡើង មានឱកាសសិក្សានិងអនាគតល្អ។ យើងប្តេជ្ញាចិត្ត ក្នុងការជម្រុញដល់សហគមន៍ឲ្យកាន់តែមានភាពរីកចម្រើនជាវិជ្ជមានបន្តទៅទៀត ដែលនឹងអាចនាំឲ្យក្មេងជំនាន់ក្រោយមានអនាគតកាន់តែប្រសើរ តាមរយៈបេសកកម្មសង្គមរបស់យើង។



**7 សែននាក់**

## ផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់កុមារ

តាមរយៈការរីកចម្រើនរបស់ឪពុកម្តាយ កុមាររាប់សែននាក់ទទួលបានជីវិតដែលប្រសើរឡើង មានអាហារគ្រប់គ្រាន់ និង មានឱកាសសិក្សាសមរម្យ។



**2**
**សែននាក់**

### ផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់អតិថិជន

ដោយមានការប្តេជ្ញាខ្ពស់ពីបុគ្គលិកយើង បានធ្វើឲ្យជីវិតរាប់សែនគ្រួសារមានការផ្លាស់ប្រែ មានអនាគតដ៏ប្រសើរមួយសម្រាប់កូនៗរបស់ពួកគេ។



**90**
**លានដុល្លារ**

### ផលប័ត្រឥណទានសរុប

កម្ចីខ្នាតតូចរបស់ វីសិនហ្វាន់ ផ្តល់ឲ្យកសិករ សហគ្រិនធុនតូច និងមធ្យម និងអតិថិជនសក្តានុពលនានា នៅតាមសហគមន៍ដែលត្រូវការដើមទុនឬកំពុងជួបវិបត្តិហិរញ្ញវត្ថុនៅក្នុងគ្រួសារ។



**94%**
**ជាស្ត្រី**

### អតិថិជនភាគច្រើនជាស្ត្រី

វីសិនហ្វាន់ ផ្តល់អំណាចដល់ស្ត្រីតាមរយៈប្រាក់កម្ចីខ្នាតតូចក្នុងការបង្កើតអាជីវកម្ម និងពង្រីករបរកសិកម្ម ឬអាជីវកម្មរបស់ពួកគេ។

# អំពី វីសិនហ្វាន់

## យើងជឿជាក់ថាកុមារនឹងមានអនាគតភ្លឺស្វាង ដែលពួកគេទទួលបានសេចក្តីស្រលាញ់ពីព្រះ ដើម្បីកសាងជីវិតដ៏ពេញបរិបូរណ៍មួយ និងប្រកបដោយសេចក្តីសង្ឃឹម។

យើងផ្តល់អំណាចដល់ស្ត្រី និងគ្រួសាររបស់គេ តាមរយៈប្រាក់កម្ចីខ្នាតតូច និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត។ យើងជួយបង្កើតឲ្យមានបម្លាស់ប្រែចំពោះ អតិថិជនទាំងបុរស និងស្ត្រី តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងវិធីសាស្រ្ត ក្នុងការប្រកបអាជីវកម្មប្រកបដោយជោគជ័យដែលអាចជួយផ្តល់ប្រាក់ចំណូលទៀងទាត់ដល់ពួកគាត់។

យើងផ្តល់សក្តានុពលឲ្យសហគមន៍រីកលូតលាស់។ វីសិនហ្វាន់ ខេមបូឌា គឺជាផ្នែកមួយនៃបណ្តាញប្រតិបត្តិការរបស់ វីសិនហ្វាន់អន្តរជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )ដែលជាអង្គការគ្រិស្តបរិស័ទ អភិវឌ្ឍន៍ និងតស៊ូមតិអន្តរជាតិ។ យើងសហការគ្នាផ្តល់នូវមូលដ្ឋានគ្រឹះដល់សេដ្ឋកិច្ចក្នុងស្រុកដើម្បីឲ្យសហគមន៍រីកចម្រើនប្រកបដោយស្ថេរភាពនិង សុវត្ថិភាព។



## ទស្សនៈវិស័យរបស់យើង

ទស្សនៈវិស័យរបស់យើងគឺ ចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍ និងសូមឲ្យសេចក្ដីអធិស្ឋានរបស់យើងសូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសម្រេចបំណងនេះ

## បេសកកម្ម

**យើងជឿជាក់ថាកុមារនឹងមានអនាគតភ្លឺស្វាង** តាមរយៈការផ្ដល់អំណាចដល់គ្រួសាររបស់គេក្នុងការបង្កើតប្រាក់ចំណូល និងមានការងារធ្វើ នឹងពង្រីកសក្ដានុពលសេដ្ឋកិច្ចដើម្បីឲ្យសហគមន៍រីកលូតលាស់

**វីសិនហ្វាន់-ទទួលបានអំណាចហិរញ្ញវត្ថុពីអង្គការទស្សនៈពិភពលោក**

## តម្លៃស្នូលរបស់យើង

យើងជាគ្រិស្ដបរិស័ទ
យើងប្ដេជ្ញាចិត្តជួយដល់ជនក្រីក្រ
យើងឲ្យតម្លៃមនុស្ស
យើងជាអ្នកបម្រើដែលមានទំនួលខុសត្រូវខ្ពស់
យើងជាដៃគូ
យើងជាអ្នកឆ្លើយតប

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

## 1990s

ត្រូវបានបង្កើតឡើងជាសកម្មភាពមួយរបស់កម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) ។

## 2000

ត្រូវបានដាក់ឈ្មោះថាកម្មវិធីអភិវឌ្ឍន៍មីក្រូសហគ្រាសជាកម្មវិធីឥណទានមួយរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) ។

## 2003

កម្មវិធីអភិវឌ្ឍន៍មីក្រូសហគ្រាសបានក្លាយជាក្រុមហ៊ុនមួយបានចុះបញ្ជីដោយមានឈ្មោះថា វីសិនហ្វាន់ ខេមបូឌា ដោយធនាគាជាតិនៃកម្ពុជា។

## 2004

- ទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (ខែមិនា)ដោយមានឈ្មោះថា វីសិនហ្វាន់ ខេមបូឌា ។
- អតិថិជន វីសិនហ្វាន់ 6នាក់ ត្រូវបានគេទទួលស្គាល់ដោយ UNDP សម្រាប់ការប្រើប្រាស់កម្ចីដោយជោគជ័យ និងបានក្លាយជាសហគ្រិនគំរូ។

## 2005

- ចំនួនអតិថិជន 25,000នាក់
- ផលប័ត្រឥណទានជាង 3 លានដុល្លារអាមេរិក
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 7

## 2006

- ចំនួនអតិថិជន 35,000 នាក់
- ផលប័ត្រឥណទានជាង 6 លានដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាល់ជាវិជ្ជមានលើកុមារចំនួនជាង 243,400នាក់
- ទទួលបានពានរង្វាន់ចំណាត់ថ្នាក់ លេខ 1 ផ្នែកតម្លាភាពហិរញ្ញវត្ថុពីក្រុមប្រឹក្សាពិគ្រោះយោបល់ ជួយដល់ជនក្រីក្រ (CGAP របស់ធនាគារពិភពលោក)
- បានទទួល Alpha Minus (αe−) លើការវាយតម្លៃផ្នែកហិរញ្ញវត្ថុ ពីក្រុមហ៊ុនវាយតម្លៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អន្តរជាតិ

## 2007

- ចំនួនអតិថិជន 53.000 នាក់
- ផលប័ត្រឥណទានជាង 10លានដុល្លារអាមេរិក
- អតិថិជនជាស្ត្រីមានចំនួន 84%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 8

## 2008

- ចំនួនអតិថិជន 80,000 នាក់
- ផលប័ត្រឥណទានជាង 20 លាន ដុល្លារអាមេរិក
- អតិថិជនជាស្ត្រីមានចំនួន 84%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 12

## 2009

- ចំនួនអតិថិជន 100,000 នាក់
- ផលប័ត្រឥណទានជាង 21 លាន ដុល្លារអាមេរិក
- អតិថិជនជាស្ត្រីមានចំនួន 84%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 13
- ទទួលបានរង្វាន់ "កំរិតប្រាក់" ផ្នែកការរៀបចំរបាយការណ៍សមិទ្ធិផលសង្គមពីក្រុមប្រឹក្សាដើម្បីជួយជនក្រីក្រ(CGAP) រួមសហការជាមួយមូលនិធិម៉ៃឃើល និងស៊ូសានឌែល(Susan Dell) និងមូលនិធិហ្វដ (Ford) ។
- ទទួលបាន 4- លើពិន្ទុខ្ពស់បំផុត 5+ ពីការវាយតម្លៃលើសមិទ្ធផលសង្គមដែលធ្វើពី ស្ថាប័នវាយតម្លៃ Microfinance ឡើង ដោយ Planet Rating

## 2010

- ចំនួនអតិថិជន 110,000 នាក់
- ផលប័ត្រឥណទានជាង 30 លាន ដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាលជាវិជ្ជមានលើកុមារចំនួនជាង 440,000នាក់
- អតិថិជនជាស្ត្រីមានចំនួន 88%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 17
- ទទួលបាន រង្វាន់ Gold ពី MIX លើរបាយការណ៍សមិទ្ធផលសង្គម។

## 2011

- ចំនួនអតិថិជន 130,000 នាក់
- ផលប័ត្រឥណទានជាង 37 លាន ដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាលជាវិជ្ជមានលើកុមារចំនួនជាង 500,000នាក់
- អតិថិជនជាស្ត្រីមានចំនួន 90%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 19
- ទទួលបាន4- លើសមិទ្ធផលសង្គមពី Planet Rating
- ទទួលបានរង្វាន់ផ្លាទីនពី MIX លើតម្លាភាព និងបេសកកម្មសង្គម
- ទទួលបានអាជ្ញាប័ណ្ណ ប្រមូលប្រាក់សន្សំពីធនាគារជាតិនៃកម្ពុជា

## 2012

- ចំនួនអតិថិជន 159,000 នាក់
- ផលប័ត្រឥណទានជាង 48 លាន ដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាល់ជាវិជ្ជមានលើកុមារចំនួនជាង 556,000
- អតិថិជនជាស្ត្រីមានចំនួន 93%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 20
- ទទួលបាន BBB+ ពីស្ថាប័នវាយតម្លៃ Microfinanceza លើប្រតិបត្តិការហិរញ្ញវត្ថុ
- ទទួលបានរង្វាន់កំពូល Five Diamond ពីស្ថាប័នវាយតម្លៃ MIX

## 2013

- ចំនួនអតិថិជន 192,000 នាក់
- ផលប័ត្រឥណទានជាង 62 លាន ដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាល់ជាវិជ្ជមានលើកុមារចំនួនជាង 600,000 នាក់
- អតិថិជនជាស្ត្រីមានចំនួន 93%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 23
- ទទួលពានរង្វាន់2 ពី Oiko Credit លើសមិទ្ធផលសង្គម និងរង្វាន់សម្រាប់ការពង្រីកតំបន់ប្រតិបត្តិការ និងការផ្តល់សេវាទៅដល់អតិថិជនដែលមានជីវភាពខ្វះខាត
- បានទទួលរង្វាន់លើតម្លាភាពនៃតម្លៃពី MF Transparency
- បានទទួលរង្វាន់ S.T.A.R សម្រាប់តម្លាភាពសង្គម និងភាពមានទទួលខុសត្រូវពី MIX

## 2014

- ចំនួនអតិថិជន 228,000 នាក់
- ផលប័ត្រឥណទានជាង 90 លាន ដុល្លារអាមេរិក
- ផ្តល់ផលប៉ះពាល់ជាវិជ្ជមានលើកុមារចំនួនជាង 753,000
- អតិថិជនជាស្ត្រីមានចំនួន 94%
- ប្រតិបត្តិការក្នុងខេត្តក្រុងចំនួន 25
- ទទួលបាន BBB+ ពីស្ថាប័នវាយតម្លៃ Microfinanceza លើប្រតិបត្តិការហិរញ្ញវត្ថុ
- ទទួលបានរង្វាន់កំពូល Five Diamond ពីស្ថាប័នវាយតម្លៃ MIX (ខែកញ្ញា 2014 )

# ប្រវត្តិសង្ខេបអំពី វីសិនហ្វាន់

វីសិនហ្វាន់ ខេមបូឌា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែមួយគត់នៅកម្ពុជា ដែលមានបណ្តាញអន្តរជាតិក្នុង 35 ប្រទេសជុំវិញពិភពលោក ជាមួយ នឹងបេសកកម្មក្នុងការធ្វើឲ្យជីវិតកុមារមានភាពប្រសើរឡើង តាមរយៈការផ្តល់កម្ចីខ្នាតតូច និងសេវាហិរញ្ញវត្ថុផ្សេងៗដល់គ្រួសាររបស់ពួកគេ ។ វីសិនហ្វាន់ គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជា។

កិច្ចការរបស់យើង គឺផ្តល់អំណាចដល់អតិថិជនឲ្យទទួលបានជោគជ័យក្នុងអាជីវកម្ម ដែលនឹងផ្តល់លទ្ធភាពដល់កូនៗរបស់គេធំធាត់ ប្រកបដោយសុខភាពល្អ និងមានការសិក្សាអប់រំប្រសើរជាងមុន។ ក្នុងភាពជាដៃគូជាមួយ អង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) យើងប្តេជ្ញាធ្វើឲ្យមានការផ្លាស់ប្រែយូរអង្វែង ដែលនឹងផ្តល់សក្តានុពលរុងរឿងឲ្យមនុស្សជំនាន់ក្រោយៗទៀត ។

វីសិនហ្វាន់ បានកើតចេញពីកម្មវិធីឥណទានខ្នាតតូចរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) នាឆ្នាំ 1993 ហើយបានផ្តាច់ខ្លួនជាស្ថាប័នឯករាជ្យនៅឆ្នាំ 2003 ដែលជាសមាជិកសម្ព័ន្ធរបស់វីសិនហ្វាន់អន្តរជាតិ ដែលមានបណ្តាញគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងប្រតិបត្តិការក្នុង 35 ប្រទេសផ្សេងទៀតនៅទូទាំងពិភពលោក។

វីសិនហ្វាន់ បានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្នុងនាមជាស្ថាប័នផ្តល់សេវាហិរញ្ញវត្ថុនៅឆ្នាំ 2003 ហើយទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅឆ្នាំ 2004 និង នៅឆ្នាំ 2007 ទទួលបានអាជ្ញាប័ណ្ណមួយទៀត ដែលផ្តល់សិទ្ធិឲ្យ វីសិនហ្វាន់ ធ្វើប្រតិបត្តិការស្របច្បាប់ដោយគ្មានកាលកំណត់ ។

ដោយទទួលស្គាល់ថា សេវាហិរញ្ញវត្ថុមិនមែនជាឧបករណ៍តែមួយគត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ វីសិនហ្វាន់ បានបង្កើតទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាដៃគូជាមួយ និងអង្គភាពដែលផ្តោតលើសមិទ្ធផលសង្គមជាច្រើន។ សកម្មភាពនេះបានធ្វើឲ្យមានផលប៉ះពាល់ជាវិជ្ជមាន កាន់តែច្រើនឡើងដល់សង្គមព្រមទាំងជម្រុញឲ្យគោលដៅយុទ្ធសាស្ត្រ និងលទ្ធភាពប្រកួតប្រជែងរបស់ វីសិនហ្វាន់ កាន់តែមានភាពប្រសើរឡើងព្រមទាំងបង្កើតឲ្យមានភាពខុសប្លែកពីគេ ។

ចាប់តាំងពីពេលចាប់ផ្តើមរបស់ខ្លួន វីសិនហ្វាន់ ខេមបូឌា មានសេចក្តីសោមនស្សជាខ្លាំងដែលត្រូវបានទទួលស្គាល់ និង ទទួលបាននូវពានរង្វាន់ជាច្រើនពីបណ្តាស្ថាប័ននានា មានដូចជាវីសិនហ្វាន់អន្តរជាតិ ស្ថាប័នបម្លាស់ប្តូរព័ត៌មានមីក្រូហិរញ្ញវត្ថុ ក្រុមអ្នកប្រឹក្សាជួយជនក្រីក្រ (CGAP) United National Development Program (UNDP) និងពីស្ថាប័នជាច្រើនទៀត ដោយផ្តោតទៅលើសេវាហិរញ្ញវត្ថុ ការងារក្នុងសង្គម និង តម្លាភាពក្នុងការងារ។ នៅខែកុម្ភៈឆ្នាំ 2011 វីសិនហ្វាន់ ខេមបូឌា បានទទួលអាជ្ញាប័ណ្ណប្រមូលប្រាក់សន្សំ Microfinance Deposit Taking ពីធនាគារជាតិនៃកម្ពុជាហើយបានចាប់ផ្តើមផ្តល់សេវាប្រាក់សន្សំ ដល់អតិថិជនគោលដៅ។

វីសិនហ្វាន់ មានផលប័ត្រឥណទានជាង 91 លានដុល្លារអាមេរិក និងអតិថិជន ចំនួនជាង 228,948 គ្រួសារដែលភាគច្រើនរស់នៅជនបទ និងតំបន់ដាច់ស្រយាលនៅបណ្តាខេត្តក្រុងចំនួន 25ទៀត និងអត្រាបង់សងត្រឡប់គឺ 99.85% គិតត្រឹមថ្ងៃទី 31 ខែធ្នូឆ្នាំ2014។ ទន្ទឹមនឹងនេះដែរ យើងបានសម្រេចជោគជ័យលើការប្រមូលប្រាក់បញ្ញើសន្សំរបស់អតិថិជនជិត 15 លានដុល្លារអាមេរិក ពីអតិថិជនសរុបជាង3ម៉ឺននាក់សម្រាប់ឆ្នាំនេះ ។





“ខ្ញុំរីករាយណាស់ ដែលបានទទួលប្រាក់កម្ចីសម្រាប់តម្រូវការផ្នែកហិរញ្ញវត្ថុរបស់ខ្ញុំ តាំងពីវគ្គដំបូងរហូតដល់វគ្គទីប្រាំពីរ ពី វីសិនហ្វាន់”







**ស្តត់ ប្រោន**
ប្រធាន និងអគ្គនាយកប្រតិបត្តិ
វីសិនហ្វាន់អន្តរជាតិ

# សារពីលោក ស្កត់ ប្រោន

## ប្រធាន និងអគ្គនាយកប្រតិបត្តិ វីសិនហ្វាន់ អន្តរជាតិ

វីសិនហ្វាន់ ខេមបូឌា គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏រឹងមាំមួយក្នុងចំណោមគ្រឹះស្ថានដទៃទៀតនៅក្នុងបណ្តាញរបស់យើង។ តាមរយៈការផ្តួចផ្តើម និងសមិទ្ធផលដ៏ជោគជ័យរបស់ខ្លួន វីសិនហ្វាន់ បានក្លាយជាគំរូដ៏ល្អមួយសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដទៃទៀតទៅលើផ្នែកការងារសង្គម ភាពច្នៃប្រឌិតនៃផលិតផល និងនិរន្តរភាពផ្នែកហិរញ្ញវត្ថុ។

ឆ្នាំ 2014 គឺជាឆ្នាំដ៏ជោគជ័យមួយទៀតរបស់ វីសិនហ្វាន់ ខេមបូឌា ក្នុងការពង្រីកប្រតិបត្តិការនៅគ្រប់ខេត្តក្រុងទាំង25 ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជាក្រីក្រដែលរស់នៅតាមតំបន់ដាច់ស្រយាល។ វីសិនហ្វាន់ ខេមបូឌា បានបញ្ចប់ឆ្នាំសារពើពន្ធជាមួយនឹងផលប័ត្រឥណទានចំនួនជាង 90លានដុល្លារអាមេរិកស្មើ នឹងកំណើន 30% ពីឆ្នាំមុន។ កំណើននេះបានធ្វើឲ្យចំនួនអតិថិជនកើនដល់ 228,000 នាក់ដែលក្នុងនោះ ចំនួន 94% ជាស្ត្រី។ វីសិនហ្វាន់បានជះឥទ្ធិពលជាវិជ្ជមានដល់ជីវិតកុមារចំនួនជាង 750,000នាក់ដែលកំពុងរស់នៅសហគមន៍ក្រីក្រនៅប្រទេសកម្ពុជា ។

ក្នុងឆ្នាំនេះ វីសិនហ្វាន់ ខេមបូឌា បានផ្តោតសំខាន់លើការអប់រំរបស់កុមារ និងយុវជនដោយធ្វើការជាដៃគូជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) ដើម្បីផ្តួចផ្តើមគណនីកូនល្អ ក៏ដូចជាយុទ្ធនាការសង្គមផ្សេងៗដើម្បីជួយគាំទ្រការអប់រំក្នុងប្រទេសកម្ពុជា។ គណនីនេះបង្កើតឡើង ក្នុងគោលបំណងលើកទឹកចិត្តដល់ឪពុកម្តាយក្នុងការសន្សំប្រាក់សម្រាប់ការសិក្សារបស់កូនៗ ដើម្បីអនាគតដ៏រុងរឿងរបស់ពួកគេ។ ជាមួយនឹងការខិតខំប្រឹងប្រែងរបស់បុគ្គលិក និងភាពខ្លាំងរបស់ក្រុមការងារ ថ្មីៗនេះ វីសិនហ្វាន់ ខេមបូឌាបានទទួលការវាយតម្លៃក្នុងកម្រិត A- ដែលជាកម្រិតកំពូលមួយ ពីស្ថាប័នវាយតម្លៃ Planet Rating ដែលបង្ហាញពីភាពរឹងមាំនៃប្រតិបត្តិការរបស់ស្ថាប័នតាមរយៈប្រតិបត្តិការនិងការគ្រប់គ្រងដែលមានស្តង់ដាខ្ពស់ ។

វីសិនហ្វាន់ ខេមបូឌា គឺជាផ្នែកមួយនៃបណ្តាញ វីសិនហ្វាន់ សកល ។ យើងបានចាប់កំណើតនៅឆ្នាំ 2003 ពីអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) ហើយឥឡូវនេះយើងកំពុងធ្វើប្រតិបត្តិការនៅតាមបណ្តាញគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 35 ប្រទេស ហើយកាលពីឆ្នាំមុនយើងបានផ្តល់កម្ចីជូនដល់អតិថិជនជាងមួយលាននាក់ ដែលមានផលប័ត្រឥណទានសរុបចំនួន 606 លានដុល្លារអាមេរិក។ យើងជឿជាក់ថាកុមារ នឹងអាចមានអនាគតកាន់តែភ្លឺស្វាងដោយពួកគេទទួលបានសេចក្តីស្រលាញ់ពីព្រះ ដើម្បីកសាងជីវិតដែលពេញបរិបូរណ៍ និងប្រកបដោយសេចក្តីសង្ឃឹម។ យើងផ្តល់អំណាចដល់គ្រួសារ ដើម្បីបង្កើតចំណូលនិងការងារ និងផ្តល់សក្តានុពលសេដ្ឋកិច្ចដើម្បីឲ្យសហគមន៍រីកលូតលាស់ ។

យើងចូលរួមអបអរសាទរដល់ វីសិនហ្វាន់ ខេមបូឌា ចំពោះភាពជោគជ័យដ៏ឆ្នើម និងការចូលរួមចំណែកឆ្ពោះទៅរកការទទួលបានជោគជ័យជាសកលរបស់យើង។ យើងសូមថ្លែងអំណរគុណដល់ដៃគូសហការ និងអ្នកដែលពាក់ព័ន្ធទាំងក្នុងស្រុក និងក្រៅស្រុកទាំងអស់ចំពោះការគាំទ្រដល់យើង ក្នុងការនាំមកនូវភាពរីកចម្រើនប្រកបដោយនិរន្តរភាពមកដល់សហគមន៍របស់យើង។



ស្កត់ ប្រោន
ប្រធាន និងអគ្គនាយកប្រតិបត្តិ
វីសិនហ្វាន់ អន្តរជាតិ



**ជេសិន អ៊ីវែនស៍**
ប្រធានក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
វីសិនហ្វាន់ ខេមបូឌា និងជានាយកប្រចាំប្រទេស
របស់អង្គការ ទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )

# សារពីលោក ជេសិន អ៊ីវែនស៍

## ក្រុមប្រឹក្សាភិបាលនៃ វីសិនហ្វាន់ ខេមបូឌា និង ជានាយកប្រចាំប្រទេសនៃ អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )

### ជាមួយនឹងការរីកចម្រើនក្នុងឆ្នាំកន្លងទៅនេះ មានន័យថា យើងបានបង្កើនឱកាសទៅដល់គ្រួសារជាច្រើន និងផ្តល់អនាគតដ៏ភ្លឺស្វាងដល់កុមារកម្ពុជា។

អ្វីដែលខ្ញុំពេញចិត្តជាមួយនឹងវីសិនហ្វាន់ គឺវីសិនហ្វាន់ជាគំរូដ៏ល្អជាងគេបំផុតក្នុងនាមជា ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយ ដែលជួយដល់ជនក្រីក្រ និងផ្តោតលើការធ្វើឲ្យមានផលប៉ះពាល់ជាក់ស្តែងជាវិជ្ជមាន សម្រាប់ជីវិតដែលងាយជួបប្រទះហានិភ័យក្នុងការជំនះជាមួយនឹងភាពក្រីក្រ ។

សម្រាប់ឆ្នាំ2014 វីសិនហ្វាន់ ខេមបូឌា មានអតិថិជនចំនួន28% និងផលប័ត្រកម្ចីចំនួន32% នៃចំនួនអតិថិជន និងផលប័ត្រកម្ចីសរុបក្នុងបណ្តាញ វីសិនហ្វាន់អន្តរជាតិដែលមាន35 នៅជុំវិញពិភពលោក។ ក្នុងរយៈពេល 11 ឆ្នាំចុងក្រោយ ផលប័ត្រឥណទានបានកើនឡើងពី 1 លាន 5 សែនដុល្លារអាមេរិក ដល់ 91លានដុល្លារអាមេរិក បច្ចុប្បន្នមានចំនួនអតិថិជនជិត2សែន 3 ម៉ឺនគ្រួសារ ហើយគ្រឹះស្ថាននឹងបន្តបម្រើដល់អតិថិជនប្រមាណ 5 ម៉ឺនគ្រួសារថែមទៀតនៅឆ្នាំនេះ ។

សម្រាប់ខ្ញុំ តួលេខមួយនេះគឺពិតជាចំនួនមួយដែលល្អបំផុត ក៏ប៉ុន្តែអ្វីដែលគួរឲ្យរំភើប និងរីករាយបំផុតនោះ គឺនៅពេលដែលយើងឃើញថាកម្ចីទាំងនេះបានទៅដល់ជីវិតរបស់កុមារច្រើនជាង 7 សែន 5 ម៉ឺន នាក់នៅស្ទើរទូទាំងប្រទេស ឲ្យទទួលបាននូវជីវិតដ៏ភ្លឺស្វាងមួយ ។ លើសពីនេះទៅទៀត ជាមួយនឹងយុទ្ធសាស្រ្ត បន្ទាប់គឺយើងនឹងបន្តជួយដល់កុមាររហូតដល់ចំនួនមួយលាននាក់ នៅចុងឆ្នាំ 2016 ដើម្បីអនាគតដ៏ភ្លឺស្វាងរបស់ពួកគេ ។

ភាពជាដៃគូដ៏រឹងមាំរបស់វីសិនហ្វាន់ ជាមួយនឹង អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ គឺជាលទ្ធផលពីការផ្សារភ្ជាប់ទំនាក់ទំនងដ៏រឹងមាំ រវាងក្រុមប្រឹក្សាភិបាល និង អ្នកដឹកនាំទាំងអស់ដែលតែងតែសំឡឹងឃើញលទ្ធផលវិជ្ជមានល្អ និង ភាពប្រសើរឡើងក្នុងការរស់នៅរបស់កុមារកម្ពុជាដែលកើតចេញពីការសហការយ៉ាងជិតស្និទ្ធរបស់ស្ថាប័នទាំងពីរនេះ ។

បើទោះបីមានឧបសគ្គមួយចំនួនក៏យើងនៅតែបន្តដំណើរការប្រពន្ធ័ ធនាគារចល័តក្នុងពេលឆាប់ៗនេះដើម្បីជួយបង្កើននូវប្រសិទ្ធិភាព និងសមិទ្ធផលរបស់យើង ហើយយើងនៅតែបន្តធ្វើការងារដើម្បីទទួលបានលទ្ធផលរឹតតែប្រសើរនាពេលខាងមុខ ។

ក្នុងពេលវេលានេះផងដែរ ដោយភាពគោរពស្រលាញ់ ខ្ញុំសូមជូនពរ ដល់ការចូលនិវត្តន៍របស់លោក ឈីឈិនហូ ដែលជាអគ្គនាយកប្រតិបត្តិរបស់ វីសិនហ្វាន់ខេមបូឌា និងក៏ជាមិត្តល្អរបស់ខ្ញុំផងដែរដែលលោកបានចំណាយរយៈពេលជាង5ឆ្នាំនិងបានផ្តល់នូវការដឹកនាំមួយដ៏រីកចម្រើនមកដល់ស្ថាប័ន ហើយសូមឲ្យព្រះប្រទានពរដល់គាត់ក្នុងដំណើរចូលនិវត្តន៍ដើម្បីត្រលប់ទៅប្រទេសម៉ាឡេស៊ីវិញ និងបានមានពេលវេលាជាមួយនឹងគ្រួសារជាទីស្រលាញ់ផងដែរ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងជំរាបជូនលោកអ្នកផងដែរថា អគ្គនាយកប្រតិបត្តិថ្មីរបស់ វីសិនហ្វាន់ខេមបូឌា នឹងនាំមកនូវបទពិសោធន៍លើវិស័យមីក្រូហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំសម្រាប់ វីសិហ្វាន់ខេមបូឌា ។

ដោយសេចក្តីរាប់អានយ៉ាងជ្រាលជ្រៅពីខ្ញុំ!

ជេសិន អ៊ីវែនស៍

ប្រធានក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ខេមបូឌា និងជានាយកប្រចាំប្រទេសរបស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )



**ឈី ឈិនហួ**
អគ្គនាយកប្រតិបត្តិរបស់គ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់

# សារពីលោក ឈី ឈិនហូ

## អគ្គនាយកប្រតិបត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់

ដោយ ព្រះគុណព្រះជាម្ចាស់ និងកិច្ចគាំទ្រពីស្ថាប័នរដ្ឋ អ្នកពាក់ព័ន្ធក៏ដូចជាដៃគូ អាជីវកម្មផ្សេងៗ ទើបគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ អាចឈានមក ដល់ស្ថានភាពបច្ចុប្បន្ននេះ។ ចាប់ផ្តើមកាលពី10ឆ្នាំមុន យើងបានរីកចម្រើននិងក្លាយជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំមួយក្នុងចំណោមគ្រឹះស្ថានធំៗជាច្រើននៅកម្ពុជា ដែលឈោងចាប់អតិថិជនចំនួនជាង 228,000នាក់ និងផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់ជីវិតកុមារជាង 753,000នាក់ ជាមួយនឹងផលប័ត្រឥណទានជាង 90 លានដុល្លារអាមេរិក។ បច្ចុប្បន្ននេះ បណ្តាញគ្រឹះស្ថានរបស់យើងគ្របដណ្តប់ទូទាំង 25 សាខាខេត្ត-ក្រុង ដែលមាន នីយោជិកប្រមាណជិត 1,200នាក់។

យើងបាននឹងកំពុងមានឆ្នាំពិសេសមួយផ្សេងទៀតនៅក្នុង វីសិនហ្វាន់ ខេមបូឌា គឺយើងបានឃើញនូវកំណើនបន្ថែមទៀតនៅទូទាំងសកល ដែលតែងតែរក្សាបាននូវបេសកកម្ម និងចក្ខុវិស័យ នៅក្នុងផ្នត់គំនិតរបស់យើង។ ជាងនេះទៅទៀតការប្រឹងប្រែងពីបុគ្គលិកគ្រឹះស្ថានយើងខ្ញុំបានខិតខំធ្វើការយ៉ាងសកម្ម ពីមួយឆ្នាំទៅមួយឆ្នាំបានធ្វើឲ្យមានសន្ទុះខ្លាំងសម្រាប់ឆ្នាំនេះ ដែលជាមោទនភាពមួយ ក៏ដូចជាថ្លែងអំណរគុណជាអនេកដល់ការអនុវត្តគំនិតថ្មីៗ និងការប្តេជ្ញាចិត្តដ៏មោះមុត គឺមានមុនគេនៅក្នុងចិត្តរបស់យើងហើយយើងខ្ញុំនឹងបន្តនូវគំរូនេះជានិរន្តិ៍។

ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបានសមាហ-រណកម្មជាមួយការងារអភិវឌ្ឍន៍របស់អង្គការទស្សនៈ-ពិភពលោកអន្តរជាតិ វីសិនហ្វាន់ គឺជាស្ថាប័នដែលខុសពីស្ថាប័នហិរញ្ញវត្ថុដទៃទៀត។សេវាកម្មផ្សេងៗរបស់យើងជួយឲ្យប្រជាជនបង្កើតមូលដ្ឋានជីវិតដ៏រឹងមាំនិង ពង្រីកអាជីវកម្មរបស់ពួកគេដោយជោគជ័យ។ ភាពជាដៃគូរបស់យើងជាមួយនិងអង្គការទស្សនៈពិភលោកអន្តរជាតិ( កម្ពុជា )បង្ហាញថាការធ្វើឲ្យជីវិតពេញបរិបូរណ៍ប្រជាជនអាចចាកចេញពីភាពក្រីក្រដែលមានយូរមកហើយ ឈានទៅរកអនាគតដ៏ភ្លឺស្វាងមួយ។

វីសិនហ្វាន់ ឈរក្នុងតំណែងលេខ 4 លើចំនួនអតិថិជននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ ចំនួនអតិថិជនដែលកំពុងទទួលសេវាកម្មប្រាក់កម្ចីបានកើនពី 194,780នាក់នៅឆ្នាំ 2013 ដល់ 228,948នាក់ក្នុងឆ្នាំ2014 ដែលបានប៉ះពាល់ដល់ជីវិតកុមារជាង 753,000នាក់ ។ ដោយឡែកផលប័ត្រឥណទានបានកើនឡើងពី 62 លានដុល្លារអាមេរិក ដល់ ជាង 91លានដុល្លារអាមេរិកក្នុងឆ្នាំនេះ។ អរគុណដល់បុគ្គលិកប្រមាណជាង 1,200នាក់ ដែលធ្វើឲ្យយើងអាចពង្រីកតំបន់ប្រតិបត្តិការក្នុង 25ខេត្ត-រាជធានី ។

ទោះបីជាមានគ្រោះមហន្តរាយធម្មជាតិក្តី ផលប័ត្រឥណ-ទានមានហានិភ័យ > 30 ថ្ងៃគឺនៅមានកម្រិតទាបត្រឹមតែ 0.25% គិតត្រឹមខែធ្នូ ឆ្នាំ2014។ សេវាប្រាក់កម្ចីមិនមែនសម្រាប់អាជីវកម្ម គឺនៅតែបន្តបំពេញបន្ថែមលើសេវាហិរញ្ញវត្ថុរបស់យើង ដើម្បីចូលរួមចំណែកក្នុងកិច្ចការសង្គមដែលមានដូចជា កម្ចីសម្រាប់ការសិក្សា អនាម័យទឹកស្អាត និងសុខភាព ក៏ដូចជាសេវាអប់រំផ្នែកហិរញ្ញវត្ថុដើម្បីបង្រៀនអតិថិជនឲ្យចាត់ចែងលុយកាក់របស់ពួកគាត់បានប្រសើរឡើង រួមទាំងការចាត់ចែងសម្រាប់ការសងប្រាក់ផងដែរ ។

ក្នុងចំណោមបណ្តាញអន្តរជាតិទាំង35ប្រទេស វីសិនហ្វាន់ ខេមបូឌា ទទួលបាននូវការទទួលស្គាល់ជាបន្តបន្ទាប់ពី វីសិនហ្វាន់ អន្តរជាតិ ថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេ និងមានសមិទ្ធផលខ្ពស់ផងដែរ។ យើងបានធ្វើការងារជាមួយ អង្គការទស្សនៈពិភពលោកកម្ពុជាប្រកបដោយពហុគុណកម្លាំងដើម្បីពង្រឹង ទស្សនវិស័យរួមរបស់យើង សម្រាប់កុមារគ្រប់រូបទទួលបានជីវិតពេញបរិបូរណ៍។

## លទ្ធផលផ្នែកហិរញ្ញវត្ថុ

ប្រាក់ចំណេញសុទ្ធរបស់ វីសិនហ្វាន់ ខេមបូឌា មានរហូតដល់2.57លានដុល្លារអាមេរិក ក្នុងឆ្នាំ2014ដោយបានរក្សានិរន្តរភាពហិរញ្ញវត្ថុឲ្យនៅកំរិត107% ដែលបញ្ជាក់ពីការកើនឡើងនូវគុណភាពកម្ចីនិងការគ្រប់គ្រងចំណាយប្រតិបត្តិការនិងចំណាយហិរញ្ញវត្ថុបានល្អតាមរយៈផលិតភាព។ ចំណូលធៀបនឹងទ្រព្យសកម្មបានកើនឡើងដល់ 2.9%។ ផលប័ត្រឥណទានមានកំណើន 47% គឺពី61.6លានដុល្លារអាមេរិកដល់90.9លានដុល្លារអាមេរិក ដែលរួមចំណែកដល់ការកើនឡើងនៃទ្រព្យសកម្ម ។

សម្រាប់ ឆ្នាំ2014នេះ វីសិនហ្វាន់ បានទទួលការវាយតម្លៃអោយស្ថិតក្នុងកម្រិតថ្នាក់ល្អប្រសើរ “A-” ជាថ្នាក់ខ្ពស់បំផុត សម្រាប់ការងាររបស់យើងក្នុងការលើកកម្ពស់ជីវិតឲ្យប្រសើរឡើងរបស់កុមារកម្ពុជា និងសហគមន៍ ។ វីសិនហ្វាន់ ទទួលបានរង្វាន់(ត្រា)តម្លាភាពដ៏ខ្ពង់ខ្ពស់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ផ្នែកតម្លាភាពលើតម្លៃផលិតផលរបស់យើង ដែលសបញ្ជាក់ថា ការងាររបស់ វីសិនហ្វាន់ ខេមបូឌា ទទួលបានការផ្តល់តម្លៃយ៉ាងខ្លាំងក្លាពីវិស័យនេះ ។

ក្នុងឆ្នាំនេះ ក៏មានការដាក់បង្ហាញផលិតផលសន្សំថ្មីមួយក្រោមកិច្ចសហប្រតិបត្តិការជាដៃគូ ដែលមានដូចជាគណនីកូនល្អជាដើម។ ការបន្តវិនិយោគក្នុងទឹកស្អាតនិងអនាម័យ(អនាម័យនិងទឹកស្អាត) រួមបញ្ចូលទាំងការផ្តល់ប្រាក់កម្ចីសម្រាប់ទិញធុងចម្រោះទឹកប្រាក់កម្ចីសម្រាប់បង្គន់អនាម័យ និងប្រាក់កម្ចីសម្រាប់ផលិតផលដើរដោយថាមពលពន្លឺព្រះអាទិត្យ។ យើងបាននឹងកំពុងបន្ត ឲ្យមានការផ្តោតសំខាន់ទៅលើការផ្តល់អំណាចដល់ស្ត្រីក្នុងនោះមាន 94% ជាស្ត្រី។ យើងបានធ្វើការស្រាវជ្រាវដើម្បីកំណត់នូវអ្វីដែលផ្តល់ផលប្រយោជន៍ដល់កុមារដែលទទួលបានជាលទ្ធផលនៃការផ្តល់កម្ចីពី វីសិនហ្វាន់ ខេមបូឌា ដោយមាន 99% នៃអតិថិជនគំរូ បានបង្ហាញពីផលប្រយោជន៍មួយចំនួននៃប្រាក់កម្ចីសម្រាប់កូនៗរបស់ពួកគេ ។

ផលប្រយោជន៍សំខាន់ៗបីយ៉ាង លើសុខមាលភាពកុមារ (CWBO) រួមមាន៖

1. អនាម័យមានភាពប្រសើរឡើង(62%)
2. សម្លៀកបំពាក់/ ស្បែកជើងបន្ថែម (59%) និង
3. ផ្តល់ប្រាក់សម្រាប់ការចំណាយលើសុខភាពកុមារ (57%) ។

យើងស្ថិតនៅក្នុងចំណោមមីក្រូហិរញ្ញវត្ថុដំបូងគេនៅក្នុងកម្ពុជាដែលបានសាកល្បងកម្មវិធីសំណាញ់សុវត្ថិភាព ដោយយើងនឹងលុបចោលនូវបំណុលរបស់អតិថិជន នៅពេលដែលពួកគាត់ទទួលមរណៈភាព ដូច្នេះអ្នកដែលនៅរស់មិនត្រូវបានរែកពុននូវបំណុល ។ ទោះបីជាត្រូវចំណាយមួយចំនួនក្តី យើងនៅតែបន្តផ្តល់នូវអត្ថប្រយោជន៍នេះដល់អតិថិជនរបស់យើងដោយគ្មានគិតកម្រៃសេវាឡើយ ។

ដើម្បីគាំទ្រក្នុងការសិក្សាឲ្យបានខ្ពង់ខ្ពស់ វីសិនហ្វាន់ បានរៀបចំ និងឧបត្ថម្ភកម្មវិធីអាហារូបករណ៍ទូទាំងប្រទេសដើម្បីជួយដល់សិស្សក្រីក្រដែលមានទេពកោសល្យអាចបន្តការសិក្សា របស់ពួកគេឲ្យបានខ្ពង់ខ្ពស់។



## ការពង្រឹងផ្នែកទំនាក់ទំនង/បច្ចេកវិទ្យាព័ត៌មាន

វីសិនហ្វាន់អន្តរជាតិ បានទទួលស្គាល់ វីសិនហ្វាន់ ខេមបូឌា ដោយសារតែមានគំនិតបង្កើតថ្មី ដែលមានដូចជា មីក្រូហិរញ្ញវត្ថុដំបូងក្នុងកម្ពុជាដែលមានការសហការជាមួយប្រតិបត្តិករផ្ទេរប្រាក់ តាមរយៈទូរស័ព្ទដៃ តាំងពីជាង 5ឆ្នាំមុន។

គិតមកដល់ខែធ្នូ ឆ្នាំ2014 យើងបានអភិវឌ្ឍប្រព័ន្ធស្នូលនៃធនាគារ(Core Banking System) ទៅប្រើ T24 និងបានពង្រីកទៅកាន់គ្រប់សាខាខេត្ត និង សាខាស្រុកមួយចំនួនទៀតផងដែរ។ ប្រព័ន្ធថ្មីបានធ្វើសមាហរណកម្មបញ្ចូលប្រាក់កម្ចីប្រាក់សន្សំ រតនាគារ និងគណនេយ្យទៅក្នុងប្រព័ន្ធតែមួយដែលឲ្យយើងធ្វើប្រតិបត្តិការបានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

យើងកំពុងតែដំណើរការ បង្កើតនិងអនុវត្តនូវគម្រោង Tablet (Automated Business Process)នៅឆ្នាំខាងមុខដើម្បីកាត់បន្ថយការងារ និងដំណើរការផ្សេងៗ។

## ចក្ខុវិស័យសម្រាប់ឆ្នាំ 2015

ជាមួយនិងការរំពឹងទុកថាសេដ្ឋកិច្ចកម្ពុជានឹងរីកចម្រើនក្នុងឆ្នាំ2015 យើងនឹងនៅតែបន្តពង្រីកតំបន់ប្រតិបត្តិការទៅ ទីកន្លែងដែលត្រូវការក្នុងការលើកស្ទួយជីវិតកុមារ ស្ត្រី និងសហគមន៍ដែលមិនបានទទួលការបម្រើពីមុន។ ដើម្បីផ្តល់សេវារបស់យើង ប្រកបដោយគុណភាពនិងតម្លៃថោកក្នុងរយៈពេលវែង យើងនឹងដាក់ទុនបន្ថែមទៀតលើបច្ចេកវិទ្យា ដើម្បីអភិវឌ្ឍដំណើរការប្រតិបត្តិការរបស់យើង។ យើងនឹងខិតខំក្នុងការលើកកម្ពស់ផលិតភាពរបស់យើងដើម្បីជាប្រយោជន៍ដល់អតិថិជន។

## ការថ្លែងអំណរគុណ

យើងសូមដឹងគុណដល់ វីសិនហ្វាន់ អន្តរជាតិ ដែលបានផ្តល់ទាំងហិរញ្ញវត្ថុនិងជំនួយផ្នែកបច្ចេកទេសដល់ វីសិនហ្វាន់ ខេមបូឌា តាំងពីពេលចាប់ផ្តើម។ ដូចគ្នានេះដែរ យើងសូមថ្លែងអំណរគុណដល់អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )សម្រាប់ការបន្តគាំទ្រ និងកិច្ចសហប្រតិបត្តិការក្នុងការផ្តល់អំណាចដល់យើងដើម្បីបំពេញបេសកកម្មកន្លងមក។



ក៏សូមកោតសរសើរដោយស្មោះស្ម័គ្រចំពោះក្រុមប្រឹក្សា-ភិបាល ដែលបានផ្តល់ការណែនាំ និងតម្រង់ទិសដៅសម្រាប់ វីសិនហ្វាន់ ខេមបូឌា។

យើងសូមទទួលស្គាល់កិច្ចខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត និងការចំណាយពេលវេលា ព្រមទាំងភាពស្មោះត្រង់របស់បុគ្គលិក វីសិនហ្វាន់ គ្រប់ជាន់ថ្នាក់។ យើងសូមថ្លែងអំណរគុណជាពិសេស ចំពោះអតិថិជន ដៃគូម្ចាស់ជំនួយ អ្នកផ្តល់កម្ចី និងទីភ្នាក់ងាររដ្ឋាភិបាល ជាពិសេសធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរមូលដ្ឋានដែលបានជួយគាំទ្រ និងប្រើប្រាស់សេវាកម្មរបស់យើង។ យើងសូមថ្វាយនូវរាល់ភាពជោគជ័យទាំងឡាយដល់ព្រះជាម្ចាស់ដែលជាប្រភពជួយជម្រុញយើងឲ្យទទួលបានជោគជ័យ។

សូមព្រះជាម្ចាស់ប្រទានពរដល់លោកអ្នក។



**ឈី ឈិនហូ**
អគ្គនាយកប្រតិបត្តិរបស់
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់

# ក្រុមប្រឹក្សាភិបាល



## លោក ជេសិន ជេមស៍ អ៉ីវេនស៍

ប្រធានក្រុមប្រឹក្សាភិបាល
វីសិនហ្វាន់ ខេមបូឌា នាយកប្រចាំប្រទេស
អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា)

លោក ជេសិន ជេមស៍ អ៉ីវេនស៍ (Jason James Evans) មានសញ្ជាតិអង់គ្លេស ស្វីស លោក ជេសិន បានដើរតួនាទីជាអ្នកដឹកនាំសកលមួយរូប ក្នុងការអភិវឌ្ឍសហគមន៍អស់រយៈពេល 20ឆ្នាំក្នុង នោះលោកបានចំណាយពេល12 ឆ្នាំធ្វើការជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ ក្នុងមុខតំណែងជានាយកប្រចាំតំបន់។ លោក ជេសិន មានបទពិសោធន៍សំខាន់ៗទាក់ទងនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងបានកាន់មុខតំណែងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ ក្នុងប្រទេសហ្សកហ្ស៊ី(ចាប់ពីឆ្នាំ 2003 ដល់ ឆ្នាំ 2012)នៅ អាល់បានី (ពីឆ្នាំ2006 ដល់ឆ្នាំ 2012) និង ប្រទេសកូសូវ៉ូ(ពីឆ្នាំ2010ដល់ឆ្នាំ 2012) ។



## លោក ឈី ឈិនហូ

សមាជិកក្រុមប្រឹក្សាភិបាល និង
ជាអគ្គនាយកប្រតិបត្តិ
វីសិនហ្វាន់ ខេមបូឌា

លោក ឈី ឈិនហូ មានសញ្ជាតិ ម៉ាឡេស៊ី បានចូលបម្រើការងារនៅ វីសិនហ្វាន់ ក្នុងមុខនាទីជាអគ្គនាយកប្រតិបត្តិនៅក្នុង ខែកុម្ភៈ ឆ្នាំ2010។ មុននឹងចូលកាន់តំណែងនេះលោក គឺជាប្រធានរដ្ឋបាល និងគាំពារសេវាឥណទាន នៃធនាគារពាណិជ្ជឈានមុខគេមួយនៅប្រទេសម៉ាឡេស៊ី។ លោកមានបទពិសោធន៍ជាង 33 ឆ្នាំខាងផ្នែកធនាគារពីធនាគារចំនួនពីរផ្សេងគ្នា។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយទាំងប្រតិបត្តិការធនាគារ និងឥណទានហើយលោកធ្លាប់ មានតួនាទីក្នុងជួរថ្នាក់ដឹកនាំ និងគ្រប់គ្រងនៅលំដាប់សាខាតំបន់ និងការិយាល័យកណ្តាល ។ លោកគឺជាអ្នកជំនាញអាជីពផ្នែកឥណទាននៅវិទ្យាស្ថាន នៃធនាគារនៅប្រទេសម៉ាឡេស៊ី ហើយលោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ។



## លោក ឆឹង ឈិនគ័ន

សមាជិកក្រុមប្រឹក្សាភិបាល បម្រើការនៅម៉ាឡេស៊ី

លោក ឆឹង មានសញ្ជាតិម៉ាឡេស៊ី។ លោកមានបទពិសោធន៍ជាង3ទសវត្សរ៍ នៅក្នុងធនាគារពីរ ដែលឈានមុខគេនៅប្រទេសម៉ាឡេស៊ី ហើយបានទទួលតំណែងចុងក្រោយជាប្រធានប្រចាំប្រទេសក្នុងធនាគារបរទេសឈានមុខមួយ។ តែក្រោយមក លោកបានផ្លាស់ទៅធ្វើការនៅ ភាគខាងកើតនៃប្រទេសម៉ាឡេស៊ីជាតំបន់ដែលមានការអភិវឌ្ឍតិចតួច ដោយទទួលយកតំណែងជាប្រធានប្រចាំតំបន់វិញក្នុងគោលបំណងជួយអភិវឌ្ឍសហគមន៍ក្នុងតំបន់នោះ ជាពិសេសក្រុមនិស្សិត។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ សេដ្ឋកិច្ចពីសាកលវិទ្យាល័យម៉ាឡេស៊ីនៃប្រទេសម៉ាឡេស៊ី ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានសិក្សាកម្មវិធីអន្តរជាតិជាច្រើន។ លោក ឆឹង ក៏ជាសហការីជាន់ខ្ពស់នៃវិទ្យាស្ថានភ្នាក់ងារធនាគារម៉ាឡេស៊ី (Institute of Bankers Malaysia) ផងដែរ ។



## លោក ចាប វិបុល

សមាជិកក្រុមប្រឹក្សាភិបាល នៃអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )

លោកវិបុល បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអភិវឌ្ឍន៍ ពី Asian School of Development and Cross Cultural Studies និងទទួលបានវិញ្ញាបនបត្រផ្នែកជំនួយមនុស្សធម៌ពីសាកលវិទ្យាល័យមែលប៊ិន និង វិញ្ញាបនបត្រ ក្នុងកម្មវិធីភាពជាអ្នកដឹកនាំមនុស្សធម៌ពី សាកលវិទ្យាល័យ ដេគិនប្រទេសអូស្ត្រាលី។

លោកវិបុល មានបទពិសោធន៍ទូលំទូលាយជាង 22 ឆ្នាំមក ហើយនៅក្នុងវិស័យអភិវឌ្ឍន៍ និងបានបម្រើការងារជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) ជាង 14 ឆ្នាំផងដែរ។ លោក វិបុល បានផ្តល់ភាពជាអ្នកដឹកនាំការគាំទ្រ និងការសម្របសម្រួលទៅដល់ការប្រតិបត្តិការទាំងអស់នៅក្នុង អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) ដើម្បីធានាឲ្យបាននូវការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាព បំពេញតាមគោលដៅ និងគោលបំណងរបស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) និងដៃគូសហគមន៍ដើម្បីឲ្យស្របជាមួយនឹងយុទ្ធសាស្រ្ត និងធានាឲ្យបាននូវការធ្វើសមាហរណកម្មលើគម្រោង និងកម្មវិធីទាំងអស់ជាមួយសហគមន៍ និងដៃគូក្នុងស្រុកជាដើម។



## លោកស្រី ហ្វីអូណា វ៉ាយត៍

**សមាជិកក្រុមប្រឹក្សាភិបាល**
**បម្រើការនៅនូវែលហ្សេឡង់**

លោកស្រី ហ្វីអូណា វ៉ាយត៍ មានសញ្ជាតិនូវែលហ្សេឡង់។ លោកស្រី ធ្លាប់ជាអ្នកស្ម័គ្រចិត្តក្នុងកម្មវិធី Banker with Vision របស់ វីសិនហ្វាន់ អន្តរជាតិជាមួយ វីសិនហ្វាន់ ខេមបូឌា។ លោកស្រី មានបទពិសោធន៍ផ្នែកធនាគារ អស់រយៈពេល 23 ឆ្នាំ នៅនូវែលហ្សេឡង់ និងមានបទពិសោធន៍ 12 ឆ្នាំក្នុងការងារគ្រប់គ្រងហានិភ័យរូបិយប័ណ្ណអន្តរជាតិ។ លោកស្រី បានបញ្ចប់ការសិក្សាផ្នែកពាណិជ្ជកម្មនិងគ្រប់គ្រងអាជីវកម្មអន្តរជាតិនៅសកលវិទ្យាល័យ Massey នៃប្រទេសនូវែលហ្សេឡង់ក្នុងឆ្នាំ 2007។ លោកស្រី ក៏ជាអ្នកតំណាងមួយរូបនៃស្ថាប័ន NZ Institute of Chartered Accountants Business Development Special Interest Group។ លោកស្រីក៏ជាអ្នកសម្របសម្រួលមួយ រូបលើមុខវិជ្ជាចាត់ចែងថវិកា CAP Money នៅក្នុង Auckland ប្រទេសនូវែលហ្សេឡង់។



## លោក ម៉ែខលចន ស្ទីងឃ្លើ

**សមាជិកក្រុមប្រឹក្សាភិបាល វីសិនហ្វាន់ ខេមបូឌា**
**នាយក វីសិនហ្វាន់ អន្តរជាតិ ប្រចាំតំបន់អាស៊ី**
**បម្រើការនៅទីក្រុងបាងកក**

លោក ម៉ែខល ស្ទីងឃ្លើ គឺជាអ្នកជំនាញ ផ្នែកហិរញ្ញវត្ថុ ដែលមានបទពិសោធន៍ ការងារជិត 20ឆ្នាំ ក្នុងកិច្ចការងារអភិវឌ្ឍមាន ដូចជាផ្តល់ការពិគ្រោះយោបល់ផ្នែកយុទ្ធសាស្ត្រ ជំនួយបច្ចេកទេស និងសេវាពង្រឹងសមត្ថភាពដល់អង្គការអន្តរជាតិ អង្គការក្រៅរាជរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុធនាគារ និង/ឬ សហជីពឥណទាន នៅកម្ពុជា ភីលីពីន ថៃ ឥណ្ឌូនេស៊ី ទីម័រខាងកើត (East Timor) វៀតណាម មីយ៉ាន់ម៉ា ស្រីលង្កា ឥណ្ឌា ម៉ុងហ្គោលី អេស៊ីប ហ្គាណា និង នីហ្សេរីយ៉ា (Nigeria)។ លោកក៏ធ្លាប់បម្រើការងារក្នុង គ្រឹស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត និងបានធ្វើការជាមួយ CRS និង Chemonics ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ អ្នកដឹកនាំប្រចាំតំបន់ផ្នែកបច្ចេកទេស និងអភិវឌ្ឍសមត្ថភាពក្នុងគម្រោងនានា។ នាពេលបច្ចុប្បន្ន លោក ម៉ែខលគឺជាសមាជិកក្រុមប្រឹក្សាក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ប្រចាំតំបន់អាស៊ីអាគ្នេយ៍ទាំង 6 ស្ថាប័ន។



## លោក គ្រិស ប្រាយអាន

### សមាជិកក្រុមប្រឹក្សាភិបាល បម្រើការនៅកម្ពុជា

លោក គ្រិស មានសញ្ជាតិនូវែលហ្សេឡង់។ លោកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ Lincoln ខាងផ្នែកកសិអាជីវកម្ម មានបទពិសោធន៍ការងារផ្នែកហិរញ្ញវត្ថុនៅតំបន់ជនបទ ការគ្រប់គ្រងកសិដ្ឋានការអភិវឌ្ឍក្រុមហ៊ុន និងទីផ្សារការនាំចេញ និងការធ្វើគម្រោងអាជីវកម្ម។ លោកធ្លាប់ជាសមាជិកនៃក្រុមប្រឹក្សារបស់នាយករដ្ឋមន្ត្រីនូវែលហ្សេឡង់ ប្រមាណ 3ឆ្នាំ គឺបានផ្តល់ប្រឹក្សាដល់នាយករដ្ឋមន្ត្រី 2រូប លើបញ្ហាទាក់ទងនិងវិស័យស្ទូលនៅនូវែលហ្សេឡង់ ។

លោក មានបទពិសោធន៍ច្បាស់លាស់ក្នុងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងបុគ្គលិកការធ្វើ គម្រោងផែនការការប្រតិបត្តិតាម និង ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ។ លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន និង សហគមន៍អង្គការមនុស្សធម៌ទាំងនៅក្នុង និងក្រៅប្រទេសនូវែលហ្សេឡង់ ដោយគាត់ប្រកាន់យកអភិបាលកិច្ចល្អ ដល់ស្ថាប័នទាំងអស់នេះជាចម្បង។

# អំពីគណៈគ្រប់គ្រង





## លោក ឈី ឈិនហូ

### អគ្គនាយកប្រតិបត្តិ

លោក ឈី ឈិនហូ មានសញ្ជាតិម៉ាឡេស៊ី បានចូលបម្រើការងារនៅ វីសិនហ្វាន់ ក្នុងមុខនាទីជាអគ្គនាយកប្រតិបត្តិនៅក្នុង ខែកុម្ភៈ ឆ្នាំ2010។ មុននឹងចូលកាន់តំណែងនេះលោក គឺជាប្រធានរដ្ឋបាល និងគាំពារសេវាឥណទាន នៃធនាគារពាណិជ្ជឈានមុខគេមួយនៅប្រទេសម៉ាឡេស៊ី។

លោកមានបទពិសោធន៍ជាង 33 ឆ្នាំខាងផ្នែកធនាគារពីធនាគារចំនួនពីរផ្សេងគ្នា។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយទាំងប្រតិបត្តិការធនាគារនិងឥណទាន ហើយលោកធ្លាប់ មានតួនាទីក្នុងជួរថ្នាក់ដឹកនាំ និងគ្រប់គ្រងនៅលំដាប់សាខាតំបន់ និងការិយាល័យកណ្តាល។

លោកគឺជាអ្នកជំនាញអាជីពផ្នែក ឥណទាននៅវិទ្យាស្ថាននៃធនាគារនៅប្រទេសម៉ាឡេស៊ី ហើយលោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ។

## លោក វេសលី ចូដាន់

### អគ្គនាយកហិរញ្ញវត្ថុ

លោក វេសលី បានចូលបម្រើការនៅ វីសិនហ្វាន់ ក្នុងខែឧសភា ឆ្នាំ2014 ហើយលោកមានបទពិសោធន៍ការងារជាង15 ឆ្នាំ ទៅលើជំនាញហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រតិបត្តិការក្នុងវិស័យធនាគារ ការគ្រប់គ្រងគម្រោងភាពបង្កើតថ្មី និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ លោកធ្លាប់បានបម្រើការជាមួយ វីសិនហ្វាន់ នៅប្រទេសអាហ្វ្រិកហើយមុនចូលបម្រើការជាមួយ វីសិនហ្វាន់ ខេមបូឌា លោកបានធ្វើការជាមួយ PACT GLOBAL MICROFINANCE FUND នៅប្រទេសភូមា ក្នុងមុខតំណែងជានាយកហិរញ្ញវត្ថុ។ មិនត្រឹមតែប៉ុណ្ណោះ លោកក៏បានធ្វើការក្នុងមុខតំណែងជាន់ខ្ពស់ជាច្រើនទៀត នៅប្រទេសសៀរ៉ាឡេអូន សាធារណរដ្ឋ ប្រជាធិបតេយ្យ

លោក វេសលី មកពីសហរដ្ឋអាមេរិក ហើយលោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកសិល្បៈពីសាកលវិទ្យាល័យ NORTH CAROLINA និងថ្នាក់អនុបណ្ឌិត (MASTER'S DEGREE IN INTERNATIONAL AFFAIRS) ផ្នែកកិច្ចការអន្តរជាតិ ពីសាកលវិទ្យាល័យកូឡុំប៊ី។ លោកក៏ទទួលបាន សញ្ញាប័ត្រ CPA (CERTIFIED PUBLIC ACCOUNTANT) នៅក្នុងរដ្ឋវ៉ាស៊ីនតោនផងដែរ។ ក្រៅពីភាសាអង់គ្លេស លោកក៏អាចនិយាយភាសាបារាំង និងរុស្ស៊ីបានផងដែរ ។



## លោកស្រី តុប សុក្រសម្ភារ

### អគ្គនាយិការប្រតិបត្តិការ

លោកស្រីបានបម្រើការងារក្នុងមុខនាទីបច្ចុប្បន្ន តាំងពីឆ្នាំ2008 បន្ទាប់ពីបានបម្រើការ ជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុចាប់ពីឆ្នាំ2002។ មុនចូលបម្រើការងារនៅ វីសិនហ្វាន់ លោកស្រី មានមុខងារជាសវនករជាន់ខ្ពស់នៅ ក្រុមហ៊ុន Ernst & Young និង Price Water House Cooper។

លោកស្រី សម្ភារ មានកំណើតនៅទីក្រុងភ្នំពេញ និងមានបទពិសោធន៍ ជាង10ឆ្នាំលើផ្នែកគណនេយ្យហិរញ្ញវត្ថុ ការរៀបចំផែនការអាជីវកម្ម និងយុទ្ធសាស្ត្រសវនកម្ម កិច្ចការរដ្ឋបាល និងទំនាក់ទំនង។

លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៃប្រទេសកម្ពុជា។ លោកស្រីបានទទួលវិញ្ញាបនបត្រថ្នាក់ជំនាញបច្ចេកទេសជាន់ខ្ពស់ផ្នែកគណនេយ្យ និង រដ្ឋបាលពីមហាវិទ្យាល័យ Noisy Le Grand ប្រទេសបារាំង។



## លោក ផន សំផា

### ប្រធានពហុនាយកដ្ឋានយុទ្ធសាស្ត្រ និង អភិវឌ្ឍអង្គភាព

លោក សំផា បានចូលបម្រើការនៅ វីសិនហ្វាន់ខេមបូឌា ក្នុងតំណែងជាប្រធានពហុនាយកដ្ឋានយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍អង្គភាពនៅឆ្នាំ 2013។ គាត់មានបទពិសោធន៍ការងារដ៏ជោគជ័យជាង17 ឆ្នាំ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនានា និងស្ថាប័នពិគ្រោះយោបល់ អង្គការក្នុងតំបន់ អង្គការអន្តរជាតិ និងក្រុមហ៊ុនឯកជនក្នុងការគ្រប់គ្រងអភិបាល កិច្ចការដឹកនាំការគ្រប់គ្រងទូទៅការប្រឹក្សាយោបល់ ការគ្រប់គ្រងប្រតិបត្តិការ ផ្នែកធនធានមនុស្ស និងការកសាងសមត្ថភាព ការវាយតម្លៃ ការស្រាវជ្រាវ ការធ្វើផែនការ ( យុទ្ធសាស្ត្រ អាជីវកម្ម និងផែនការអនុវត្ត )ការគ្រប់គ្រងលើការពង្រឹងគុណភាព និងការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងគម្រោងរកជំនួយការគ្រប់គ្រងគម្រោង និងការអនុវត្តគម្រោងជាដើម។

លោក សំផា ធ្លាប់បានកាន់មុខតំណែងជានាយកផ្នែកស្រាវជ្រាវ និងពិគ្រោះយោបល់របស់អង្គការក្រៅរាជរដ្ឋាភិបាល SEDECA និងជាអ្នកសម្របសម្រួលកម្មវិធីប្រចាំតំបន់អាស៊ី អាគ្នេយ៍របស់អង្គការ OXFAM America អស់រយៈ ពេល 3 ឆ្នាំ។



## លោក ព្រាប ពិសិដ្ឋ

**ប្រធានប្រតិបត្តិការជាន់ខ្ពស់**

លោកពិសិដ្ឋ កើតនៅខេត្តកណ្តាល លោកមានបទពិសោធន៍ជាងមួយទសវត្សរ៍ ខាងវិស័យអភិវឌ្ឍន៍ផ្នែកសេវាកម្មអតិថិជន ការគ្រប់គ្រងទំនាក់ទំនងសាធារណៈ និងរដ្ឋបាលកិច្ច ។ លោកបានចូលបម្រើការងារឲ្យ វីសិនហ្វាន់ ខេមបូឌា នៅឆ្នាំ2008។ នៅក្នុងជីវិតការងាររបស់លោកមួយភាគធំគឺនៅអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) និងនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា ។

លោក ពិសិដ្ឋ ទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យន័រតុន និងបរិញ្ញាប័ត្រគ្រប់គ្រងសហគ្រាសពី សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

# តួលេខសំខាន់ៗ

| | ខែធ្នូ 2014 | ខែធ្នូ 2013 |
|---|---|---|
| ចំនួនអ្នកខ្ចីសកម្ម | 228,948 | 191,974 |
| ( % ) អ្នកខ្ចីជាស្ត្រី | 94% | 93% |
| ចំនួនខេត្តប្រតិបត្តិការ | 17 | 14 |
| ចំនួនស្រុកប្រតិបត្តិការ | 138 | 127 |
| បុគ្គលិកសរុប | 1191 | 967 |
| ផលប័ត្រឥណទាន | $90,901,505 | $61,602,551 |
| ផលប័ត្រឥណទានជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់ | $397 | $321 |
| ផលប័ត្រឥណទានជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ | $163,492 | $132,194 |
| ផលប័ត្រឥណទានមានហានិភ័យ > 30ថ្ងៃ | 0.25% | 0.26% |
| ចំនួនអតិថិជនបញ្ញើសន្សំ | 29,818 | 2,806 |
| សមតុល្យប្រាក់បញ្ញើសន្សំ | $14,734,633 | $4,806,878 |
| សរុបទ្រព្យសកម្ម | $105,882,626 | $73,065,145 |
| មូលនិធិម្ចាស់ហ៊ុនសរុប | $21,696,993 | $18,495,236 |
| និរន្តរភាពប្រតិបត្តិការ | 114% | 119% |
| និរន្តរភាពហិរញ្ញវត្ថុ | 107% | 111% |
| ចំណូលធៀបទ្រព្យសកម្ម | 2.90% | 4.05% |

## ចំណែកវិធីសាស្រ្តតាមរយៈ ចំនួនអតិថិជន




## ចំណែកវិធីសាស្រ្តតាមទំហំ ផលប័ត្រឥណទាន



# ស្ថាប័នដែលមានភាពលេចធ្លោក្នុងឆាកអន្តរជាតិ

“ វីសិនហ្វាន់ ខេមបូឌា គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុដ៏ឆ្នើមមួយក្នុងចំណោមស្ថាប័នមីក្រូហិរញ្ញវត្ថុ អន្តរជាតិជាច្រើន ” ប្រសាសន៍របស់លោក ស្កត់ ប្រោន ប្រធាននិងអគ្គនាយកប្រតិបត្តិ វីសិនហ្វាន់អន្តរជាតិ

ក្រោមការសហការជាមួយអង្គការទស្សនៈពិភពលោក វីសិនហ្វាន់ ខេមបូឌា ត្រូវបានទទួលស្គាល់ជាបន្តបន្ទាប់ថាជាស្ថាប័នមីក្រូហិរញ្ញវត្ថុកំពូលមួយ ក្នុងចំណោមស្ថាប័នមីក្រូហិរញ្ញវត្ថុ ដទៃទៀតរបស់ វីសិនហ្វាន់អន្តរជាតិ ដែលទទួលបានសមិទ្ធផលការងារល្អបំផុត។ វីសិនហ្វាន់ អន្តរជាតិមានបណ្តាញស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន 35 ប្រទេសទូទាំងពិភពលោក។

## ពានរង្វាន់ និងការទទួលស្គាល់

នៅឆ្នាំ2009 វីសិនហ្វាន់ ខេមបូឌា ជាស្ថាប័នទី 51 ក្នុងចំណោមស្ថាប័នមីក្រូហិរញ្ញវត្ថុកំពូលចំនួន 100 ទូទាំងពិភពលោក ដែលបានជាប់ជាចំណាត់ថ្នាក់ក្រោមការវាយតម្លៃរបស់ MIX Global Composite Ranking ដែលផ្តោតសំខាន់លើលក្ខខណ្ឌធំៗមួយចំនួន ដូចជាការពង្រីកតំបន់ប្រតិបត្តិការប្រសិទ្ធភាពការងារ និងតម្លាភាព។

នៅក្នុងឆ្នាំដដែលនោះដែរ វីសិនហ្វាន់ ក៏បានឈ្នះ **“ពានរង្វាន់ប្រាក់”** ទៅលើការរៀបចំរបាយការណ៍សមិទ្ធផលសង្គម ដែលបានរៀបចំឡើងដោយក្រុមការងារពិគ្រោះពីសមិទ្ធផលសង្គម (CGAP Social Performance Task Force) មូលនិធិម៉ៃឃើល និងស៊ូសានឌែល (Michael & Susan Dell Foundation) និងមូលនិធិក្រុមហ៊ុនហ្វត (Ford Foundation) ជាមួយនឹងព័ត៌មានហិរញ្ញវត្ថុដែលផ្តល់ជូនដោយ MIX។

នៅក្នុងឆ្នាំ2010 វីសិនហ្វាន់ ខេមបូឌា ទទួលបាន **“ពានរង្វាន់មាស”** ដែលផ្តល់ដោយ MIX លើការរៀបចំរបាយការណ៍សមិទ្ធផលសង្គមចំពោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាដែលបានរៀបចំរបាយការណ៍សមិទ្ធផលសង្គមរបស់ខ្លួន ដោយផ្តល់ទិន្នន័យអំពីការវាស់វែងកម្រិតនៃភាពក្រីក្រ និងការវាយតម្លៃលើសមិទ្ធផលសង្គមដោយមានការធ្វើសវនកម្មលើខ្នាតនៃរូបមន្តនៃការវាស់វែងភាពក្រីក្រ ដែលបានប្រើដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ រង្វាន់លើការរៀបចំរបាយការណ៍សមិទ្ធផលសង្គមនេះ បានទាក់ទាញស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនទូទាំងពិភពលោក បន្ទាប់ពីការចាប់ផ្តើមប្រតិបត្តិការដំបូងក្នុងឆ្នាំ2009 ។

នៅក្នុងឆ្នាំ 2011 វីសិនហ្វាន់ បានទទួលរង្វាន់កិត្តិយសមួយផ្សេងទៀតដែលជាទីមោទនភាពនោះគឺ **“រង្វាន់ប្លាទីន”** ដែលជារង្វាន់លំដាប់កំពូលថ្មីមួយដែលទើបតែបង្កើតឡើងដោយ MIX ក្នុងឆ្នាំ 2011 ដោយទទួលស្គាល់លើតម្លាភាពនិងការប្តេជ្ញាខ្ពស់របស់ វីសិនហ្វាន់ ក្នុងការសម្រេចនូវបេសកកម្មសង្គម។

នៅក្នុងឆ្នាំ 2012 វីសិនហ្វាន់ ទទួលបាននូវរង្វាន់កំពូលមួយទៀតគឺ រង្វាន់ FIVE DIAMONDS ម្តងទៀតពី MIX លើការទទួលស្គាល់នូវឧត្តមភាពក្នុងការបង្ហាញនូវព័ត៌មានរបស់ខ្លួន ។

នៅក្នុងឆ្នាំ 2012 វីសិនហ្វាន់ ទទួលបាននូវរង្វាន់កំពូលមួយទៀតគឺ រង្វាន់ FIVE DIAMONDS ម្តងទៀតពី MIX លើការទទួលស្គាល់នូវឧត្តមភាពក្នុងការបង្ហាញនូវព័ត៌មានរបស់ខ្លួន។

នៅក្នុងឆ្នាំ 2013 វីសិនហ្វាន់ខេមបូឌា បានទទួលរង្វាន់ជាបន្តបន្ទាប់ពីស្ថាប័នវាយតម្លៃ និងស្ថាប័នឯករាជ្យផ្សេងៗ ទាំងថ្នាក់ជាតិ និងអន្តរជាតិដែលមានដូចជា:

- វីសិនហ្វាន់ ទទួលបាននូវការទទួលស្គាល់មួយទៀតពីស្ថាប័ន Oikocredit ដែលជាអ្នកវិនិយោគនាំមុខគេជាសាកលមួយ ដែលមានការិយាល័យកណ្តាលនៅប្រទេសហូឡង់ ជាមួយនិងការិយាល័យប្រចាំតំបន់នៅអាស៊ីអាគ្នេយ៍។ តាមរយៈការទទួលស្គាល់នេះ វីសិនហ្វាន់ បានទទួលនូវរង្វាន់ ២ក្នុងពេលតែមួយគឺលើសមិទ្ធផលការងារលើផ្នែកសង្គមឆ្នើម និងរង្វាន់សម្រាប់ការពង្រីកតំបន់ប្រតិបត្តិការ និងការជួយដល់អតិថិជនដែលជួបផលលំបាក ។

- វីសិនហ្វាន់ ក៏បានទទួលរង្វាន់តម្លាភាពនៃតម្លៃឆ្នាំ 2013 ពីស្ថាប័នមីក្រូហិរញ្ញវត្ថុអន្តរជាតិ MFTransparency លើតម្លាភាពនៃផលិតផល និងតម្លៃរួមជាមួយការផ្តល់ទិន្នន័យច្បាស់លាស់ត្រឹមត្រូវនិងមានភាពប្រកួតប្រជែង ហើយវីសិនហ្វាន់ ត្រូវបានចាត់ទុកថាជាស្ថាប័នដែលមានទំនួលខុសត្រូវខ្ពស់។

- ពានរង្វាន់ MIX S.T.A.R 2013 (តម្លាភាពសង្គម និង ទំនួលខុសត្រូវ) ដែលបានទទួលស្គាល់ លើការបំពេញនូវដំណើរការនៃការត្រួតពិនិត្យរបស់ MIX ដោយជោគជ័យ ហើយបានបំពេញនូវគ្រប់លក្ខណ្ឌទាំងអស់របស់រង្វាន់ S.T.A.R 2013 ។

## ការវាយតម្លៃរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ

ឆ្នាំ2013 វីសិនហ្វាន់ត្រូវបានផ្តល់ឲ្យនូវ Five Diamond Rating ដោយ MIX ទៅលើការបើកចំហរពត៌មាន និងការតាំងចិត្តក្នុងការងារល្អបំផុត ។

## ការវាយតម្លៃរបស់ស្ថាប័ន Planet Rating

នៅក្នុងខែកញ្ញា ឆ្នាំ 2014 វីសិនហ្វាន់ ខេមបូឌា ទទួលបានការវាយតម្លៃកម្រិត A- លើស្ថេរភាពស្ថាប័នពី Planet Rating ដែលមានការិយាល័យកណ្តាលស្ថិតនៅទីក្រុងប៉ារីស។ ការវាយតម្លៃនេះ ផ្តោតទៅលើភាពរឹងមាំរបស់ស្ថាប័ន ភាពយូរអង្វែងលើគុណភាពនៃប្រតិបត្តិការ និងការគ្រប់គ្រងរបស់ស្ថាប័ន។ Planet Rating គឺជាស្ថាប័នជំនាញវាយតម្លៃលើវិស័យមីក្រូហិរញ្ញវត្ថុ ដែលផ្តល់ជាសេវាវាយតម្លៃ ទៅដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុផ្សេងៗទៀត ។



# រចនាសម្ព័ន្ធ វីសិនហ្វាន់




វីសិនហ្វាន់អន្តរជាតិ ប្រចាំតំបន់អាស៊ីអាគ្នេយ៍
នាយកប្រចាំតំបន់អាស៊ី
នាយកគ្រប់គ្រងគម្រោង
នាយកហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី
នាយកសវនកម្មប្រចាំតំបន់អាស៊ី
គណៈកម្មការក្រុមប្រឹក្សាភិបាលសវនកម្ម
នាយកដ្ឋានសវនកម្មផ្ទៃក្នុង និង វាយតម្លៃ
អគ្គនាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងគម្រោង
នាយកដ្ឋានប្រព័ន្ធព័ត៌មានវិទ្យា
ផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាធនាគារ
ផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា
នាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងពង្រឹងគុណភាព
នាយកដ្ឋានរតនាគារ
ផ្នែករដ្ឋបាល
ពហុនាយកដ្ឋានយុទ្ធសាស្ត្រ និងអភិវឌ្ឍអង្គភាព
នាយកដ្ឋានធនធានមនុស្ស និងវប្បធម៌
ផ្នែកធនធានមនុស្ស និងវប្បធម៌
ផ្នែកអភិវឌ្ឍន៍សមត្ថភាព និង វប្បធម៌រៀនសូត្របុគ្គលិក

# ដោះស្រាយឧបសគ្គផ្នែកហិរញ្ញវត្ថុជាមួយវីសិនហ្វាន់

**វីសិនហ្វាន់ អបអរភាពជោគជ័យរបស់ខ្លួនតាមរយៈការចែករំលែកសាច់រឿងអតិថិជនទី20ម៉ឺន ដើម្បីបង្ហាញថាកម្ចីរបស់ខ្លួនផ្តល់ការផ្លាស់ប្រែជាវិជ្ជមាន សម្រាប់គ្រួសារជាច្រើន។**

ផល្លី បាននិយាយថា *«ពីមានកីតម្បាញសូត្រតែមួយរហូតដល់មានកីត្បាញសូត្រដល់ទៅបី ពីផ្ទះខ្ទមដែលទទេផ្លាស់ប្រែជាផ្ទះដ៏ធំមួយ ពីគ្រួសារដែលគ្មានសូម្បីតែក្តីសង្ឃឹទៅជាគ្រួសារ មួយដែលពោរពេញទៅដោយគោលដៅ និងសុភមង្គល។ នេះគឺជាសាច់រឿងរបស់យើង។ ខ្ញុំពិតជាថ្លែងអំណរគុណជាខ្លាំង ចំពោះអ្វីៗដែលខ្ញុំមានសព្វថ្ងៃនេះណាស់»*។

ផល្លី មានអាយុ 43ឆ្នាំជាម្តាយរបស់កូន 4 នាក់ ដែលរស់នៅក្នុងភូមិថ្មី ខេត្តតាកែវ ។ ផល្លីបានបន្តទៀតថា៖ *«ត្រលប់ទៅកាលពី 10 ឆ្នាំមុន ខ្ញុំនិងគ្រួសារមានជីវភាពលំបាកយ៉ាប់យឺនជាខ្លាំងក្នុងរយៈពេល10ថ្ងៃ ខ្ញុំអាចរកចំណូលបានតែ 10 ទៅ 20 ដុល្លារអាមេរិក ប៉ុណ្ណោះពីការត្បាញសូត្រ។ ខ្ញុំគ្មានប្រាក់គ្រប់គ្រាន់ទិញម្ហូបសម្រាប់គ្រួសារនិងទិញសម្ភារៈសិក្សាគ្រប់គ្រាន់សម្រាប់កូនខ្ញុំឡើយ»*។

ផល្លី និងប្តីរបស់គាត់ បានខំប្រឹងធ្វើការជាខ្លាំង ដើម្បីជំនះលើភាពលំបាករបស់ពួកគេ។ ផល្លី គឺជាអតិថិជនវ័យក្មេង និងមានភាពស្វាហាប់ម្នាក់របស់យើងហើយគាត់ព្យាយាមចូលរួមជាមួយសហគមន៍ និង ការបណ្តុះបណ្តាលផ្សេងៗ ដោយសារគាត់ចូលចិត្តរៀន និងចង់ដឹងពីចំណេះជំនាញបំនិនជីវិតឲ្យបានច្រើន។ គាត់បានស្គាល់អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) នៅដើមឆ្នាំ 2005។ គាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ រួមមានការអប់រំផ្នែកហិរញ្ញវត្ថុ កសិកម្ម សុខភាព និងអនាម័យ និងបច្ចេកទេសក្នុងការតម្បាញ ដែលជាមុខរបរដ៏ធំមួយរបស់គាត់នាបច្ចុប្បន្ននេះ។ ផល្លី បាននិយាយថា៖*«ក្រោយពីបានរៀននូវជំនាញបន្ថែម ខ្ញុំបានផ្លាស់ប្រែទៅជាមានទំនុកចិត្តច្រើនជាងមុន។ ខ្ញុំបានទទួលការបណ្តុះបណ្តាលក្នុងការបង្កើតមុខរបរថ្មីដើម្បីបង្កើនប្រាក់ចំណូលរបស់ខ្ញុំ។ យ៉ាងណាមិញបញ្ហានៅតែមានដោយសាយើងគ្មានប្រាក់គ្រប់គ្រាន់នឹងទិញម្ហូបអាហារផង កុំថាឡើយមានដើមទុនសម្រាប់បង្កើតមុខរបរថ្មី »*។

ដោយជួបឧបសគ្គផ្នែកហិរញ្ញវត្ថុ ផល្លី មិនអាចយកជំនាញដែលខ្លួនមានទៅអនុវត្តន៍នោះទេ ។ ក្រោយមកនៅឆ្នាំ 2005 វីសិនហ្វាន់ បានផ្តល់ជាដំណោះស្រាយផ្នែកហិរញ្ញវត្ថុដល់គាត់ ដោយបានផ្តល់កម្ចីខ្នាតតូច គឺត្រឹមតែ 20 ដុល្លារអាមេរិក ប៉ុណ្ណោះ។ គាត់បានយកទៅពង្រីកមុខរបរតម្បាញសូត្ររបស់គាត់ ដោយគាត់បានទិញនូវវត្ថុធាតុដើមខ្លះសម្រាប់ត្បាញ ។ គាត់ក៏នៅតែទទួលកម្ចីជាបន្តបន្ទាប់ពី វីសិនហ្វាន់ ដើម្បីពង្រីកមុខរបរសូត្ររបស់គាត់ ក៏ដូចជាទិញសម្ភារៈផ្សេងៗ ។ ផល្លីអាចរកប្រាក់ចំណូលបានច្រើនជាងមុន គឺ 90 ដុល្លារអាមេរិកក្នុងមួយសប្តាហ៍។

មុខរបរមានការរីកចម្រើន ដោយផ្លាស់ប្រែពីមានកីតម្បាញតែមួយរហូតដល់មានកីតម្បាញបី គាត់ក៏ត្រូវការជំនួយពីអ្នកជិតខាងផងដែរ។ ផល្លីបានផ្តល់ការងារដល់អ្នកជិតខាងនៅក្នុងភូមិ ដែលនេះរាប់បញ្ចូលជាចំណូលបន្ថែមដល់ពួកគេ ។ ផល្លី បាននិយាយថា *«នេះគឺជាការរីករាយក្នុងការធ្វើការជាមួយអ្នកជិតខាង ។ យើងក៏មានទំនាក់ទំនងជិតស្និទជាមួយគ្នាណាស់ ។ ខ្ញុំមានសេចក្តីត្រេកអរដែលអាចជួយឲ្យពួកគេមានការងារធ្វើ។»*

ផល្លី បានទទួលប្រាក់កម្ចីខ្នាតតូចដំបូងបង្អស់ពី វីសិនហ្វាន់ ចំនួនត្រឹមតែ 20 ដុល្លារអាមេរិក ឥឡូវគាត់ប្រើប្រាស់កម្ចីខ្នាតធំរហូតដល់ 4,000 ដុល្លារអាមេរិក។ កម្ចីវគ្គចុងក្រោយនេះគាត់បានយកទៅបង្កើត មុខរបរថ្មីមួយ ឲ្យកូនស្រីច្បងរបស់គាត់។ មុខរបរថ្មីនោះគឺ បង្កើតហាងកាត់ដេរតូចមួយ។ ផល្លីបានថ្លែងអំណរគុណដល់អង្គការទស្សនៈ-ពិភពលោកអន្តរជាតិ(កម្ពុជា) និង វីសិនហ្វាន់ ក្នុងការជួយបណ្តុះបណ្តាលគាត់ឲ្យមានជំនាញ និងទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ។

ផល្លី បាននិយាយថា *«ស្រីលីន គឺជាសិស្សពូកែម្នាក់នៅក្នុងថ្នាក់ ដែលមានគំនិតវិជ្ជមានមួយ ក្នុងការបន្តការសិក្សារឲ្យបានដល់ថ្នាក់ខ្ពស់»។ ស្រីលីន គឺជាកូនទីបីរបស់បងស្រីផល្លីបានបន្តថា៖ «ខ្ញុំចង់បន្តការសិក្សានៅមហាវិទ្យា-ល័យ ហើយខ្ញុំចង់ធ្វើការនៅក្នុងអង្គការ/ស្ថាប័នផ្សេងៗ។»*
*(តទៅទំព័រ33)*





“ ជាចុងក្រោយ ផល្លីបានបន្តថា៖«ខ្ញុំតែងតែលើកទឹកចិត្តកូនរបស់ខ្ញុំឲ្យទៅសាលារៀន ពួកគេកំពុងរៀននៅអនុវិទ្យាល័យថ្នាក់ទី 5 ទី8 និងទី 9។ ខ្ញុំ និងប្ដីរបស់ខ្ញុំ នឹងខិតខំប្រឹងធ្វើយ៉ាងណាឲ្យកូនៗរបស់ខ្ញុំអាចបន្តការសិក្សានៅមហាវិទ្យាល័យឲ្យបាន»។

ផល្លីបានបន្តទៀតថា៖«កូនស្រីច្បងរបស់ខ្ញុំរៀនកាត់ដេរ។ ខ្ញុំនឹងបើកហាងកាត់ដេរឲ្យកូនស្រីច្បងរបស់ខ្ញុំនៅក្នុងផ្សារមួយហើយ កូនស្រីច្បងរបស់ខ្ញុំអាចយកសូត្រដែលខ្ញុំត្បាញទៅលក់ក្នុងហាងរបស់គាត់បាន»។ ”





# អំពីផលិតផល

## I. ប្រាក់កម្ចី

វីសិនហ្វាន់ ខេមបូឌា បាននឹងកំពុងបម្រើសេវាជូនអតិថិជនចំនួន 228,948 គ្រួសារ ជាមួយនឹងទំហំកម្ចីសរុបចំនួន 90,901,505 លានដុល្លារអាមេរិក គិតត្រឹមខែ ធ្នូ ឆ្នាំ 2014។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អតិថិជន នឹងការប្រកួតប្រជែងក្នុងទីផ្សារហិរញ្ញវត្ថុបច្ចុប្បន្ន កម្ចីជាច្រើនប្រភេទត្រូវបានបង្កើតឡើងដូចខាងក្រោម៖

### I.) កម្ចីអាជីវកម្មខ្នាតតូច

កម្ចីអាជីវកម្មខ្នាតតូច ជាប្រភេទកម្ចី ដែលផ្តល់ជូនអតិថិជនសម្រាប់ប្រើប្រាស់ដូចជា៖ ដើមទុនក្នុងការប្រកបរបរឬអាជីវកម្ម ដែលអាចរកចំណូលបានជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ។ មុខរបរ ឬអាជីវកម្មខ្នាតតូចទាំងនោះមានដូចជា អាជីវកម្មលក់គ្រឿងទេស អាជីវកម្មលក់គុយទាវ អាជីវកម្មលក់កាហ្វេ អាជីវកម្មលក់ផលិតផល/សម្ភារៈកសិកម្ម និងលក់ចំណីអាហារជាដើម។

ទំហំកម្ចីៈ 80,000 រៀល ដល់ទៅ 8,000,000 រៀល
151 ដុល្លារអាមេរិក ដល់ទៅ 15,000 ដុល្លអាមេរិក
800 បាត ដល់ទៅ 100,000 បាត

រយៈពេលៈ 3 ខែ ដល់ 42 ខែ

### 2.) កម្ចីលើវិស័យកសិកម្ម

កម្ចីលើវិស័យកសិកម្ម ជាប្រភេទកម្ចី សម្រាប់ប្រើប្រាស់លើដំណើរការកសិកម្ម ឬសម្រាប់ប្រកបរបរកសិកម្ម ដែលអាចទទួលប្រាក់ចំណូលទៅតាមរដូវកាលដូចជាធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វជាដើម។

ទំហំកម្ចីៈ 80,000 រៀល ដល់ទៅ 8,000,000 រៀល
151 ដុល្លារអាមេរិក ដល់ 15,000 ដុល្លារអាមេរិក
8,00 បាត ដល់ទៅ 100,000 បាត

រយៈពេលៈ 3 ខែ ដល់ 42 ខែ

### 3). កម្ចីមិនមែនអាជីវកម្ម

កម្ចីមិនមែនអាជីវកម្ម ជាប្រភេទកម្ចីដែលយកទៅប្រើប្រាស់សម្រាប់ការទិញសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនឬក្នុងគ្រួសារ ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការក្នុងគ្រួសារនិងផ្តល់ផលប៉ះពាល់ដល់សុមាលភាពរបស់កុមារដូចជា ការទិញធុងចម្រោះទឹក សាងសង់បង្គន់អនាម័យ និងទិញឧបករណ៍ដើរដោយពន្លឺព្រះអាទិត្យជាដើម។

ទំហំកម្ចីៈ 80,000រៀល ដល់ 8,000,000រៀល
151 ដុល្លារអាមេរិក ដល់ 3,000 ដុល្លារអាមេរិក
8,00 បាត ដល់ 100,000 បាត

រយៈពេលៈ 3 ខែ ដល់ 30 ខែ

### 4). កម្ចីសម្រាប់ការសិក្សា

កម្ចីសម្រាប់ការសិក្សា ជាកម្ចីសង្គមមួយប្រភេទរបស់វីសិនហ្វាន់ ដែលជាជំនួយផ្នែកហិរញ្ញវត្ថុដល់សិស្ស/និស្សិត ដែលមកពីគ្រួសារក្រីក្រ មានប្រវត្តិការសិក្សាល្អ មានការប្តេជ្ញាចិត្តខ្ពស់ និងឆន្ទៈក្នុងការបន្តការសិក្សាកម្រិតជាន់ខ្ពស់ ឬ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ជាមួយការផ្តល់ជូននូវអត្រាការប្រាក់ដ៏សមរម្យ។

ទំហំកម្ចីៈ 100 ដុល្លារអាមេរិក ដល់ 3,000 ដុល្លារអាមេរិក

រយៈពេលៈ
កម្រិតបរិញ្ញាបត្ររង៖ 4 ដល់ 48 ខែ (រយៈពេល 4 ឆ្នាំ)
កម្រិតបរិញ្ញាបត្រ៖ 3 ដល់ 84 ខែ (រយៈពេល ៧ឆ្នាំ)
កម្រិតអនុបណ្ឌិត៖ 3 ដល់ 48 ខែ (រយៈពេល 4ឆ្នាំ)
វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ៖ 3 ដល់ 24 ខែ (រយៈពេល2ឆ្នាំ)

## 5). កម្ចីគ្រាអាសន្ន

កម្ចីគ្រាអាសន្ន គឺជាប្រភេទកម្ចីបង្កើតឡើងដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជននៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ដែលអាចនឹងត្រូវទទួលរងផលប៉ះពាល់ដោយសារហេតុការបន្ទាន់ និងព្រឹត្តិការណ៍ដែលមិនអាចគិតទុកជាមុនទាំងគ្រោះធម្មជាតិ និងគ្រោះថ្នាក់ផ្ទាល់ខ្លួន ។

ទំហំកម្ចី: 80,000 រៀល ដល់ 1,400,000 រៀល
20 ដុល្លារអាមេរិក ដល់ 350ដុល្លារអាមេរិក
800 បាត ដល់ 14,000 បាត

រយៈពេល: 3 ដល់ 6 ខែ

## ៦). កម្ចីអភិវឌ្ឍន៍សហគមន៍

កម្ចីអភិវឌ្ឍន៍សហគមន៍ ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ពង្រឹងសមត្ថភាពរបស់សហគមន៍អភិវឌ្ឍន៍ លើវិស័យកសិកម្ម ឬសហគមន៍កសិកម្មដែលស្រដៀងគ្នា ជាពិសេសគឺសហគមន៍ណាដែលស្ថិតនៅក្រោមការគាំទ្រ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) ដោយផ្តល់ជាប្រភពមូលនិធិ ដើម្បីជួយបំពេញនូវតម្រូវការបង្វិលទុន និងគម្រោងពង្រីកអាជីវកម្ម។

ទំហំកម្ចី: 5,000 ដុល្លារអាមេរិក ដល់ 25,000ដុល្លារអាមេរិក

រយៈពេល: 6ខែ ដល់ 36ខែ

## 7). កម្ចីសហគ្រាសធុនតូច និងមធ្យម

កម្ចីសម្រាប់សហគ្រាសធុនតូច និងមធ្យមបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អតិថិជន ដែលប្រកបរបរ ឬធ្វើជំនួញជាលក្ខណៈ សហគ្រាសធុនតូច និងមធ្យម ហើយមានបំណងពង្រីកអាជីវកម្មបន្ថែម ។ កម្ចីប្រភេទនេះ អាចប្រើប្រាស់សម្រាប់ជាដើមទុន និងទ្រព្យសកម្មបន្ថែមសម្រាប់មុខរបរដូចជា ទិញយានជំនិះសម្រាប់ដឹកទំនិញ ឬម៉ាស៊ីនក្នុងដំណើរការផលិតកម្មជាដើម។

ទំហំកម្ចី: 10,001 ដុល្លារអាមេរិក ដល់ 50,000 ដុល្លារអាមេរិក

រយៈពេល: 3ខែ ដល់ 36ខែ



## II. ប្រាក់សន្សំ

បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណប្រមូលប្រាក់សន្សំ Microfinance Deposit Taking Institution (MDI) ពីធនាគារជាតិនៃកម្ពុជា កាលពីឆ្នាំ 2011 វីសិនហ្វាន់ បានទទួលទំនុកចិត្តពីសាធារណៈជនជាតិ និងអន្តរជាតិ កាន់តែច្រើនឡើងជាលំដាប់លើសេវាកម្មរបស់ខ្លួន។

ត្រឹមបំណាច់ខែធ្នូ ឆ្នាំ 2014 វីសិនហ្វាន់ មានអតិថិជនប្រមាណជិតបីម៉ឺននាក់ កំពុងប្រើប្រាស់សេវាប្រាក់សន្សំ ដែលគិតជាទឹកប្រាក់មានចំនួនប្រមាណជិត 15លាន ដុល្លារអាមេរិក។ សេវាប្រាក់បញ្ញើនេះត្រូវបានបង្កើតឡើង ក្នុងគោលបំណងបម្រើដល់អ្នកដែលមានប្រាក់ចំណូលខ្ពស់ហើយមានសណ្តានចិត្តបម្រើដល់សហគមន៍តាមរយៈ វីសិនហ្វាន់ ខេមបូឌា ក៏ដូចជាជួយដល់អតិថិជនក្រីក្រ ដែលត្រូវការប្រាក់កម្ចីដើម្បីកែប្រែជីវភាពឲ្យបានប្រសើរជាងមុន ឬ ក្នុងគ្រាមានអាសន្ន ព្រមទាំងហេតុការណ៍ជាយថាហេតុណាមួយ។

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន វីសិនហ្វាន់ បានបង្កើតផលិតផលសេវាប្រាក់បញ្ញើសន្សំជាច្រើនប្រភេទដូចជា៖

### 1.) គណនីបញ្ញើអភិវឌ្ឍន៍សង្គម

គណនីបញ្ញើអភិវឌ្ឍន៍សង្គម គឺជាគណនីបញ្ញើ សម្រាប់លោកអ្នកដែលមានសណ្តានចិត្តជួយដល់សហគមន៍ពិសេសគឺកុមារ។ លោកអ្នកអាចសម្រេចគោលដៅសង្គម ព្រមទាំងគោលដៅហិរញ្ញវត្ថុក្នុងពេលតែមួយតាមរយៈការដាក់ប្រាក់បញ្ញើជាមួយយើង។ ប្រាក់បញ្ញើរបស់លោកអ្នក នឹងដាក់ឲ្យខ្ចីបន្តដើម្បីឲ្យពួកគាត់ពង្រីក និងបង្កើតមុខរបរ។ វីសិនហ្វាន់ នឹងគ្រប់គ្រងប្រាក់របស់លោកអ្នកប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

### 2.) គណនីសង្ឃឹម

គណនីសង្ឃឹម គឺជាគណនីសន្សំដែលអាចជួយលោកអ្នកក្នុងការចាត់ចែងប្រាក់របស់លោកអ្នកប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព។ បើកគណនីសង្ឃឹមជាមួយ វីសិនហ្វាន់ ឥឡូវនេះលោកអ្នកនឹងសម្រេចបានផែនការអនាគតរបស់អ្នក ដោយការកាត់បន្ថយហានិភ័យ និងកាត់បន្ថយចំណាយមិនចាំបាច់ ក៏ដូចជាបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសាច់ប្រាក់។ លើសពីនេះ លោកអ្នកនឹងបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

### 3). គណនីកូនល្អ

គណនីកូនល្អ គឺជាគណនីដែលបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការរបស់ឪពុកម្តាយ ឬសាច់ញាតិដែលមានបំណងសន្សំប្រាក់សម្រាប់កូនៗរបស់ពួកគេ ដើម្បីសម្រេចគោលបំណងឬក្តីស្រម៉ៃរបស់កូនៗពួកគេនាពេលអនាគតដូចជា ការទទួលបានការអប់រំកម្រិតខ្ពស់ ឬការបង្កើតមុខជំនួញផ្សេងៗ។

## III. សេវាផ្ទេរប្រាក់ក្នុងស្រុក

សេវាផ្ទេរប្រាក់ក្នុងប្រទេសរបស់ វីសិនហ្វាន់ ផ្តល់សុវត្ថិភាព និងសេវាងាយស្រួលដល់លោអ្នកក្នុងតម្លៃសមរម្យនៅក្នុងប្រទេសកម្ពុជា។ លោកអ្នកចំណាយពេលវេលាតិច និងតម្លៃសេវាទាបក្នុងការផ្ទេរប្រាក់របស់លោកអ្នកជាមួយយើង។







“ ចាប់ផ្តើមសន្សំថ្ងៃនេះដើម្បីអនាគត
ភ្លឺស្វាងរបស់កូនជាទីស្រឡាញ់
របស់លោកអ្នក ”







**គឹម ធីតា**

អតិថិជន វីសិនហ្វាន់ ប្រកបមុខរបរធ្វើកញ្ជ្រែ
នៅក្នុងខេត្ត សៀមរាប

# កិច្ចសហប្រតិបត្តិការជាដៃគូ

ដោយជឿជាក់ថា សេវាហិរញ្ញវត្ថុ មិនមែនជាសេវាកម្មតែមួយគត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនោះ វីសិនហ្វាន់ ខេមបូឌា បានបង្កើនភាពជាដៃគូរបស់ខ្លួន ដោយធ្វើកិច្ចសហការជាមួយ អង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាល និងស្ថាប័នមួយចំនួនដែលមានគោលដៅដូចគ្នា ក្នុងការលើកកម្ពស់ភាពខ្លាំងរបស់ស្ថាប័នក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុ រួមជាមួយនឹងដៃគូដែលបម្រើលើសេវាកម្មមិនមែនហិរញ្ញវត្ថុនានា។ ការពង្រឹងភាពជាដៃគូ បានចូលរួមចំណែកដល់ការពង្រីកសេវាកម្ម និងការងារក្នុងសង្គមបានទូលាយជាងមុន និងបានជម្រុញឲ្យ វីសិនហ្វាន់ ក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែមួយគត់ ដែលមានភាពប្រកួតប្រជែងខ្ពស់ និងមានយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ ។

World Vision

អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) គឺជាអង្គការអភិវឌ្ឍន៍ និងគ្រិស្តបរិស័ទអន្តរជាតិធ្វើការដើម្បីលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសគឺកុមារ។ អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) ធ្វើការបម្រើជនក្រីក្រនៅទូទាំងពិភពលោក ដោយមិនប្រកាន់ពូជសាសន៍ សាសនា ឬ ជនជាតិ។ វីសិនហ្វាន់ ខេមបូឌា បានធ្វើការក្នុងភាពជាដៃគូយុទ្ធសាស្ត្រយ៉ាងជិតស្និទ្ធជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា)ចាប់តាំងពីឆ្នាំ1990។ វីសិនហ្វាន់ ខេមបូឌា ធ្វើការផ្តល់សេវាហិរញ្ញវត្ថុ ចំណែកឯកម្មវិធីអភិវឌ្ឍន៍តាមតំបន់របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា)ធ្វើការគ្រប់គ្រងទៅលើកម្មវិធីសុវត្ថិភាព និងគម្រោងនានាដូចជា សន្តិសុខស្បៀង និងទឹកស្អាត ការអប់រំសុខភាព សន្តិភាព និងយុត្តិធម៌ និងជម្ងឺអេដស៍។

គិតត្រឹមខែធ្នូឆ្នាំ2014 យើងបានផ្តល់ប្រាក់កម្ចីដល់អតិថិជនចំនួន32,640នាក់ ដែលជាអ្នកទទួលផលរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) និងដែលកំពុងប្រើប្រាស់ប្រាក់កម្ចីសម្រាប់ប្រកបរបររកប្រាក់ចំណូលជាច្រើនប្រភេទដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវិតរបស់កុមារ និងក្រុមគ្រួសារ មិនត្រឹមតែប៉ុណ្ណោះពួកគេកំពុងដាក់ប្រាក់សន្សំជាមួយ វីសិនហ្វាន់ ខេមបូឌា ដើម្បី សុវត្ថិភាពសាច់ប្រាក់ និងជាផ្នែកមួយនៃការសន្សំរបស់ពួកគេ។ ក្នុងចំនោមនោះ មានសហករណ៍កសិកម្មចំនួន24 ដែលមានសមាជិកសរុប ចំនួន 3,535នាក់ ក្នុងខេត្តចំនួន7 ដែលបានយកប្រាក់កម្ចីរបស់ វីសិនហ្វាន់ ទៅចាប់ផ្តើម និងពង្រីកមុខជំនួញរបស់ពួកគេ ក្នុងការទិញជីសម្រាប់ការដាំដុះស្រូវ ទិញប្រេងនិងសាងសង់ហាងលក់ទំនិញជាដើម។

Plan
Be a part of it.

អង្គការភ្លែន ជាអង្គការអភិវឌ្ឍន៍ក្រៅរដ្ឋាភិបាលផ្តោតលើកុមារ ដែលលើកកម្ពស់សិទ្ធិកុមារដើម្បីបំបាត់ភាពក្រីក្រ។ ភាពជាដៃគូរវាង វីសិនហ្វាន់ ខេមបូឌា និងអង្គការភ្លែនកម្ពុជា បានចាប់ផ្តើមក្នុងឆ្នាំ 2007ក្នុងខេត្តកំពង់ចាម និងបានពង្រីកទៅខេត្តសៀមរាបបន្ថែមទៀត។ ភាពជាដៃគូ បានផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រមធ្យម និងក្រីក្របំផុត ជាពិសេស ស្ត្រីដែលស្ថិតនៅក្នុងតំបន់គោលដៅរបស់ អង្គការភ្លែនដែលអាចប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុរបស់ វីសិនហ្វាន់ ខេមបូឌា ដើម្បីបង្កើត និង / ឬ ពង្រីកមុខរបររបស់ពួកគាត់ និង / ឬ បង្កើនផលិតកម្មកសិកម្ម ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគាត់។ អតិថិជនប្រភេទនេះ បច្ចុប្បន្នមានចំនួន 7,173 នាក់ ជាមួយផលប័ត្រឥណទានសរុបចំនួន 2,856,371 ដុល្លារអាមេរិក ដែលទំហំប្រាក់កម្ចីសម្រាប់អតិថិជនជាង 7ពាន់នាក់ជាមធ្យមគឺ 398ដុល្លារអាមេរិក។ ទាំងនេះបញ្ជាក់ឲ្យឃើញថា វីសិនហ្វាន់ ខេមបូឌា នៅតែរក្សាការផ្តោតសំខាន់ទៅលើអតិថិជនគោលដៅដែលមានចំណូលទាប ឬជនក្រីក្រដែលរស់តាមជនបទ ។

## PATH

A catalyst for global health

អង្គការផាស (PATH) ផ្តល់កម្មវិធីសម្រាប់បច្ចេកវិទ្យាសុខភាពសមស្រប និងជាអង្គការអន្តរជាតិ មិនរកប្រាក់ចំណេញ ដែលធ្វើការផ្លាស់ប្តូរស្ថានភាពសុខភាពសហគមន៍ទូទាំងពិភពលោក តាមរយៈរបកគំហើញថ្មីៗ។ អង្គការ ផាសធ្វើការប្រើប្រាស់អភិក្រមសហគ្រិនភាពដើម្បីអភិវឌ្ឍ និងផ្តល់នូវដំណោះស្រាយជាមួយនឹងចំណាយតិច និងមានផលប៉ះពាល់ខ្ពស់ពីឧបករណ៍ និងវ៉ាក់សាំងសង្គ្រោះជីវិតដែលផ្តល់ដោយកម្មវិធីសហ-ប្រតិបត្តិការជាមួយសហគមន៍នានា។ អង្គការ PATH បានសហការជាមួយ HYDROLOGIC SOCIAL ENTERPRISE ចាប់ផ្តើមភាពជាដៃគូជាមួយ វីសិនហ្វាន់ តាំងពីដើមឆ្នាំ 2011 ដើម្បីសាកល្បងកម្មវិធីធុងចម្រោះនៅក្នុងសហគមន៍ ខេត្តកំពង់ស្ពឺ ដើម្បីលើកកម្ពស់អនាម័យទឹកស្អាត។ កម្មវិធីសាកល្បងបានបង្ហាញនូវភាពជោគជ័យជាខ្លាំង ហើយបានពង្រីកទូទាំងខេត្តកំពង់ស្ពឺ និង បណ្តាខេត្តមួយចំនួនទៀតរួមមានកណ្តាល តាកែវ និង កំពង់ចាម ក្នុងភាពជាដៃគូកាន់តែជិតស្និទ្ធជាមួយ នឹង វីសិនហ្វាន់ ។ បច្ចុប្បន្នយើងមាន អតិថិជនចំនួន 50,476 នាក់ ដែលបានប្រើប្រាស់កម្ចីទិញធុងចម្រោះទឹក ។

នៅដើមឆ្នាំ 2012យើងបានចាប់ផ្តើមសាកល្បងផលិតផលសង្គមថ្មីមួយទៀត ដែលមានឈ្មោះថា «កម្ចីហិរញ្ញវត្ថុលើផ្នែកអនាម័យ» នៅក្នុងខេត្តកណ្តាលក្នុងភាពជាដៃគូបីភាគីរវាង PATH IDE និងវីសិនហ្វាន់ ដើម្បីលើកទឹកចិត្តសហគមន៍ឲ្យយកចិត្តទុកដាក់លើបញ្ហាអនាម័យបឋមដោយប្រើប្រាស់បង្គន់អនាម័យ ។ ចាប់ពីឆ្នាំ 2014 យើងធ្វើការពង្រីកគម្រោងរបស់យើងជាមួយ IDE ។ បច្ចុប្បន្នយើងមាន អតិថិជនចំនួន 11,567នាក់ ជាមួយនិង ផលប័ត្រឥណទានសរុប 1,164,720ដុល្លារអាមេរិក។

## hydrologic

សហគ្រាសសង្គម Hydrologic

សហគ្រាសផលិតផលសង្គម ហាដ្រូឡូជិក (HYDROLOGIC): ចាប់ចេញពីជំនាញ និងចំនេះធ្វើដំយូររបស់សហគ្រាសអភិវឌ្ឍអន្តរជាតិ សហគ្រាសសង្គម ហាដ្រូឡូជិក បច្ចុប្បន្នគឺជានីតិបុគ្គលឯករាជ្យ និង ជាសហគ្រាសសង្គមដែលផ្តល់ទឹកស្អាតមានសុវត្ថិភាពដល់ប្រជាជនកម្ពុជាជាងកន្លះលាននាក់ តាមរយៈឧបករណ៍បន្សុទ្ធទឹកសេរ៉ាមិច សញ្ញារូបទន្សាយ។ ក្នុងគោលបំណង ដោះស្រាយបញ្ហាទឹកស្អាតនៅតំបន់ជនបទនៃប្រទេសកម្ពុជា សហគ្រិនអភិវឌ្ឍអន្តរជាតិ (INTERNATIONAL DEVELOPMENT ENTERPRISE) បាននាំយកឧបករណ៍បន្សុទ្ធទឹកសេរ៉ាមិចសញ្ញារូបទន្សាយ មកកម្ពុជានៅឆ្នាំ2001 ។

## iDE

IDE (សហគ្រាសអភិវឌ្ឍអន្តរជាតិ) ផ្តោតលើការអភិវឌ្ឍប្រព័ន្ធទីផ្សារ ដើម្បីបំពេញតម្រូវការជនក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ រយៈពេលជាង 8ឆ្នាំ នៅប្រទេសកម្ពុជា វៀតណាម ទីម័រ ឡាវ ហើយបច្ចុប្បន្ន នៅប្រទេសនេប៉ាល់ និង បង់ក្លាដេស សហគ្រាសអភិវឌ្ឍអន្តរជាតិ IDE ជាអ្នកត្រួសត្រាយក្នុងការអនុវត្តអភិក្រមផ្តោតទីផ្សារដើម្បីលើកកម្ពស់ទឹកស្អាត អនាម័យ និងការលាងដៃនៅ តាមជនបទ។ អភិក្រមរបស់ IDE ទាញយកអត្ថប្រយោជន៍ប្រៀបធៀបពីវិស័យសាធារណៈ រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់សេវាកម្មដល់គ្រួសារក្រីក្របានកាន់តែទូលំទូលាយក្នុងរយៈពេលខ្លី ។

ADRA
ADVENTIST DEVELOPMENT AND RELIEF AGENCY CAMBODIA

អង្គការ ADVENTIST DEVELOPMENT & RELIEF AGENCY (ADRA) ផ្តោតជាចំបងលើគម្រោងអភិវឌ្ឍរយៈពេលវែងប្រកបដោយនិរន្តភាពជាមួយនឹងប្រជាជនក្រីក្រ និងប្រជាជនដែលជួបហានិភ័យ។ អង្គការ ADRA ជួយប្រជាជនក្រីក្រទាំងឡាយដោយពុំគិតពីជំនឿសាសនា និន្នាការនយោបាយ ឬជាតិសាសន៍ឡើយ។ យើងបានធ្វើការជាមួយនិងអង្គការADRA ចាប់តាំងពីដើមឆ្នាំ2010ក្នុងខេត្តពោធិសាត់។ ភាពជាដៃគូនេះបានយកជំនាញរបស់វីសិនហ្វាន់ក្នុងការផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុនៅតំបន់គោលដៅក្នុងស្រុកភ្នំក្រវាញ។ អ្នកទទួលផលរបស់អង្គការបានទទួលប្រាក់កម្ចីពីវីសិនហ្វាន់ ខេមបូឌា ជាចំបងសម្រាប់ការធ្វើស្រែចំការ និង/ឬ បង្កើតឬពង្រីកអាជីវកម្មខ្នាតតូចរបស់ពួកគេ។ បច្ចុប្បន្នយើងមានអតិថិជនចំនួន640នាក់ជាមួយនិងផលប័ត្រឥណទានសរុប 282,425 ដុល្លារអាមេរិក ។

Habitat for Humanity® Cambodia

ក្នុងឆ្នាំ 2013 យើងបានចាប់ផ្តើមសហការជាដៃគូជាមួយ HABITAT FOR HUMANITY CAMBODIA (HFHC), គឺជាអង្គការដែលមិនរកប្រាក់ចំណេញក្នុងការផ្តល់ដំណោះស្រាយលើលំនៅស្ថាន ដែលបានបំរើការគ្រួសារតាមរយៈការផ្តល់លំនៅស្ថាន ការអភិវឌ្ឍសហគមន៍ និងទឹកស្អាត បង្គន់អនាម័យ និង អនាម័យនៅក្នុងប្រទេសកម្ពុជា។ ការចាប់ដៃគូនេះគឺ ផ្តល់ប្រាក់កម្ចីសម្រាប់ការសាងសង់បង្គន់អនាម័យ (SANITATION FINANCING) នៅក្នុងស្រុកចំនួនពីរ គឺស្រុកពួក និង ស្រុកអង្គរជុំ ខេត្តសៀមរាប។ HABITAT ជួយឧបត្ថម្ភ 5 ដុល្លារអាមេរិក/10 ដុល្លារអាមេរិក សម្រាប់អតិថិជនម្នាក់ ដើម្បីលើកទឹកចិត្តឲ្យពួកគេទិញ និងប្រើប្រាស់បង្គន់អនាម័យ។ បច្ចុប្បន្ននេះ យើងមានអតិថិជនចំនួន 751 នាក់ ជាមួយផលប័ត្រឥណទានសរុបចំនួន 176,997 ដុល្លារអាមេរិក ។

Water SHED
Water, Sanitation & Hygiene Enterprise Development

WATERSHED កម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលសម្របសម្រួលឲ្យទទួលបានផលិតផលអនាម័យ និង ទឹកស្អាត ដែលបង្កើនការទទួលយក និងការប្រើប្រាស់ត្រឹមត្រូវក្នុងចំណោមជនក្រីក្រដែលរស់នៅតាមជនបទ។ ដោយអនុវត្តគោលការណ៍ មូលដ្ឋានទីផ្សារដែលត្រូវបានបញ្ជាក់ពិតប្រាកដពី WATERSHED ក្នុងការលើកកម្ពស់អំណាចសហគ្រាសឯកជនក្នុងការនាំមកនូវ ទឹកស្អាត សុខភាព និង ភាពចម្រុងចម្រើនដល់ប្ញាជននៅអាស៊ីអាគ្នេយ៍។WATERSHED ចាប់ផ្តើមភាពជាដៃគូជាមួយវីសិនហ្វាន់ នៅពាក់កណ្តាល ឆ្នាំ 2012 ក្នុងការផ្តល់ប្រាក់កម្ចីលើកកម្ពស់អនាម័យដែលជំរុញឲ្យប្រជាជនក្រីក្រតាមជនបទអាចមានលទ្ធភាពទិញបង្គន់។ បច្ចុប្បន្នយើងមានអតិថិជនចំនួន 9,838 នាក់ ជាមួយនិងផលប័ត្រឥណទានសរុប 655,310 ដុល្លារអាមេរិក។

KAMWORKS
Sustainable Solar Solutions

នៅចុងឆ្នាំ 2013 វីសិនហ្វាន់ ខេមបូឌា បានចាប់ផ្តើមសហការជាដៃគូ ជាមួយ KAMWORKS ដែលជាក្រុម-ហ៊ុនឈានមុខគេមួយនៅក្នុងប្រទេសកម្ពុជា ខាងផលិតផលបន្ទះសូឡា ហើយបានចាប់ផ្តើមជាសហគ្រាសសង្គមមួយក្នុងឆ្នាំ 2006 ដើម្បីផ្តល់ជូននូវផលិតផលបន្ទះសូឡាដល់ប្រជាជនដែលរស់នៅក្នុងខេត្តក្រចេះ ហើយក្រោយមកផ្តល់ជូនដល់ប្រជាជននៅខេត្តកំពង់ឆ្នាំង តាមរយៈការផ្តល់ហិរញ្ញប្បទាន។ បច្ចុប្បន្នយើងមានអតិថិជនទាំងអស់ចំនួន 158 នាក់ (ផលប័ត្រឥណទាន 57,884 ដុល្លាអាមេរិក)។ ទោះបីជាយ៉ាងណាក៏ដោយ ជាមួយក្រុមហ៊ុនសហការជាមួយយើងទាំងអស់មានអតិថិជនសរុប 567 នាក់ ដែលកំពុងទិញបន្ទះសូឡា ជាមួយនឹងផលប័ត្រឥណទាន ចំនួន 167,861 ដុល្លាអាមេរិក ។

យើងបានដាក់ គម្រោងធានារ៉ាប់រងសុខភាពខ្នាតតូចសម្រាប់អតិថិជនរបស់យើង លើសុខភាព និងពិការភាពជាមួយ PKMI ឲ្យប្រើប្រាស់សាកល្បង ដោយមានការគាំទ្រពីអង្គការ UNDP នៅចុងឆ្នាំ 2012 រហូតដល់ចុងឆ្នាំ 2013 ។ អតិថិជនបង់ប្រាក់ត្រឹមប្រហែល 5ដុល្លារអាមេរិកប៉ុណ្ណោះក្នុងមួយឆ្នាំ ដើម្បីទទួលបានសេវាធានារ៉ាប់រងខ្នាតតូចដែលគ្របដណ្តប់ លើការព្យាបាលជំងឺតូចតាច ការវះកាត់តូចតាច ការព្យាបាលជំងឺដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្សេងទៀតនិងសំណងសម្រាប់ពិការភាពបង្កដោយគ្រោះថ្នាក់ចរាចរណ៍។ ក្រោយពីទទួលបានការវាយតម្លៃលើផលប៉ះពាល់ គេបានរកឃើញថាគម្រោងនេះមានគុណប្រយោជន៍ និងរួមចំណែកជួយដល់ការរស់នៅរបស់អតិថិជន និងសហគមន៍របស់ពួកគេជាច្រើន។ វីសិនហ្វាន់ ខេមបូឌា នឹងពង្រីកគម្រោងនេះនៅក្នុងឆ្នាំ 2014 ទៅបណ្តាខេត្តផ្សេងៗជាច្រើនទៀត ក្នុងភាពជាដៃគូកាន់តែជិតស្និទ្ធជាមួយ KPMI ។ បច្ចុប្បន្នយើងមានអតិថិជនចំនួន 6,564នាក់ ។

KIVA គឺជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ ដែលមានបេសកកម្មផ្សារភ្ជាប់ទៅនឹងមនុស្សគ្រប់រូប តាមរយៈការផ្តល់ប្រាក់កម្ចី ដើម្បីជួយកាត់បន្ថយភាពក្រីក្រដោយគ្របដណ្តប់លើប្រព័ន្ធអ៊ិនធឺណេត និងមានបណ្តាញគ្រឹះស្ថាន-មីក្រូហិរញ្ញវត្ថុទូទាំងពិភពលោក។ KIVA អនុញ្ញាតិឲ្យបុគ្គលម្នាក់ៗផ្តល់ប្រាក់កម្ចីទាបបំផុតត្រឹម 25 ដុល្លារអាមេរិក ដើម្បីជួយបង្កើតឱកាសដល់ប្រជាជនក្រីក្រជុំវិញពិភពលោក។ វីសិនហ្វាន់ ខេមបូឌា បានក្លាយជាដៃគូរបស់ KIVA នៅខែ កញ្ញា ឆ្នាំ2011 ដោយឋិតនៅក្នុងដំណាក់កាលសាកល្បង នៅក្នុងខេត្តចំនួន2ហើយបន្ទាប់មក ត្រូវបានតំឡើងទៅជាដំណាក់កាលពេញលេញមួយនៅក្នុងខែមេសា ឆ្នាំ 2012។ ជាមួយ និងបេសកកម្មដ៏រឹងមាំ និងស្នាដៃគួរឲ្យកត់សម្គាល់របស់ខ្លួន វីសិនហ្វាន់ ខេមបូឌា បានទទួលមេដាយខាងផ្នែកសមិទ្ធផលសង្គមចំនួន 5 ក្នុងចំណោមមេដាយសរុបចំនួន 7 ដែលនោះមានដូចជា ការផ្តោតទៅលើការប្រយុទ្ធប្រឆាំងភាពក្រីក្រ សម្លេងរបស់អតិថិជន ការផ្តល់អំណាចដល់គ្រួសារ និងសហគមន៍ ការសម្របសម្រួលក្នុងបញ្ញើប្រាក់សន្សំ និងការច្នៃប្រឌិត។ បច្ចុប្បន្ននេះ វីសិនហ្វាន់ ខេមបូឌា បានពង្រីកភាពជាដៃគូ ទៅដល់ 12 ខេត្ត ដើម្បីបង្កើនផលប៉ះពាល់ និងសមិទ្ធផលសង្គម ។ គិតត្រឹមខែធ្នូ2014 វីសិនហ្វាន់ បានក្លាយជាដៃគូរបស់ KIVA រយៈពេលជាង បីឆ្នាំកន្លះហើយ បានប្រមូលមូលនិធិសរុបប្រហែល 6.77 លានដុល្លារអាមេរិក នៅលើបណ្តាញផ្សព្វផ្សាយរបស់ KIVA។

គម្រោងប្រមូលមូលនិធិ តាមរយៈប្រព័ន្ធអេឡិចត្រូនិចដែលមានឈ្មោះថា WORLD VISION MICRO ធ្វើការភ្ជាប់ទំនាក់ទំនងរវាងម្ចាស់ជំនួយទាំងអស់នៅទូទាំងពិភពលោក ជាមួយនឹងសហគមន៍ តាមរយៈប្រាក់កម្ចីខ្នាតតូចរបស់ វីសិនហ្វាន់។ ស្របទៅនិងការប្រមូលមូលនិធិតាមរយៈគម្រោងនេះ ក្រៅពីការនាំមកនូវសេវាហិរញ្ញវត្ថុកាន់តែប្រសើរដល់អតិថិជន វាក៏ធ្វើឲ្យម្ចាស់ជំនួយទាំងអស់អាចយល់អំពីស្ថានភាពហិរញ្ញវត្ថុ និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាកាន់តែច្រើនផងដែរ តាមរយៈដំណើររឿងនានារបស់សហគ្រិនទាំងអស់ ដែលរួមបញ្ចូលទាំងផលប៉ះពាល់ជាវិជ្ជមាននៃប្រាក់កម្ចី ចំពោះសហគមន៍ជាពិសេសកុមារ។ វីសិនហ្វាន់ ខេមបូឌា បានដំណើរការគម្រោងនេះតាំងពីដើមឆ្នាំ 2011 ជាមួយ WORLD VISION MICRO មកដល់បច្ចុប្បន្ននៅក្នុងខេត្តចំនួន 9 ដែលមានកម្មវិធីអភិវឌ្ឍតាមតំបន់របស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា)។ វីសិនហ្វាន់ ខេមបូឌាបានចាប់ផ្តើមអនុវត្តទូរស័ព្ទ SAMSUNG GALAXY សម្រាប់មន្ត្រីបម្រើសេវាអតិថិជនដើម្បីបញ្ចូលការធ្វើបច្ចុប្បន្នកម្មសាច់រឿងពាក់កណ្តាលវគ្គ និងចុងបញ្ចប់វគ្គ។ គិតមកត្រឹមខែធ្នូ ឆ្នាំ 2014 ប្រាក់កម្ចីប្រហែលចំនួន 9សែន3ម៉ឺនដុល្លារអាមេរិកត្រូវបានប្រមូលតាមរយៈគម្រោង MICRO នេះ ។

ROTARY CLUB OF PURSAT (RCP) វីសិនហ្វាន់ ខេមបូឌា ទើបតែចាប់ផ្តើមសហការជាដៃគូជាមួយនឹង ROTARY CLUB OF PURSAT (RCP) ក្នុងពាក់កណ្តាលឆ្នាំ 2014 តាមរយៈ SUSTAINABLE CAMBODIA ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលមានចក្ខុវិស័យជួយប្រជាជនកម្ពុជា អាចរស់នៅដោយខ្លួនឯងបាន។ ចាប់ពីពេលនោះ យើងបានផ្តល់សេវាហិរញ្ញវត្ថុ ទៅគ្រួសារក្រីក្រដែលរស់នៅក្នុងភូមិតំបន់គោលដៅរបស់ SUSTAINABLE CAMBODIA ក្នុងខេត្តពោធិ៍សាត់។

សូឡាភូមិយើង គឺជាក្រុមហ៊ុនផ្តត់ផ្គង់ផលិតផលបន្ទះសូឡាមួយផ្សេងទៀតដែល វីសិនហ្វាន់ ខេមបូឌា បានសហការជាដៃគូក្នុងការផ្គត់ផ្គង់ផលិតផលបន្ទះសូឡាឲ្យអតិថិជន របស់ខ្លួននៅក្នុងខេត្តមួយចំនួនតាំងពីពាក់កណ្តាលឆ្នាំ 2014 មកម្លេះ។ វាគឺជាក្រុមហ៊ុនផ្គត់ផ្គង់បន្ទះសូឡាក្នុងស្រុកមួយដែលបានចុះបញ្ជីជាមួយនឹងអាជ្ញាធរក្នុងស្រុក និងបណ្តាញក្រសួងរដ្ឋាភិបាលនានា។ បច្ចុប្បន្ន យើងមានអតិថិជនចំនួន379 នាក់ដែលបានប្រើប្រាស់កម្ចី ដើម្បីទិញផលិតផលបន្ទះសូឡា សម្រាប់បំភ្លឺផ្ទះឬ សម្រាប់គោលបំណងអាជីវកម្ម។

AFD (AGENCY FOR FRENCH DEVELOPMENT): វីសិនហ្វាន់ ខេមបូឌា គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាដែលទទួលបានហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ក្នុងឆ្នាំនេះដើម្បីបង្កើនការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅក្រម្ពុជា។ គម្រោងថាមពលបន្ទះសូឡាជាមួយនឹង ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD)។ យ៉ាងណាក៏ដោយ កម្ចីសម្រាប់បន្ទះសូឡាគឺមិនមែនថ្មីសម្រាប់វីសិនហ្វាន់ ខេមបូឌាទេ។ យើងបានចាប់ផ្តើមធ្វើវាតាំងពីឆ្នាំ 2011ដោយចាប់ដៃគូជាមួយ និងសហគ្រាសសង្គមផ្សេងៗដូចជា ក្រុមហ៊ុន ISS(INTERNATIONAL SOLAR SOLUTION) KAMWORKS និង SOLAR PHUMYEOUNG ជាដើម។ រហូតមកដល់បច្ចុប្បន្ននេះមានអតិថិជនចំនួន 1,034 នាក់ បានទិញបន្ទះសូឡាតាមរយៈប្រាក់កម្ចីរបស់យើង។

# ផ្នែកសមិទ្ធផលសង្គម

**វីសិនហ្វាន់ខេមបូឌា បាននិងកំពុងធ្វើការជាមួយដៃគូយុទ្ធសាស្ត្រ និងស្ថាប័នមួយចំនួនដែលសមានចិត្តដូចគ្នា ដើម្បីអភិវឌ្ឍ កែសម្រួល និងផ្តល់ជូននូវកម្មវិធីផលិតផលសង្គមឲ្យបានទូលំទូលាយជាងមុន ដើម្បីជាកិច្ចខិតខំប្រឹងប្រែង និងការបង្កើនភាពខ្លាំងរបស់ស្ថាប័នក្នុងការជួយលើកកម្ពស់សុខមាលភាពកុមារឲ្យបានប្រសើរឡើងតាមរយៈការដោះស្រាយភាពក្រីក្រជាសកល។**

យើងបានរៀបចំកម្មវិធីសង្គម និងសកម្មភាពសង្គមផ្សេងៗជាច្រើនក្នុងគោលបំណងបង្កើនអត្ថប្រយោជន៍ និងផលប៉ះពាល់សម្រាប់អតិថិជន កូនរបស់ពួកគេ និងសហគមន៍។ ជារៀងរាល់ឆ្នាំ យើងរៀបចំកម្មវិធីដូចជា កម្មវិធីជ្រើសរើសអតិថិជនឆ្នើម កម្មវិធីអាហារូបករណ៍កុមារ (កូនអតិថិជន) កម្មវិធីពានរង្វាន់សិស្សឆ្នើម កម្មវិធីចាប់ឆ្នោតផ្សងសំណាង និងកម្មវិធីសប្បុរសធម៌ផ្សេងៗជាដើម ។

យើងផ្តល់ឱកាសការងារសម្រាប់ប្រជាជននៅតាមសហគមន៍ បុគ្គលិកដែលពិការផ្តល់ជូននូវការអប់រំផ្នែកហិរញ្ញវត្ថុ ការអប់រំផ្នែកសុខភាព ហើយធ្វើការផ្សារភ្ជាប់អតិថិជនជាមួយអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូរបស់ វីសិនហ្វាន់ ដើម្បីឲ្យពួកគេទទួលបាននូវសេវាមិនមែនហិរញ្ញវត្ថុមានដូចជា អាហារ ទឹកស្អាត សុខមាលភាព ការអប់រំ សន្តិភាព និង យុត្តិធម៌។ កិច្ចខិតខំប្រឹងប្រែងរបស់យើង បាននឹងកំពុងបន្តជួយប្រជាជនដែលងាយរងគ្រោះដូចជាអ្នកដែលរងការប៉ះពាល់ជាមួយមេរោគអេដស៍ ឬជំងឺអេដស៍(HIV/AIDS) និងកុមារកំព្រា និងកុមារងាយរងគ្រោះ(OVC) ជនពិការ ស្ត្រីមេម៉ាយ គ្រួសារ ពលកម្មកុមារ និងក្រុមដែលជួបការលំបាកផ្សេងៗ ។



## I.) របៀបបកស្រាយពីបេសកកម្មសង្គមរបស់យើង




## ចំនុចសំខាន់អំពីការគ្រប់គ្រងលទ្ធផលការងារសង្គម

- វីសិនហ្វាន់ ខេមបូឌា បានបន្តផ្តោតសំខាន់លើប្រជាជនក្រីក្រ និង មិនដែលឃ្លាតឆ្ងាយពីបេសកកម្មសង្គមរបស់ខ្លួនឡើយ ជាមួយទំហំប្រាក់កម្ចីជាមធ្យមសម្រាប់អតិថិជនក្នុងកម្ចីវគ្គទីមួយ មានចំនួន US $345 ដុល្លារអាមេរិក( 34% ក្រោម GDP ដែលកំណត់ដោយប្រទេសកម្ពុជាក្នុងមួយនាក់ត្រឹម 1,008 ដុល្លារអាមេរិក-ប្រភពពីធនាគារពិភពលោកឆ្នាំ (2010-2014) ។
- កុមារចំនួនជាង 753,000 ដែលជាកូនអតិថិជនរួមជាមួយបុគ្គលិករបស់ពួកគេកំពុងទទួលផលប៉ះពាល់ដោយសារសេវាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុរបស់ វីសិនហ្វាន់។
- ផ្តោតសំខាន់លើ GENDER និងការផ្តល់អំណាចដល់ស្ត្រី (ដោយសារ អតិថិជន 94% ជាស្ត្រី)។
- អតិថិជនរបស់យើងភាគច្រើន (88%) រស់នៅតំបន់ជនបទក្រីក្រ។
- 22.4% នៃអតិថិជនក្នុងវគ្គកម្ចីទីមួយរបស់យើងរស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (NPL) បើប្រៀបធៀបជាមួយបន្ទាត់ភាពក្រីក្រថ្នាក់ជាតិដែលស្មើនឹង 16.4% (យោងតាមរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ2011)។ នេះបញ្ជាក់ថាការបម្រើដល់ប្រជាជនក្រីក្ររបស់យើងគឺល្អលើសពីបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (NPL)។
- អនុវត្តការវាយតម្លៃតាមស្តង់ដារសកលសម្រាប់ការគ្រប់គ្រងលទ្ធផលការងារសង្គម (USSPM) និង បានដាក់ជូនទៅ MIX សម្រាប់ការវាយតម្លៃ ហើយទទួលបានរង្វាន់ S.T.A.R (លើតម្លាភាពនិងការទទួលខុសត្រូវសង្គម) ដែលជាការទទួលស្គាល់ដោយ MIX លើការអនុវត្តតាម USSPM។
- ទទួលបានត្រា (SEAL) សម្រាប់តម្លាភាពនៃតម្លៃលើផលិតផលពី MICROFINANCE TRANSPARENCY
- ទទួលបានចំណាត់ថ្នាក់ដ៏ល្អប្រសើរ A- ពីកម្មវិធី SMART GIRAFE របស់ស្ថាប័នវាយតម្លៃ PLANET RATING លើ ប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន។
- បានដាក់ដំណើរការផលិតផលសន្សំថ្មីសម្រាប់សាធារណជនក៏ដូចជានៅក្នុងកិច្ចសហប្រតិបត្តិការជាមួយដៃគូ មានដូចជាគណនីកូនល្អ ជាដើម។
- បានបង្កើនការប្រើប្រាស់ទឹកស្អាត (អនាម័យ និងទឹកស្អាត) និងការផ្តល់ប្រាក់កម្ចីដែលការពារបរិស្ថាន (GREEN LOAN) ដូចជា កម្ចីសម្រាប់ធុងចម្រោះទឹក កម្ចីសម្រាប់បង្គន់អនាម័យ និងកម្ចីសម្រាប់ផលិតផលដើរដោយថាមពលពន្លឺព្រះអាទិត្យ។
- លើសពី 99% នៃអតិថិជនគូរ បានបង្ហាញពីផលប្រយោជន៍នៃប្រាក់កម្ចីសម្រាប់កូនៗរបស់ពួកគេ។ ផលប្រយោជន៍សំខាន់ៗបីយ៉ាង លើសុខមាលភាពកុមារ (CWBO) រួមមាន៖
  1. អនាម័យមានភាពប្រសើរឡើង (62%)
  2. សម្លៀកបំពាក់/ ស្បែកជើងបន្ថែម (59%) និង
  3. ផ្តល់ប្រាក់សម្រាប់ការចំណាយលើសុខភាពកុមារ (57%) ។

## 2.) ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

### ទស្សនៈវិស័យ

ចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូណ៌
សេចក្ដីអធិដ្ឋានរបស់យើងសូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសម្រេចបំណងនេះ

### បេសកកម្មរបស់យើង

**យើងជឿជាក់ថាកុមារនឹងមានអនាគតភ្លឺស្វាង**

តាមរយៈការផ្ដល់អំណាចដល់គ្រួសាររបស់គេ ក្នុងការបង្កើតប្រាក់ចំណូល និងមានការងារធ្វើ និងពង្រីកសក្ដានុពលសេដ្ឋកិច្ចដើម្បីឲ្យសហគមន៍រីកលូតលាស់

**វីសិនហ្វាន់-ទទួលបានអំណាចហិរញ្ញវត្ថុពីអង្គការទស្សនៈពិភពលោក**




### តម្លៃមូលដ្ឋានៈ

យើងជាគ្រិស្តបរិស័ទ
យើងប្ដេជ្ញាចិត្តជួយដល់ជនក្រីក្រ
យើងឲ្យតម្លៃមនុស្ស
យើងជាដៃគូ
យើងជាអ្នកបម្រើដែលមានទំនួលខុសត្រូវខ្ពស់
យើងជាអ្នកឆ្លើយតប

## 3.) របាយការណ៍លទ្ធផលការងារសង្គម (គិតត្រឹម ខែ ធ្នូ 2014)

| ការពិពណ៌នា | ធ្នូ 2014 | | ផលប័ត្រឥណទាន | |
|---|---|---|---|---|
| ផលិតផល និងសេវាកម្ម | | | | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| **A. ផលិតផលកម្ចី** | | | | |
| ចំនួនអតិថិជន កម្ចីបរកសិកម្ម | 160,199 | 69.97% | 64,548,038 | 71.01% |
| ចំនួនអតិថិជន កម្ចីអាជីវកម្មខ្នាតតូច | 27,211 | 11.89% | 17,284,807 | 19.01% |
| ចំនួនអតិថិជន កម្ចីមិនមែនអាជីវកម្ម/សង្គម ( ឧ.កម្ចីទិញធុងច្រោះទឹក បង្គន់អនាម័យ និងឧបករណ៍ដើរដោយពន្លឺព្រះអាទិត្យ ជាដើម ) | 27,039 | 11.81% | 1,232,564 | 1.36% |
| ចំនួនអតិថិជន កម្ចីអប់រំ | 790 | 0.35% | 407,506 | 0.45% |
| ចំនួនអតិថិជន កម្ចីគ្រាអាសន្ន | 74 | 0.03% | 13,080 | 0.01% |
| ចំនួនអតិថិជន កម្ចីអភិវឌ្ឍន៍សហគមន៍ | 19 | 0.01% | 105,337 | 0.12% |
| **B. ផលិតផលសន្សំ** | | | | |
| ចំនួនអតិថិជន គណនីសង្ឃឹម | 13,816 | 46.33% | 1,698,082 | 11.52% |
| ចំនួនអតិថិជន គណនីបញ្ញើអភិវឌ្ឍន៍សង្គម ( SITD) | 1,287 | 4.32% | 12,947,827 | 87.87% |
| ចំនួនអតិថិជន គណនីកូនល្អ | 14,715 | 49.35% | 88,724 | 0.60% |
| ចំនួនអតិថិជន សន្សំជាស្ត្រី | 18,470 | 61.94% | 4,476,811 | 30.38% |
| **C. ផលិតផល/សេវាកម្ម មិនមែនហិរញ្ញវត្ថុ** | | | | |
| ចំនួនអតិថិជន គម្រោងសំណាញ់ សុវត្ថិភាពសម្រាប់ជនក្រីក្រ (SNP) និងធានារ៉ាប់រង Micro-life | 226,954 | 99.13% | | |
| ចំនួនអតិថិជន ទទួលបានការធានារ៉ាប់រងពីក្រុមហ៊ុន PKMI លើសេវាសុខភាពខ្នាតតូច និងធានារ៉ាប់រងសម្រាប់ពិការភាព | 6,564 | 2.87% | | |
| ចំនួនអតិថិជនទទួលបានការអប់រំផ្នែកហិរញ្ញវត្ថុកម្រិតមូលដ្ឋាន | 122,311 | 53.02% | | |
| ចំនួនអតិថិជនទទួលបានការអប់រំផ្នែកហិរញ្ញវត្ថុជាន់ខ្ពស់ | 82,231 | 44.02% | | |
| ចំនួនអតិថិជនទទួលបានសេវា/ការអប់រំសុខភាព | 4,900 | 2.14% | | |
| ចំនួនអតិថិជនឆ្នើមប្រចាំឆ្នាំ | 85 | 0.04% | | |
| ចំនួនអាហារូបករណ៍កុមារ(រួមជាមួយកុមារទំនុកបម្រុងដែលមានគណនីសន្សំ ដែលឧបត្ថម្ភដោយ WVSP និង WVHK | 332 | 0.15% | | |

| ការពិពណ៌នា | ធ្នូ 2014 | ផលប័ត្រឥណទាន | | |
|---|---|---|---|---|
| **ភូមិសាស្ត្រ លើសពីការរំពឹងទុក** | | | | |
| | **ចំនួន** | | | |
| ភូមិ | 5,685 | | | |
| សង្កាត់ | 1,182 | | | |
| ខណ្ឌ | 168 | | | |
| ខេត្ត / ក្រុង | 25 | | | |
| **បម្រើអតិថិជន និងផលប័ត្រឥណទានលើសពីការរំពឹងទុក** | | | | |
| | **ចំនួន** | **ភាគរយ** | **ចំនួន** | **ភាគរយ** |
| ចំនួនអតិថិជនខ្ចី សរុប | 228,948 | N/A | 90,901,650 | N/A |
| ចំនួនអតិថិជនខ្ចី នៅតំបន់ជនបទ | 201,790 | 88.14% | 78,315,525 | 86.15% |
| ចំនួនអតិថិជនខ្ចី ជាស្ត្រី | 215,028 | 93.92% | 84,226,418 | 92.66% |
| ចំនួនអតិថិជនខ្ចី ជាក្រុម | 191,532 | 83.66% | 39,083,978 | 43.00% |
| **កំណត់គោលដៅនៃភាពក្រីក្រ និង M& E** | | | | |
| ការវាយតម្លៃភាពក្រីក្រ | ប្រើប្រាស់ឧបករណ៍សន្ទស្សន៍នៃដំណើរការចាកផុតពីភាពក្រីក្រ (PPI) លើការវាស់វែងកម្រិតក្រីក្រ នៃអតិថិជនទាំងអស់ទាំងអតិថិជនថ្មី និងចាស់ ក្នុងវដ្តនៃកម្ចី | | | |
| បន្ទាត់ក្រីក្រ<br>• បន្ទាត់ក្រីក្រថ្នាក់ជាតិ (NPL)<br>• បន្ទាត់ក្រីក្រ2.5ដុល្លារអាមេរិក/ក្នុងមួយថ្ងៃ<br>• បន្ទាត់ក្រីក្រខ្លាំងរបស់ USAID | • បន្ទាត់ក្រីក្រថ្នាក់ជាតិ នៃកម្ពុជា<br>• បន្ទាត់ក្រីក្រថ្នាក់អន្តរជាតិ<br>• ជនងាយរងគ្រោះ / ក្រីក្រខ្លាំង | | | |
| ការតាមដានភាពក្រីក្រ និងការធ្វើរបាយការណ៍ | តារាងពិន្ទុ PPI របស់អតិថិជននីមួយៗ បានបញ្ចូល និងតាមដាននៅក្នុងប្រព័ន្ធ MIS។ ទិន្នន័យដកស្រង់ចេញពី MIS ជារបាយការណ៍ប្រចាំខែឲ្យបុគ្គលិក និងការគ្រប់គ្រងលើព័ត៌មាន ការធ្វើការសម្រេចចិត្ត និងសកម្មភាពបន្ទាប់។ | | | |
| របាយការណ៍សមិទ្ធផលសង្គម | 1. សូចនាករសំខាន់នៃលទ្ធផលការងារសង្គម និងដំណើរការដែលរាយការណ៍ដោយ វីសិនហ្វាន់ ខេមបូឌា ជារៀងរាល់ខែសម្រាប់បុគ្គលិក និងអ្នកគ្រប់គ្រងសម្រាប់ ទុកជា ឯកសារយោងក្នុងការសម្រេចចិត្ត និង សកម្មភាពបន្ទាប់។<br>2. សូចនាករសំខាន់ និងដំណើរការSP និងរាយការណ៍ ដោយ វីសិនហ្វាន់ អន្តរជាតិ ប្រចាំត្រីមាស ដើម្បីដាក់បញ្ចូលព័ត៌មានថ្មី ទៅ VFI Leadership និងបណ្តាញគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | | | |
| ការស្ទង់មតិភាពពេញចិត្តរបស់ អតិថិជន | បានធ្វើឡើងជារៀងរាល់ឆ្នាំដើម្បី រកមូលហេតុ អតិថិជនពេញចិត្ត ឬមិនពេញចិត្តពីផលិតផល/សេវារបស់ វីសិនហ្វាន់ ឬ បុគ្គលិកជាដើម | | | |
| ការស្ទង់មតិ អតិថិជនចាកចេញពី វីសិនហ្វាន់ | បានធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីរកមូលហេតុដែលអតិថិជន ចាកចេញពីកម្មវិធី | | | |

| ការពិពណ៌នា | ឆ្នាំ 2014 |
| --- | --- |
| ការវាយតម្លៃសមិទ្ធផលសង្គម | បានធ្វើឡើងជារៀងរាល់ 2 ឆ្នាំម្តង ដោយសវនកម្មផ្ទៃក្នុង និងក្រុមវាយតម្លៃ ដើម្បីវាយតម្លៃការអនុវត្តសមិទ្ធផលសង្គមជារួម របស់សាខាខេត្ត |
| ការវាស់វែងសង្គម | បានធ្វើឡើងដោយភាគីខាងក្រៅជារៀងរាល់ 2 ឬ 3 ឆ្នាំ (អាស្រ័យលើការសម្រេចចិត្តរបស់អគ្គនាយកប្រតិបត្តិ) ដើម្បីវាយតម្លៃលើសមិទ្ធផលសង្គមរបស់ វីសិនហ្វាន់ ខេមបូឌា |
| ការវាស់វែងផ្សេងៗ និងការស្រាវជ្រាវ | ដោយសហការជាដៃគូជាមួយ អង្គការ និងស្ថាប័នដែលមានគោលដៅដូចគ្នា ភ្ជាប់ជាមួយការវាយតម្លៃ ឬការស្រាវជ្រាវ ដែលធ្វើឡើងដោយដៃគូ ដែលអាចរកបាន សម្រាប់ជាឯកសារយោង និងការធ្វើសេចក្តីសម្រេច |
| **ទំនួលខុសត្រូវសង្គម ចំពោះបុគ្គលិក** | |
| ច្បាប់ធនធានមនុស្ស | សេចក្តីលម្អិតពីច្បាប់ធនធានមនុស្ស មាននៅកន្លែង និងអនុវត្ត |
| បុគ្គលិកទទួលបានការបណ្តុះបណ្តាល និងបណ្តុះបណ្តាលរំលឹក លើSPM រួមមាន CPPs | សម្រាប់បុគ្គលិកទាំងអស់ |
| បុគ្គលិកទទួលបានការបណ្តុះបណ្តាលផ្សេងៗ សម្រាប់ការកសាងសមត្ថភាពនិង មុខងារ | បុគ្គលិកទាំងអស់បានទទួលការបណ្តុះជាច្រើន ក្នុងមួយឆ្នាំ ដើម្បីអាចបំពេញការងាររបស់គេបានយ៉ាងល្អ និងជាផ្នែកមួយនៃការកសាងសមត្ថភាពរបស់ពួកគេ |
| ការវាយតម្លៃលទ្ធផលការងារ និងប្រាក់លើកទឹកចិត្តបុគ្គលិក | ភ្ជាប់សូចនាករសង្គមឲ្យមានមានតុល្យភាពរវាងសង្គម និងការ ផ្តោតលើហិរញ្ញវត្ថុ ក៏ដូចជាដើម្បីជម្រុញដល់លទ្ធផលការងារសង្គមក្នុងស្ថាប័ន |
| **ទំនួលខុសត្រូវសង្គម ចំពោះ អតិថិជន** | |
| សៀវភៅណែនាំសេវាអតិថិជន | សៀវភៅណែនាំសេវាអតិថិជន នៅកន្លែង និងអនុវត្ត |
| គោលការណ៍ការពារអតិថិជន | ស្ថាបនា និងអនុវត្ត ការវាយតម្លៃ CPP ដែលធ្វើឡើងដោយអ្នកប្រឹក្សាយោបល់ខាងក្រៅ ដើម្បីវាស់ពីរបៀប ដែលវីសិនហ្វាន់បានអនុវត្ត CPPs ទាំង 7ចំនុច។ |
| **ទំនួលខុសត្រូវសង្គម ចំពោះសហគមន៍ និងបរិស្ថាន** | |
| គោលការណ៍ណែនាំជួលការិយាល័យ និង ការប្រើប្រាស់ | លម្អិតពីគោលការណ៍ ការិយាល័យ និងការប្រើប្រាស់នៅក្នុងកន្លែងធ្វើការ និងការអនុវត្តសន្សំសំចៃក្រដាស ទឹក ភ្លើង នៅក្នុងការិយាល័យ |
| ច្បាប់ SPM រួមបញ្ចូល ការការពារបរិស្ថាន | លម្អិតពីគោលការណ៍ SPM រួមមានការការពារបរិស្ថាននៅកន្លែង និងអនុវត្ត |
| បុគ្គលិកសំខាន់តាមសហគមន៍ ទទួលបានការបណ្តុះបណ្តាលស្តីពីការការពារបរិស្ថាន | បុគ្គលិកតាមសហគមន៍ទាំងអស់ ទទួលបានការបណ្តុះបណ្តាលស្តីពី ការការពារបរិស្ថាន ដើម្បីចែកចាយសារ ពីការការពារបរិស្ថានដល់អតិថិជន |
| ការងារ | ប្រជាជនក្នុងស្រុក/យុវជន ត្រូវបានលើកទឹកចិត្ត និងបម្រើការងារជាមួយ វីសិនហ្វាន់ |
| អតិថិជនបានភ្ជាប់ទំនាក់ទំនង ទទួលអត្ថប្រយោជន៍ ពីសេវាមិនមែនហិរញ្ញវត្ថុដែលផ្តល់ដោយអង្គការក្រៅ | អតិថិជនរបស់យើង ត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងសកម្មភាពអភិវឌ្ឍន៍របស់អង្គការក្រៅរដ្ឋាភិបាល និងដៃគូ រួមមាន៖<br>អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា)(WVI-C)សហគ្រាសអភិវឌ្ឍអន្តរជាតិ(iDE)សហគ្រាសរដ្ឋាភិបាល និងដៃគូផលិតផលសង្គមហាដ្រូឡូជិ (Hydrologic) អង្គការ WaterSHED កម្ពុជា អង្គការ Habitat for Humanity អង្គការRotary Club ក្រុមហ៊ុន PKMI ក្រុមហ៊ុន Kamworks សហគ្រាស Solar Phumyeung អង្គការភ្លែនកម្ពុជា(Plan) អង្គកាហាការ(Hagar) |

| ការពិពណ៌នា | ធ្នូ 2014 ផលប័ត្រឥណទាន |
| --- | --- |
| មួយផ្នែកនៃប្រាក់ចំណេញសុទ្ធ បានទុកចំណាយលើការបង្កើតតម្លៃឲ្យអតិថិជន និងសហគមន៍ | ចំនួនជាក់លាក់នៃប្រាក់ចំណេញសុទ្ធ បានទុកជារៀងរាល់ឆ្នាំសម្រាប់ចំណាយលើសកម្មភាពសង្គម កម្មវិធី សប្បុរសធម៌ ការបរិច្ចាគ ដើម្បីបង្កើតតម្លៃឲ្យអតិថិជន និងសហគមន៍។ ប្រាក់ចំណេញសុទ្ធ11% បានទុកចំណាយលើការបង្កើតតម្លៃឲ្យអតិថិជន និងសហគមន៍។ |

## ធនធានមនុស្ស

| | ចំនួន | ភាគរយ | | |
| --- | --- | --- | --- | --- |
| ចំនួនបុគ្គលិក បម្រើការតាមសហគមន៍ | 706 | 59.2% | | |
| ចំនួនបុគ្គលិកមកពីសហគមន៍ជនបទ | 1,072 | 90.01% | | |
| ចំនួនបុគ្គលិក ជាស្ត្រី | 409 | 4.34% | | |
| ចំនួនបុគ្គលិកជាស្ត្រី ក្នុងមុខដំណែងគ្រប់គ្រង | 10 | 18.18% | | |

## រង្វាន់ និងការទទួលស្គាល់ពីសង្គម

| | |
| --- | --- |
| 1. ពានរង្វាន់ S.T.A.R ( តម្លាភាព សង្គម និងទំនួលខុសត្រូវ) | ទទួលបានរង្វាន់ពី MIX នៅចុងឆ្នាំ2013 លើការសម្រេច បាននូវលទ្ធផលខ្ពស់នៃការអនុលោមតាមច្បាប់ ជាមួយ USSPM |
| 2. ពានរង្វាន់ប្លាទីន | ទទួលបានរង្វាន់ពី MIX នៅក្នុងឆ្នាំ 2011 ដែលជារង្វាន់ថ្នាក់ កំពូលលើការលើការរៀបចំរបាយការណ៍លទ្ធផលការងារ សង្គម កម្រិតប្លាទីន |
| 3. ពានរង្វាន់មាស | ទទួលបានរង្វាន់ពី MIX នៅក្នុងឆ្នាំ 2010 លើការរៀបចំរបាយការណ៍លទ្ធផលការងារសង្គម កម្រិតមាស |
| 4. ពានរង្វាន់ប្រាក់ | ទទួលបានរង្វាន់ពី MIX នៅក្នុងឆ្នាំ 2009 លើការរៀបចំរបាយការណ៍លទ្ធផលការងារសង្គម |
| 5. ពានរង្វាន់ ESG (បរិស្ថានសង្គម និងអភិបាលកិច្ចល្អ) | ទទួលបានរង្វាន់ពី Oikocredit នៅក្នុងឆ្នាំ 2013 លើសការផ្តល់សេវាកម្មហិរញ្ញវត្ថុផ្តោតលើជនក្រ |
| 6. ពានរង្វាន់ សមិទ្ធផលឆ្នើម (Award for Outstanding Achievement) | ទទួលបានរង្វាន់ពី Oikocredit នៅក្នុងឆ្នាំ2013 លើការទទួលបានលទ្ធផលការងារសង្គមឆ្នើម(outstanding achievement in social performance)។ |
| 7. ពានរង្វាន់ទទួលបានការទទួលស្គាល់លើតម្លាភាពនៃតម្លៃ | ទទួលបានរង្វាន់ពី Microfinance Transparency នៅក្នុងឆ្នាំ2013 លើការចូលរួមគំនិតផ្តួចផ្តើមតម្លាភាពនៃតម្លៃ ( for participating in the Transparent Pricing Initiative ) |
| 8. រង្វាន់ FIVE DIAMONDS | ទទួលបានរង្វាន់ពី MIX Market នៅក្នុងឆ្នាំ2013 លើការផ្តល់ទិន្នន័យច្បាស់លាស់ត្រឹមត្រូវ និងឧត្តមភាពក្នុងការបង្ហាញនូវព័ត៌មានរបស់ខ្លួន |
| 9. ស្លាកសញ្ញា KIVA ផ្តោតលើការប្រឆាំងភាពក្រីក្រ (Kiva Badge for Anti-Poverty Focus) | ទទួលបានរង្វាន់ពី Kiva នៅក្នុងឆ្នាំ2012 លើការបង្ហាញពីការប្តេជ្ញាចិត្តដ៏អស្ចារ្យក្នុងការជួយសម្រួលដល់សហគមន៍ដែលពួកគេបម្រើការ |
| 10. ទទួលបានពានរង្វាន់ផ្សេងៗ ការទទួលស្គាល់ និងការពេញចិត្ត ពីសំណាក់ដៃគូ អ្នកពាក់ព័ន្ធ និងម្ចាស់ជំនួយ | CGAP Micro Summit Campaign វីសិនហ្វាន់ អន្តរជាតិ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ធនាគារជាតិនៃកម្ពុជា កាកបាទក្រហមកម្ពុជា និង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |

## 4.) ការវាស់កម្រិតភាពក្រីក្រ និងផលប៉ះពាល់របស់អតិថិជន

### សន្ទស្សន៍នៃដំណើរការចាកផុតពីភាពក្រីក្រ (PPI)

វីសិនហ្វាន់ ខេមបូឌា ប្រើប្រាស់ PPI ដើម្បី៖

- វាស់វែងកម្រិតក្រីក្ររបស់អតិថិជន ដែលជាឧបករណ៍ដ៏ត្រឹមត្រូវ
- ដឹងពីទំហំនៃការបម្រើអតិថិជនក្រីក្រ នាពេលបច្ចុប្បន្ន
- កំណត់សម្គាល់តំបន់ និងវិធីសាស្ត្រដែលយើងអាចបម្រើប្រជាជនក្រីក្រកាន់តែច្រើនឡើង

យើងប្រើ PPI ជាការស្ទង់មតិមានលក្ខណៈដូចជំរឿន ជំនួសឲ្យការស្ទង់មតិដោយជ្រើសរើសអតិថិជនគំរូ ដើម្បីវាស់កម្រិតក្រីក្ររបស់អតិថិជនថ្មីទាំងអស់ និង អតិថិជនដែលកំពុងប្រើប្រាស់កម្ចីក្នុងវគ្គសេសមានដូចជាវគ្គទី3 ទី5 ទី7 ទី9 និង វគ្គទី11 ជាដើម។ វីសិនហ្វាន់ ខេមបូឌា បានចាប់ផ្តើមសាកល្បង ដាក់ឲ្យប្រើប្រាស់ PPI ក្នុងសាខាមួយចំនួនមុនពេល ដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅគ្រប់សាខាទាំងអស់ក្នុងដើមឆ្នាំ2012។

គិតត្រឹមខែធ្នូឆ្នាំ 2014 អតិថិជន 138,523នាក់ (62%) នៅគ្រប់សាខាខេត្តទាំង 17 ត្រូវបានវាយតម្លៃដោយប្រើប្រាស់ឧបករណ៍វាយតម្លៃ PPI ។ ដោយបានប្រើប្រាស់ PPI វីសិនហ្វាន់ ខេមបូឌា បានកំណត់ទិសដៅដ៏ត្រឹមត្រូវលើប្រជាជនក្រីក្រមធ្យម និងក្រីក្របំផុតដើម្បីអាចជួយឲ្យពួកគេរួចផុតពីភាពក្រីក្រ។ ផ្អែកលើឧបករណ៍វាស់វែងភាពក្រីក្រ PPI វីសិនហ្វាន់ ខេមបូឌា បានបម្រើដល់អតិថិជនថ្មីចំនួន 22.49% ដែលកំពុងរស់នៅក្រោមបន្ទាត់ក្រីក្រជាតិ (NPL)មានន័យថាប្រជាជនក្នុងក្រុមនេះ គឺតំណាងឲ្យប្រជាជនក្រីក្រក្នុងប្រទេសកម្ពុជា។ នៅពេលប្រៀបធៀបនឹងអត្រានៃភាពក្រីក្រជាតិកម្ពុជាដែលស្មើរនឹង16.40% តាមធនាគារពិភពលោកឆ្នាំ 2011។ យើងបានបម្រើអតិថិជនដែលក្រីក្របំផុតចំនួន 9.24% ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្របំផុតរបស់ USAID។



## សុខមាលភាពកុមារ និងផលប៉ះពាល់

ដើម្បីវាស់វែងផលប៉ះពាល់លើគ្រួសារ ជាពិសេសកុមារ យើងបានបន្ថែមសំនួរ ចំនួន 5 ទៀត ក្នុងទម្រង់បែបបទប្រាក់កម្ចី (LAF) ដូចជា៖

- តើចំនូលរបស់អតិថិជនមានការផ្លាស់ប្រែយ៉ាងដូចម្តេច ក្រោយពីទទួលបានប្រាក់កម្ចី?
- តើប្រាក់កម្ចីកន្លងមកអាចជួយដល់កូនរបស់អតិថិជនបានដែរឬទេ?
- ប្រសិនបើប្រាក់កម្ចីកន្លងមកអាចជួយបាន តើបានជួយទៅលើចំនុចអ្វីខ្លះដល់កូនរបស់អ្នក?
- តើអតិថិជនជឿជាក់ទៅលើប្រាក់កម្ចីនេះយ៉ាងដូចម្តេចដែរ ក្នុងការជួយដល់កូនៗរបស់ពួកគាត់?

យើងបានដាក់ឲ្យប្រើប្រាស់ទម្រង់បែបបទថ្មីនេះចាប់ពីចុងឆ្នាំ 2013 ដើម្បីយល់ឲ្យកាន់តែច្បាស់ ថាតើសេវារបស់យើងអាចជួយដល់កុមារយ៉ាងដូចម្តេចខ្លះ? ព័ត៌មានបន្ថែមរួមមាន ការផ្លាស់ប្រែនៃចំណូលក្នុងគ្រួសារ ចំនួនកុមារ និងផលប្រយោជន៍អ្វីខ្លះដែលអតិថិជនទទួលបានពីកម្ចី។

ដោយផ្អែកលើសំណួរគន្លឹះទាំងប្រាំ, យើងអាចប្រមូលទិន្នន័យសុខុមាលភាពកុមារសម្រាប់ការវិភាគស៊ីជម្រៅហើយ 99% នៃអតិថិជនគំរូសរុបចំនួន 27,718បង្ហាញថាកូនរបស់ពួកគេ បានទទួលផលប្រយោជន៍ ពីប្រាក់កម្ចីដែលគាត់បានខ្ចី។ ក្នុងចំណោមអតិថិជនដែលប្រាប់យើងថាប្រាក់កម្ចីជួយគ្រួសាររបស់ពួកគេ ជាពិសេសកុមា៖

- 62% បានរាយការណ៍ថា មានការរីកចម្រើនផ្នែកអនាម័យ
- 59% បានរាយការណ៍ថា មានសំលៀកបំពាក់ និងស្បែកជើងច្រើនជាងមុន
- 57% បានរាយការណ៍ថា បានទទួលការចំណាយលើសុខភាពកុមារ
- 56% បានរាយការណ៍ថា មានទឹកបរិភោគគ្រប់គ្រាន់
- 53% បានរាយការណ៍ថា មានអាហារគ្រប់គ្រាន់
- 47% បានរាយការណ៍ថា មានការអប់រំមូលដ្ឋានដែលប្រសើរ
- 26% បានរាយការណ៍ថា មានជម្រកដែលប្រសើរឡើង
- 9% បានរាយការណ៍ថា យុវជនមានឱកាសរៀនសូត្រ






## 5.) គោលការណ៍ការពារអតិថិជន និងការអនុវត្តន៍តាម

ការវាយតម្លៃគោលការណ៍អតិថិជនរបស់យើង ត្រូវបានអនុវត្តដោយអ្នកពិគ្រោះយោបល់ខាងក្រៅដើម្បីវាស់វែងការអនុវត្តតាម គោលការណ៍ការពារអតិថិជនទាំង7 ចំនុចរបស់ វីសិនហ្វាន់ នៅចុងឆ្នាំ 2013។ វាត្រូវបានគាំទ្រដោយ SMART CAMPAIGN ជាមួយការអនុលោមតាមគោលការណ៍ការពារអតិថិជនរហូតដល់ 77% នៃគោលការណ៍ទាំងមូល។

| លរ | គោលការការពារអតិថិជន | ការអនុវត្តន៍ |
|---|---|---|
| 1 | ការបង្កើត និងផ្តល់ផលិតផលដែលសមរម្យ | • មានផ្តល់ជូនផលិតផលប្រភេទផ្សេងៗ ដូចជា កម្ចីសម្រាប់គោលបំណង ផ្សេងៗ រួមមាន កម្ចីសម្រាប់កសិកម្ម កម្ចីសម្រាប់អាជីវកម្ម កម្ចីសម្រាប់គ្រាមានអាសន្ន កម្ចីសម្រាប់ការអប់រំរបស់យុវជន កម្ចីមិនមែនអាជីវកម្មកម្ចីសម្រាប់ទឹកស្អាត និងអនាម័យ( WASH ) កម្ចីសម្រាប់ផលិតផលដើរដោយថាមពលព្រះអាទិត្យ គណនីបញ្ញើសន្សំ ធានារ៉ាប់រងសុខភាព និងពិការភាពខ្នាតតូច។<br>• សេវាហិរញ្ញវត្ថុ បម្រើជូនអតិថិជនរហ័សទាន់ចិត្ត (មានដូចជា កម្មវិធីពិសេស និងការប្រមូល និងដាក់ប្រាក់កម្ចី នៅក្នុងភូមិជាដើម)<br>• យើងអនុវត្តការស្ទង់មតិជាមួយអតិថិជនដើម្បីសិក្សាអំពីការពេញចិត្ត ការមិនពេលចិត្តរបស់ពួកគេ អត្តចរិករបស់អតិថិជន និងការទោរទន់របស់ពួកគេ |
| 2 | ការការពារការជាប់បំណុលវ័ណ្ឌក | • យើងអនុវត្តមធ្យោបាយផ្តល់កម្ចីចំនួនបី រួមមាន កម្ចីក្រុមសាមគ្គីធនាគារសហគមន៍ កម្ចីក្រុមសាមគ្គី និងកម្ចីឯកត្តជន ដោយធ្វើការកំណត់ទំហំប្រាក់ កម្ចីទៅតាមស្ថានភាពគ្រួសារ<br>• បុគ្គលិកនៅក្នុងតំបន់ បានធ្វើការវាយតម្លៃយ៉ាងម៉ត់ចត់មុននឹងផ្តល់ប្រាក់កម្ចីហើយយើងក៏មានគណៈកម្មការ ក្នុងការអនុម័តប្រាក់កម្ចី ដោយពិនិត្យមើលទិន្នន័យដើម្បីសម្រេចថាតើអតិថិជនមានសមត្ថភាពទទួលប្រាក់កម្ចីដែរឬទេ។<br>• ឯកសារ និងទិន្នន័យរបស់អតិថិជន ត្រូវបានរក្សាទុក និងគ្រប់គ្រងដោយប្រព័ន្ធ MIS ដែលអាចបញ្ចៀសការផ្តល់កម្ចីត្រួតគ្នា និងបញ្ហាផ្សេងៗ។<br>• បុគ្គលិកក្នុងតំបន់ត្រូវបានលើកទឹកចិត្តឲ្យផ្តោតសំខាន់លើសមិទ្ធផលការងារសង្គម និងផ្តល់តម្លៃឲ្យអតិថិជនកាន់តែច្រើនឡើង<br>• សវនករផ្ទៃក្នុង និងមន្ត្រីហានិភ័យនិងពង្រឹងគុណភាពធ្វើការត្រួតពិនិត្យជាទៀងទាត់លើការជាប់បំណុលគ្រួសារ និង/ឬ ការអនុវត្តណាមួយដែលខុសពីដំណើរការរួមមានការផ្តល់ប្រាក់កម្ចីជាច្រើន និងការអនុវត្តន៍ផ្សេងៗទៀតដែលអាចបង្កើនបំណុលបំណុលវ័ណ្ឌក។<br>• សេវាហិរញ្ញវត្ថុ រួមជាមួយសេវាមិនមែនហិរញ្ញវត្ថុ ដែលផ្តល់ដោយដៃគូអង្គការ បន្ថែមតម្លៃអត្ថប្រយោជន៍ និងផលប៉ះពាល់សម្រាប់អតិថិជន ទាក់ទងទៅ នឹងសុវត្ថិភាពចំណីអារហារ ទឹកបរិភោគ សុខភាព ការអប់រំ និងការអភិវឌ្ឍន៍សហគមន៍ដទៃទៀត។ |

| លរ | គោលការការពារអតិថិជន | ការអនុវត្តន៍ |
|---|---|---|
| 3 | តម្លាភាព | • កិច្ចសន្យាកម្ចី និងទម្រង់បែបបទផ្សេងៗត្រូវបានសរសេរជាភាសាខ្មែរ ហើយត្រូវបានអានសម្រាប់អតិថិជនដើម្បីឲ្យពួកគាត់យល់ពីលក្ខខណ្ឌ និងព័ត៌មាន លម្អិតចាំបាច់ផ្សេងៗ។<br>• មុនទទួលបានកម្ចី អតិថិជនត្រូវទទួលការណែនាំអំពីវិធីសាស្រ្តកម្ចី តម្លៃ លក្ខខណ្ឌ និងព័ត៌មានចាំបាច់ផ្សេងៗ។<br>• យើងផ្តល់ពេលគ្រប់គ្រាន់ដល់អតិថិជនសម្រាប់ការសួរសំនួរ ការពិនិត្យឲ្យច្បាស់ អំពីកិច្ចសន្យាកម្ចីមុននឹងចុះកិច្ចព្រមព្រៀង។ |
| 4 | ការកំនត់តម្លៃដែលមានការទទួលខុសត្រូវ | • យើងមិនយកតម្លៃសេវាបន្ថែមពីអតិថិជន<br>• អត្រាការប្រាក់ គឺផ្អែកលើតុល្យភាពដែលនៅសល់ ចំនែកការគណនាគឺផ្អែកលើមូលដ្ឋានប្រចាំថ្ងៃ( ប្រាក់ដើមដែលបង់សងមួយចំណែក ឬដែលបង់ផ្តាច់ )<br>• យើងអនុវត្តការស្ទង់មតិលើតម្លៃក្នុងចំណោមអ្នកប្រកួតប្រជែង ដើម្បីពិនិត្យមើលថា តម្លៃរបស់យើងមានភាពសមរម្យ និងការប្រកួតប្រជែងក្នុងទីផ្សារ។ |
| 5 | ការដោះស្រាយជាមួយអតិថិជនដោយគោរព និងយុត្តិធម៌ | • អតិថិជន អាចរាយការណ៍អំពីបុគ្គលិកណាមួយដែលមានឥរិយាបទមិនសមរម្យតាមរយៈលេខទូរស័ព្ទ 023 96 3333 ប្រអប់ផ្តល់យោបល់អតិថិជន ឬមកជួបប្រធានរបស់បុគ្គលិកផ្ទាល់។<br>• ដើម្បីធ្វើការវាយតម្លៃការងារបុគ្គលិក អ្នកត្រួតត្រា និងប្រធាន ត្រួតពិនិត្យពីក្រមសីលធម៌របស់បុគ្គលិក រួមមានអាកប្បកិរិយា និងពង្រឹងគុណភាពនៃទំនាក់ទំនងជាមួយអតិថិជន។<br>• បុគ្គលិកត្រូវទទួលបានការណែនាំដើម្បីអនុវត្តតាមគោលការណ៍ក្រមសីលធម៌ និងដើម្បីធានាអំពីការពេញចិត្តរបស់អតិថិជន។<br>• សវនករ និងមន្ត្រីហានិភ័យ និងពង្រឹងគុណភាព កាន់តួនាទីយ៉ាងសំខាន់ក្នុងការរកនូវអំពើរខុសឆ្គងដល់អតិថិជន និងបញ្ហាផ្សេងៗទៀតទាក់ទងទៅនឹងអតិថិជន។ |
| 6 | ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន | • និយោជិកទាំងអស់ត្រូវបានណែនាំយ៉ាងច្បាស់លាស់ក្នុងការរក្សាទិន្នន័យហិរញ្ញវត្ថុ និងព័ត៌មានសម្ងាត់របស់អតិថិជនប្រកបដោយសុវត្ថិភាព។<br>• ទិន្នន័យរបស់អតិថិជនត្រូវបានថែរក្សាទុកដោយប្រព័ន្ធ MIS ដែលមានសុវត្ថិភាពនិងជំនឿចិត្ត។ ប្រព័ន្ធនេះ ត្រូវបានការពារដោយកម្មសិទ្ធបញ្ញា( Copyright )។<br>• ក្នុងករណីចាំបាច់ត្រូវប្រើប្រាស់ទិន្នន័យរបស់អតិថិជនជាមួយអ្នកជាប់ពាក់ព័ន្ធផ្សេងៗ ជាពិសេស CBC (Credit Bureau of Cambodia )បុគ្គលិករបស់យើងនឹងធ្វើលិខិតសុំអនុញ្ញាត្តិការប្រើប្រាស់ទិន្នន័យទាំងនោះពី អតិថិជនជាមុន។ |

| លរ | គោលការការពារអតិថិជន | ការអនុវត្តន៍ |
|---|---|---|
| 7 | យន្តការសម្រាប់ដោះស្រាយបណ្តឹង ឬការតវ៉ារបស់អតិថិជន | • នៅគ្រប់សាខាប្រតិបត្តិការទាំងអស់មានបំពាក់ប្រអប់ផ្តល់យោបល់អ តិថិជន ។ អតិថិជនរបស់យើង អាចទូរស័ព្ទបន្ទាន់មកកាន់លេខ 023 96 3333<br>• គ្រប់មតិរិះគន់ និង/ឬ ការផ្តល់មតិពីអតិថិជនគឺត្រូវបានត្រួតពិនិត្យ និងរាយការណ៍ទៅកាន់គណៈគ្រប់គ្រង និងបុគ្គលិកដើម្បីចាប់ផ្តើមសកម្មភាពអភិវឌ្ឍន៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ។<br>• គ្រប់បុគ្គលិកទាំងអស់ ជាពិសេសបុគ្គលិកជួរមុខ និងគណៈគ្រប់គ្រងគឺទទួលបានការហ្វឹកហាត់លើការដោះស្រាយជាមួយការរិះគន់របស់អតិថិជន ដើម្បីបម្រើដល់អតិថិជនបានប្រសើរឡើងប្រកបដោយវិជ្ជាជីវៈ<br>• ពួកគេជូនដំណឹងដល់អតិថិជនអំពីសិទ្ធិនៃការផ្តល់មតិរិះគន់តាមរយៈមធ្យោបាយផ្សេងៗ ដូចជា ប្រអប់ផ្តល់យោបល់ ទូរស័ព្ទ ឬការជួបប្រធានរបស់បុគ្គលិក និងអ្នកគ្រប់គ្រងផ្ទាល់។<br>• សវនករខាងក្នុង និងមន្ត្រីហានិភ័យ និងពង្រឹងគុណភាពសិក្សាស៊ីជម្រៅលើបញ្ហាជាមួយអតិថិជនដើម្បី ដឹងស្វែងយល់ថាតើអតិថិជនធ្លាប់បានទទួលការរំលោភបំពានផ្នែករាងកាយ ឬពាក្យសម្តី ឬការរិះគន់របស់អតិថិជនពុំទាន់បានដោះស្រាយឬទេ។ |



## 6.) ការអប់រំ ផ្នែកហិរញ្ញវត្ថុ

ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុដែលមានទិសដៅសង្គម វីសិនហ្វាន់ ខេមបូឌា យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះអតិថិជន។ ដូចនេះ យើងផ្តល់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ ។

ការអប់រំហិរញ្ញវត្ថុកម្រិតមូលដ្ឋាន ផ្តល់វគ្គបណ្តុះបណ្តាលដែលមានភាពសាមញ្ញ និងចែកចាយដោយបុគ្គលិក (FIELD STAFF) សម្រាប់អតិថិជនចាស់ និងថ្មីក្នុងកំឡុងពេលដាក់ប្រាក់កម្ចី ដើម្បីអប់រំពួកគេអំពីការរកចំណូលឲ្យបានច្រើនបំផុត និងកាត់បន្ថយចំណាយផ្សេងៗ ក៏ដូចជាដើម្បីបញ្ចៀបទម្លាប់ សន្សំរបស់ពួកគេ។ គិត្រឹមខែធ្នូ ឆ្នាំ 2014 អតិថិជនថ្មីទាំងអស់ បានទទួលវគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុកម្រិតមូលដ្ឋាន។ បុគ្គលិករបស់យើងក៏ឆ្លៀតឱកាសផ្តល់ការប្រឹក្សាមូលដ្ឋានលើអាជីវកម្មសារអប់រំអំពី ការការពារកុមារ និងការ ផ្តល់អំណាចដល់ស្ត្រី។

ការអប់រំហិរញ្ញវត្ថុកម្រិតខ្ពស់ គឺត្រូវបានដកស្រង់ចេញពីកម្មវិធីសិក្សា ចំនេះដឹងហិរញ្ញវត្ថុ របស់ស្ថាប័នអង្គការពលកម្មអន្តរជាតិ (ILO)។ កម្មវិធីសិក្សានេះមានទាំងអស់ចំនួនប្រាំបី ដែលបង្រៀនដោយបុគ្គលិកដល់អតិថិជនកម្ចីជាក្រុម ក្នុងកំឡុងពេលដាក់ប្រាក់កម្ចី ឬប្រមូលប្រាក់កម្ចី។ គិតត្រឹមខែធ្នូ ឆ្នាំ 2014 អតិថិជនកម្ចីជាក្រុម ចំនួន 97% បានទទួលការបណ្តុះបណ្តាលក្នុវគ្គនេះ។ អតិថិជនភាគច្រើនដែលបានចូលរួមការអប់រំផ្នែកហិរញ្ញវត្ថុបាននិយាយថា នេះគឺពិតជាជួយពួកគេក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់ក្នុងគ្រួសារ (ចំណូល និងចំណាយ)ធ្វើឲ្យពួកគេទទួលបានចំណេះដឹង អំពីការបើកអាជីវកម្ម និងការសន្សំប្រាក់ ។





## 7.) អតិថិជនឆ្នើមប្រចាំឆ្នាំ និង អាហារូបករណ៍កុមារ

វីសិនហ្វាន់ ខេមបូឌា បានវិនិយោគលុយចំណេញរបស់ខ្លួនត្រឡប់ទៅសហគមន៍ ដែលជាទំនួលខុសត្រូវមួយលើសហគមន៍ និងអតិថិជនដើម្បីលើកទឹកចិត្តឲ្យពួកគេពង្រីកអាជីវកម្មបានយ៉ាងជោគជ័យ។ ដូចនេះយើងបានដាក់ឲ្យប្រើប្រាស់កម្មវិធីអតិថិជនឆ្នើម ដើម្បីជ្រើសរើសអតិថិជនឆ្នើមប្រចាំសាខានីមួយៗ ជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ 2007 មកម្លេះ។ អតិថិជនឆ្នើម គឺជាអតិថិជនដែលទទួលបានជោគជ័យក្នុងការប្រើប្រាស់ប្រាក់កម្ចីពីវីសិនហ្វាន់ ខេមបូឌា បន្ទាប់ពីបានប្រើប្រាស់កម្ចីពីរ ឬបីវគ្គ។ អតិថិជន ដែលត្រូវបានជ្រើសរើស នឹងបានទទួលរង្វាន់ផ្សេងៗ ដូចជា កង់ សៀវភៅ និងកាបូប។ គិតត្រឹមខែធ្នូ ឆ្នាំ 2014 យើងបានជ្រើសរើសអតិថិជន សរុបចំនួន 85នាក់ ដែលពួកគេសុទ្ធតែជាគំរូល្អសម្រាប់គ្រួសារ និងសហគមន៍ទាំងមូល។ លើសពីនេះកូនម្នាក់របស់ពួកគេនឹងទទួលបានអាហារូបករណ៍ទ្រទ្រង់ការសិក្សារហូតចប់ថ្នាក់ទី12។ រាល់ឆ្នាំ យើងចំណាយ ចំនួន100ដុល្លារអាមេរិក ក្នុងក្មេងម្នាក់ដើម្បីទិញសម្ភារៈសិក្សា ដូចជាកាបូប សំលៀកបំពាក់សិក្សា ប៊ិច ដៃខ្មៅ ជាដើម ប្រាក់ដែលនៅសល់ពីការចំណាយទាំងនេះ វីសិនហ្វាន់ បើកគណនីសន្សំសម្រាប់កុមារ។ គិតត្រឹមខែធ្នូ ឆ្នាំ2014យើងបានផ្តល់អាហារូបករណ៍ដល់កុមារចំនួន 67 នាក់។

លើសពីនេះ យើងទទួលបានជំនួយពី អង្គការទស្សនៈពិភពលោក សិង្ហបុរី និងអង្គការទស្សនៈពិភពលោកហុងកុង ដើម្បីជួយទ្រទ្រង់អាហាររូបករណ៍កុមារ និងប្រាក់សន្សំសម្រាប់កុមារ ។ ការនេះ គឺជួយទ្រទ្រង់អាហាររូបករណ៍កុមារ ក្នុងម្នាក់ទទួលបាន100ដុល្លារអាមេរិក (COVERS US$100 FOR CHILD SCHOLARSHIP) និង 120 ដុល្លារអាមេរិក ក្នុងម្នាក់ (CHILD ACCOUNT TOP-UP) សម្រាប់បន្ថែមក្នុងគណនីកុមារ ។ បច្ចុប្បន្ននេះ គឺបានទ្រទ្រង់កុមារ ចំនួន 313 នាក់ ដែលជាកូនអតិថិជនឆ្នើម ក៏ដូចជាមិនមែនអតិថិជនឆ្នើម តាំងពីចុងឆ្នាំ 2013។ យើងអរគុណយ៉ាងខ្លាំង ដល់ការិយាល័យទាំងពីរ សម្រាប់ការជួយទ្រទ្រង់ និង ចិត្តសប្បុរសដែលពោរពេញដោយចិត្តមេត្តារបស់ពួកគេក្នុងការជួយកុមារក្រីក្រនៅកម្ពុជា ។



## 8.) ទឹកស្អាត និងអនាម័យ (WASH) និងការការពារបរិស្ថាន

ដើម្បីណែនាំ WASH ទៅកាន់គ្រួសារ និងសហគមន៍ទាំងមូល វីសិនហ្វាន់ ខេមបូឌា បានដាក់ឲ្យដំណើរការប្រាក់កម្ចីសម្រាប់ទិញបង្គន់អនាម័យ និងធុងចម្រោះទឹក ចាប់ពីឆ្នាំ2011 ដោយមានការសហការណ៍ ជាមួយអង្គការដៃគូ ដូចជា អង្គការផាស (PATH)សហគ្រាសផលិតផលសង្គម ហាដ្រូឡូជិក (HYDROLOGIC) IDE (សហគ្រាសអភិវឌ្ឍអន្តរជាតិ) WATERSHED កម្ពុជា និង HABITAT FOR HUMANITY CAMBODIA។ ដូចនេះ អតិថិជន អាចទទួលបានសម្ភារៈអនាម័យសម្រាប់ការរស់នៅប្រចាំថ្ងៃ ដើម្បីសុខភាពដែលប្រសើរឡើង និងធ្វើឲ្យពួកគេមានសុខភាពល្អក្នុងការប្រកបរបរអាជីវកម្មផ្សេងៗ ដែលអាចរកចំណូលសម្រាប់គ្រួសារ ជាពិសេសការសិក្សារបស់កុមារ។ គិតត្រឹម ខែធ្នូ ឆ្នាំ2014 យើងមាន អតិថិជនកម្ចី ចំនួន 50,476នាក់ដែលប្រើប្រាស់កម្ចីដើម្បីទិញធុងទឹកចម្រោះ និងអតិថិជនចំនួន 23,080នាក់ ដែលប្រើប្រាស់កម្ចីដើម្បីទិញបង្គន់អនាម័យ។ កម្ចីដែលផ្តល់សម្ភារៈអនាម័យគឺមិនត្រឹមតែផ្តល់ទឹកស្អាត និងអនាម័យដល់អតិថិជន

នោះទេ ថែមទាំងអាចផ្តល់ការការពារបរិស្ថាន ដោយសារអតិថិជនមិនបំផ្លាញបរិស្ថាន តាមរយៈការប្រើប្រាស់អុសសម្រាប់ចំអិនអាហារ និងប្រើប្រាស់បង្គន់អនាម័យជំនួសឲ្យការបន្ទោរបង់នៅក្នុងវាលស្រែ និងកម្ចោតព្រៃ ដោយការប្រើប្រាស់សម្ភារៈអនាម័យ ដើម្បីធានាបានថាពួកគេមានទឹកស្អាត និងអនាម័យ។ ការនេះបង្ហាញអំពីផលចំណេញសេដ្ឋកិច្ច ពីរដង លើចំណាយនៃការវិនិយោគក្នុងវិស័យអនាម័យ ស្មើរនឹងផលចំណេញ 2 ដុល្លារអាមេរិក ពីការវិនិយោគទុនក្នុងមួយដុល្លារអាមេរិក។

វីសិនហ្វាន់ ខេមបូឌា បានដាក់ឲ្យប្រើប្រាស់ផលិតផលកម្ចី សម្រាប់ការប្រើប្រាស់ឧបករណ៍ដើរដោយថាមពលពន្លឺព្រះអាទិត្យដើម្បីចូលរួមចំណែកកាត់បន្ថយ ផលប៉ះពាល់ឧស្ម័នផ្ទះកញ្ចក់ជាសកល ក៏ដូចជាលើកតម្កើងស្វ័យសិក្សារបស់កុមារនៅពេលយប់។ យើងកំពុងធ្វើការជាដៃគូជាមួយសហគ្រាសសង្គម ដូចជា ISS KAMWORKS និង សូឡាភូមិយើង (SOLAR PHUMYOEUNG) ចាប់ពីឆ្នាំ 2011។ យើងបានឃើញថា អតិថិជនមានភាពរីករាយ ដែលមានជម្រើសច្រើនក្នុងការជ្រើសរើសកម្ចី ដូចជា កម្ចីផលិតផលដើរដោយថាមពលព្រះអាទិត្យ ដែលលើកស្ទួយដល់ការប្រើប្រាស់ថាមពលកកើតឡើងវិញ។ គិតត្រឹម ខែធ្នូ ឆ្នាំ2014 យើងបានបម្រើអតិថិជនចំនួន 943 សម្រាប់កម្ចីទិញឧបករណ៍ដើរដោយថាមពលព្រះអាទិត្យក្នុងខេត្តផ្សេងៗ។



## 9.) ឱកាសទទួលបានការអប់រំសម្រាប់យុវជន

វីសិនហ្វាន់ ខេមបូឌា ផ្តល់ឱកាសមាសសម្រាប់យុវជនដើម្បីបន្តការសិក្សាកម្រិតខ្ពស់។ យើងបានចាប់ផ្តើម និងពង្រីកកម្មវិធីអប់រំ ដើម្បី ផ្តល់ឲ្យអតិថិជនដែលគ្មានលទ្ធភាពបញ្ជូនកូនៗរបស់ពួកគេទៅរៀនដល់កម្រិតខ្ពស់ និង/ឬ វគ្គបណ្តុះបណ្តាលផ្សេងៗ ដោយសារបញ្ហាការខ្វះខាតហិរញ្ញវត្ថុ។



វាផ្តល់លទ្ធភាពដល់កូនៗរបស់អតិថិជនក្នុងការបំពេញវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈកម្មវិធីបរិញ្ញាបត្រឬកម្មវិធីអនុបណ្ឌិត។ ចំនួនប្រាក់កម្ចីមានចំនួនហូតដល់ 3,000 ដុល្លារអាមេរិក និងអាចសងត្រឡប់តាមរយៈការបងរំលោះ សម្រាប់រយៈពេលរហូតដល់ 7 ឆ្នាំ។ ត្រឹមខែធ្នូ ឆ្នាំ2014 យើងបានបម្រើអតិថិជនចំនួន 790 នាក់ (ផលប័ត្រឥណទានចំនួន407.506 ដុល្លារអាមេរិក) ក្នុងគោលដៅកម្ចីសិក្សា។ អតិថិជនភាគច្រើនប្រើប្រាស់កម្ចីដើម្បីបន្តការសិក្សាកម្រិតខ្ពស់នៅសកលវិទ្យាល័យថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិត។

## 10.) ការយកចិត្តទុកដាក់សម្រាប់ គ្រួសារផ្ទុកមេរោគអេដស៍ និងគ្រួសារងាយរងគ្រោះ

អតិថិជនដែលមានផ្ទុកមេរោគអេដស៍ និងគ្រួសារដែលមានកូនកំព្រានិងពិការ គឺតែងទទួលបានការរើសអើង និងការមើលរំលងក្នុងសង្គម ហើយគ្មានឱកាសទទួលបានសេវាហិរញ្ញវត្ថុ។ វីសិនហ្វាន់ ខេមបូឌា ដើរតាមគោលដៅ របស់ព្រះ ក្នុងការបំពេញការងារជាមួយពួកគេដើម្បីធានាថា ពួកគេអាចទទួលបានសេវាហិរញ្ញវត្ថុក្នុងការដោះស្រាយឧបសគ្គនៃឱកាសការរីកចម្រើនផ្នែកសេដ្ឋកិច្ច។

យើងបានចាប់ផ្តើមចាប់ដៃគូជាមួយអង្គការកាណា (KHMER HIV/AIDS NGO ALLIANCE) ក្នុងឆ្នាំ 2007 ដើម្បីដាក់ឲ្យដំណើរការ "វិធីសាស្រ្តមីក្រូហិរញ្ញវត្ថុបែបឆ្នៃប្រឌិត" ដែលជាកិច្ចការដំបូងមួយក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាឥណទានដល់គ្រួសារដែលទទួលការប៉ះទង្គិចពីជម្ងឺអេដស៍ ឬគ្រួសារដែលមានកូនកំព្រា និងងាយរងគ្រោះនៅក្នុងខេត្តកំពង់ចាម។ បន្ទាប់មក យើងបានចាប់ផ្តើមពង្រីកគម្រោងនេះ ដោយធ្វើការសហការណ៍ជាមួយអង្គការទស្សនៈពិភពលោកកម្ពុជា នៅខេត្តផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ គិតត្រឹមខែធ្នូ ឆ្នាំ 2014 យើងមា289 អតិថិជនដែលផ្ទុកជម្ងឺអេដស៍ និងជាគ្រួសារងាយរងគ្រោះ ដែលប្រាក់កម្ចីទាំងអស់នោះ គឺផ្តោតសំខាន់លើការបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។

ការសិក្សាបានបង្ហាញថា ជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ ប្រជាជនដែលងាយទទួលរងផលប៉ះពាល់ទាំងនេអាចបង្កើនចំណូលរបស់ពួកគេ ហើយអាចទទួលការព្យាបាលជៀសផុតពីការរើសអើង និងទទួលបានសុទិដ្ឋិនិយមសម្រាប់ជីវិតរបស់ពួកគេ។



## II.) ការផ្តល់សេវាហិរញ្ញវត្ថុដើម្បីផ្តល់អំណាចដល់ស្រ្តី លើកស្ទួយសិទ្ធិកុមារ និងជួយប្រជាជនដែលស្ថិតក្នុង ស្ថានភាពពិការ និង ហេតុការណ៍គ្រោះថ្នាក់បន្ទាន់

វីសិនហ្វាន់ ខេមបូឌា បានធ្វើការតាមរយៈភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលជាច្រើនដូចជា HAGAR អន្តរជាតិនៅកម្ពុជា អង្គការពលកម្មអន្តរជាតិ (ILO) ភ្លែនអន្តរជាតិនៅកម្ពុជា (PLAN INTERNATIONAL), អង្គការ ADVENTIST DEVELOPMENT & RELIEF AGENCY (ADRA), អង្គការ ROTARY CLUB / SUSTAINABLE CAMBODIA ដើម្បីលើកកំពស់ការពង្រឹងអំណាចដល់ស្រ្តី និងសិទ្ធិកុមារក្នុងសហគមន៍ជាដើម។ ដូច្នេះ គ្រួសាររបស់ពួកគេអាចទទួលបានសេវាហិរញ្ញវត្ថុ ដែលមានតំលៃសមរម្យដើម្បីកែលម្អជីវភាពរស់នៅរបស់ពួកគេ។

ជាមួយនឹងការកើនឡើងនៃប្រាក់ចំណូលនិង ជីវភាពដែលប្រសើរឡើង ស្រ្តី និងក្រុមងាយរងគ្រោះបំផុតបានទទួលអំណាច និងការលើកទឹកចិត្តខ្ពស់ក្នុងការទ្រទ្រង់គ្រួសារ និងកូនៗរបស់ពួកគេ។ កុមារអាចទទួលបានការការពារពីការរំលោភបំពាន នៅក្នុងគ្រួសារ និងសហគមន៍។ គិតត្រឹមខែ ធ្នូ ឆ្នាំ 2014 យើងមានអតិថិជនចំនួន 7,826 នាក់ កំពុងបម្រើការនៅតាមបណ្តាខេត្តនានាសម្រាប់គោលបំណងនេះ។

ដើម្បីជួយដល់ជនពិការ ក្នុងការបង្កើតប្រាក់ចំណូលក្នុងគ្រួសារ និង ធ្វើឲ្យស្ថានភាពរស់នៅរបស់ពួកគេប្រសើរឡើង។ វីសិនហ្វាន់ បានផ្តល់ឥណទាន ដល់ក្រុមដែលងាយរងគ្រោះបំផុតទាំងនេះនៅទូទាំងប្រទេស ។ គិតត្រឹមខែធ្នូ ឆ្នាំ 2014 យើងបានបម្រើអតិថិជនចំនួន 615 នាក់ ជាមួយជនពិការគ្រប់ប្រភេទ ជាមួយផលប័ត្រឥណទានសរុបចំនួន 303,729 ដុល្លារអាមេរិក។

ស្រមៃមើលថា ប្រជាជនក្រីក្រដែលជួបបញ្ហាផ្នែកហិរញ្ញ-វត្ថុ តើពួកគេជួបប្រទះការលំបាកយ៉ាងណាខ្លះ នៅពេលដែលពួកគេមានជម្ងឺដោយចៃដន្យ គ្រោះថ្នាក់ចរាចរណ៍ គ្រោះមហន្តរាយធម្មជាតិ និងស្ថានភាពបន្ទាន់ផ្សេងៗទៀត។ ដើម្បីជួយឲ្យពួកគេជាពីជម្ងឺ និងវិលមកភាពប្រក្រតីវិញ វីសិនហ្វាន់ ខេមបូឌាបានដាក់ដំណើរការផលិតផលកម្ចីគ្រាអាសន្ននៅក្នុងសហគមន៍នានាជាមួយទំហំប្រាក់កម្ចីរហូតដល់ 250 ដុល្លារអាមេរិក

ដោយគ្មានការដាក់វត្ថុបញ្ចាំឡើយ។ ការយកចិត្តទុកដាក់

និងការគាំទ្រដល់សង្គម ត្រូវបានផ្តល់ឲ្យក្រុមអតិថិជននេះ រួមមាន ជួយរៀបចំផែនការអាជីវកម្ម និងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាថា កម្ចីរបស់យើងនឹងមិនបន្ថែមបន្ទុកហិរញ្ញវត្ថុ ឬបន្ថែមឧបសគ្គដល់អតិថិជន។

## 12.) ការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់សហករណ៍កសិកម្ម

សហករណ៍កសិកម្ម (ACS) បានដើរតួនាទីយ៉ាងសំខាន់ក្នុងសហគមន៍មូលដ្ឋានក្នុងការជំរុញការរីកចម្រើន និងសកម្មភាពសេដ្ឋកិច្ចនិងការផ្តល់សេវាផ្សេងៗដល់កសិករជាពិសេសជនក្រីក្រ ក៏ដូចជាភ្ជាប់ទំនាក់ទំនងរវាងផលិត-ករកសិដ្ឋាន ជាមួយទីផ្សារ និងអ្នកជំនួញ។ សហករកសិកម្ម (ACS)ត្រូវបានបង្កើតដោយអង្គការ និងអាជ្ញាធរស្រប



ច្បាប់ក្នុងតំបន់ និងភ្នាក់ងាររដ្ឋាភិបាល។ នៅពេលដែលពួកគេត្រូវការ ដើមទុនកាន់តែច្រើនសម្រាប់ការចាប់ផ្តើម ឬពង្រីកអាជីវកម្ម ពួកគេតែងតែជួបការលំបាកជាច្រើន។

តាមរយៈឱកាសនេះ វីសិនហ្វាន់ ខេមបូឌា បានដាក់ឲ្យប្រើប្រាស់ការសាកល្បងប្រាក់កម្ចីសម្រាប់ សហករណ៍កសិកម្ម ក្នុងតំបន់ប្រតិបត្តិការរបស់ អង្គការទស្សនៈពិភពលោកអន្តរជាតិ(កម្ពុជា) ចាប់ពីចុងឆ្នាំ 2013 ។ កម្ចីពី វីសិនហ្វាន់ ខេមបូឌា អនុញ្ញាត្តិឲ្យសហករណ៍មានដើមទុនគ្រប់គ្រាន់ដើម្បីចាប់ផ្តើម និង/ឬ ពង្រីកអាជីវកម្ម ដូចជាការទិញជីសម្រាប់ដំណាំស្រូវ បើកហាងលក់សាំង ការសាងសង់អាគារសម្រាប់ការចែកចាយផលិតផលកសិកម្ម។ គិតត្រឹម ខែធ្នូ ឆ្នាំ 2014 វីសិនហ្វាន់ ខេមបូឌាបានផ្តល់ឥណទានសម្រាប់សហករណ៍ចំនួន 24 សហករណ៍កសិកម្មនៅតាមបណ្តាខេត្តនានា។

## 13.) គម្រោងសំណាញ់សុវត្ថិភាពសម្រាប់ជនក្រីក្រ

អតិថិជនរបស់យើង មានភាពរីករាយជាមួយសំណាញ់សុវត្ថិភាពលើផលិតផលហិរញ្ញវត្ថុ ដែលពួកគេ និងសមាជិកគ្រួសារ មានសិទ្ធិទទួលបានការការពារលើឥណទានជាមួយនឹងប្រាក់ចូលរួមបុណ្យសពនៅពេលអតិថិជនទទួលមរណភាព។ គិតត្រឹមខែ ធ្នូ ឆ្នាំ 2014 អតិថិជនចំនួន 226,954 នាក់ បានទទួលផលប្រយោជន៍ ដែលត្រូវបានប្រើប្រាស់ទៅលើការបង់សងបំណុលថ្លៃចំណាយលើបុណ្យសព ដែលអាចកាត់បន្ថយបន្ទុកហិរញ្ញវត្ថុរបស់អតិថិជនក្រីក្រ និងក្រុមគ្រួសាររបស់ពួកគេ។ វីសិនហ្វាន់ បានសាកល្បង និងបានធ្វើមាត្រដ្ឋានឡើងដើម្បីធានារ៉ាប់រងខ្នាតតូច និង សុខភាពរបស់ជនពិការដោយសហការជាមួយ PKMI មាន (ក្រុមហ៊ុន PREVOIR កម្ពុជា MICROLIFE ការធានារ៉ាប់រង) ក្រុមហ៊ុនធានារ៉ាប់រងលើបុត្រសម្ព័ន្ធមួយរបស់ប្រទេសបារាំងដើម្បីផ្តល់ជូននូវសេវាកម្មនេះចាប់តាំងពីចុងឆ្នាំ 2012 អតិថិជនអាចទិញវាបាន នៅក្នុងការចំណាយទាបក្នុងមួយឆ្នាំ ហើយទទួលបានការធានារ៉ាប់រង ការព្យាបាលដោយការវះកាត់ខ្នាតតូច និងការព្យាបាលដែលទាក់ទង នឹងគ្រោះថ្នាក់ផ្សេងទៀត។ចំពោះការបន្ថែមទៀតថាតម្លៃកាន់តែច្រើន, ឥឡូវនេះអតិថិជនក៏អាចទិញវាសម្រាប់សមា-ជិករបស់ខ្លួនក្នុងគ្រួសារនិងឬ / កុមារអាស្រ័យលើលទ្ធភាពរបស់ពួកគេ។ កាលពីខែធ្នូឆ្នាំ 2014យើងបានអតិថិជន 6,564 នាក់ដែលត្រូវបានគ្របដោយកញ្ចប់ធានារ៉ាប់រងនេះ។

## 14.) ការអប់រំ សុខភាពកម្រិតមូលដ្ឋាន

នៅតាមតំបន់ជនបទ ដែលអនាម័យនៅតែជាបញ្ហាដ៏ធំមួយសម្រាប់អ្នកភូមិ និងកូនៗរបស់ពួកគេ។ អង្គការក្រៅរដ្ឋាភិបាល មានសកម្មភាពយ៉ាងសកម្មនៅក្នុងតំបន់ជនបទ ដើម្បីលើកកម្ពស់អនាម័យផ្ទាល់ខ្លួន និងការបរិភោគទឹកស្អាត។ វីសិនហ្វាន់ ខេមបូឌា បានចូលរួមជាមួយនឹង អង្គការទស្សនៈពិភពលោក នៅក្នុងដំណើរការនេះដើម្បីធានាបានថា អតិថិជនរបស់យើងអាចទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលការថែទាំសុខភាពជាមូលដ្ឋាន។ យើងជឿជាក់ថានៅពេលដែលអតិថិជនអាចរក្សាសុខភាពបានល្អ នឹងរួចផុតពីជម្ងឺ ពួកគេអាចមានផលិតភាពខ្ពស់ក្នុងការរកប្រាក់ចំណូលគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ដល់ក្រុមគ្រួសារនិងកូនៗរបស់ពួកគេ។

វីសិនហ្វាន់ ខេមបូឌា បានចាប់ផ្តើម និងពង្រីកការអប់រំផ្នែកសុខភាពជាមួយនឹងការសហការដ៏ជិតស្និទជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )។ ដូច្នេះ ក្នុងកំឡុងពេលផ្តល់វគ្គបណ្តុះបណ្តាលសុខភាពដែលបង្រៀនដោយបុគ្គលិកអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា )អតិថិជនរបស់យើងត្រូវបានលើកទឹកចិត្តឲ្យចូលរួម ដើម្បីឲ្យពួកគេបានរៀនអំពីការអប់រំលើសុខភាពផ្សេងៗដូចជា ការលាងដៃអនាម័យផ្ទាល់ខ្លួន ការចំអិនអាហារដែលមានសារជាតិចិញ្ចឹម ជម្ងឺរាគរូស និងជម្ងឺផ្តាសសាយ ជាដើម។ គិតត្រឹមខែធ្នូ ឆ្នាំ 2014 អតិថិជនប្រហែល 5000នាក់បានចូលរួមការបណ្តុះបណ្តាលសុខភាពដ៏សំខាន់នេះ ដែលបង្រៀនដោយបុគ្គលិកអង្គការទស្សនៈពិភពលោកអន្តរជាតិ( កម្ពុជា ) ជាមួយនឹងជំនួយបច្ចេកទេសពីបុគ្គលិកដែលមកពីមជ្ឈមណ្ឌលសុខភាព។ ដូចនេះអតិថិជនទាំងនោះចាប់ផ្តើមយកចិត្តទុកដាក់អំពីការថែរក្សាសុខភាពរបស់ពួកគេ និងថែមទាំងអាចមើលថែសមាជិកគ្រួសាររបស់ពួកគេ ជាពិសេសកុមារបានល្អទៀតផង។





## ពន វណ្ណារី
## អតិថិជនជោគជ័យរបស់ វីសិនហ្វាន់ ខេត្តព្រៃវែង

អ្នកមីងពន វណ្ណារី គឺជាស្ត្រីមេម៉ាយ ដែលមានកូន 4នាក់ ហើយរស់នៅក្នុង ភូមិបារាំយខាងលិច ខេត្តព្រៃវែង។ អ្នកមីង អាចរកចំណូលបានច្រើនជាងមុន ពីការធ្វើស្រែ ដែលមានទំហំ 70A។

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ 2014

## វីសិនហ្វាន់ ផ្តល់សៀវភៅសរសេរ ប្រាំមួយម៉ឺនក្បាល ដល់សិស្សានុសិស្សទូទាំងប្រទេស

វីសិនហ្វាន់ បានបោះពុម្ពសៀវភៅសរសេរចំនួនប្រាំមួយម៉ឺនក្បាល ដើម្បីចែកជូនសិស្សនៅតាមបណ្តាសាលាបឋមសិក្សា និងអនុវិទ្យាល័យនានា ដោយបានបញ្ចូលសារអប់រំសំខាន់ៗ ដូចជា សារៈសំខាន់នៃការសន្សំប្រាក់ពិសេសការសន្សំដើម្បីអនាគតកូនៗ ជៀសឲ្យឆ្ងាយពីគ្រឿងញៀន និងសុវត្ថិភាពចរាចរដោយការពាក់មួកសុវត្ថិភាព។



សកម្មភាពបុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ប្រគល់សៀវភៅសរសេរដល់សិស្សានុសិស្ស





សារអប់រំខ្លីៗ ដែលបានភ្ជាប់ជាមួយសៀវភៅសរសេររបស់ វីសិនហ្វាន់

## សកម្មភាពពិព័រណ៍ស្តង់ វីសិនហ្វាន់ ក្នុងកម្មវិធីប្រណាំងទូក ខេត្តបាត់ដំបង

វីសិនហ្វាន់ បានចូលរួមក្នុងពិធីបុណ្យប្រណាំងទូក ដែលរៀបចំឡើងនៅទីរួមខេត្តបាត់ដំបង កាលពីថ្ងៃ 06 ដល់ថ្ងៃទី 08 ខែតុលា ឆ្នាំ2014។ ក្នុងរយៈពេលទាំងបីថ្ងៃនេះ មានកម្មវិធីកំសាន្តជាច្រើន និងមានការចូលរួមយ៉ាងច្រើនកុះករពីសាធារណជន ហើយវីសិនហ្វាន់ក៏បានចូលរួមធ្វើការដាក់តាំងពិពណ៌បង្ហាញពីសេវារបស់យើង ហើយនឹងមានការផ្តល់ជារង្វាន់ផ្សេងៗ ដល់អ្នកដែលបានចូលរួមលេងល្បែងជាមួយនឹងយើងផងដែរ។



សកម្មភាពបុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ប្រគល់រង្វាន់ដល់អ្នកឈ្នះ

# កម្មវិធី PROMOTION របស់ វីសិនហ្វាន់ ក្នុងរដូវកាលបុណ្យណូអែល

កាលពី ថ្ងៃទី15 ខែ ធ្នូ ឆ្នាំ 2014 វីសិនហ្វាន់ បានរៀបចំកម្មវីធី PROMOTION ពិសេស សម្រាប់អតិថិជនរបស់ខ្លួននៅការិយាល័យកណ្តាល និងបណ្តាសាខាខេត្តទាំង 17។ អតិថិជន ដែលបើកគណនីសន្សំជាមួយ វីសិនហ្វាន់ នឹងទទួលបានវត្ថុអនុស្សាវរីយ៍ដ៏ស្រស់ស្អាតភ្លាមៗ ចំណែកឯអតិថិជន ដែលមកកាន់ ការិយាល័យ វីសិនហ្វាន់ ដែលមានប័ណ្ណCOUPON អាចបង្វិលកងដើម្បីឈ្នះរង្វាន់ពី វីសិនហ្វាន់។



កម្មវិធី PROMOTION របស់ វីសិនហ្វាន់ ក្នុងរដូវកាលបុណ្យណូអែល



រូបភាពបុគ្គលិក វីសិនហ្វាន់ និងអតិថិជនក្នុងកម្មវិធី *Promotion* នារដូវកាលបុណ្យណូអែល


សកម្មភាព *Promotion* នារដូវកាលបុណ្យណូអែល

# សិក្ខាសិលាតម្រង់ទិសសិក្សា "សុបិនខ្ញុំ" នៅខេត្តបាត់ដំបង



សកម្មភាពក្នុងកម្មវិធី "សុបិនខ្ញុំ"

ដើម្បីចូលរួមចំណែកលើកស្ទួយដល់វិស័យអប់រំ និងចំណេះដឹងសម្រាប់ យុវជន វីសិនហ្វាន់ បានរៀបចំសិក្ខាសិក្ខាលាតម្រង់ទិសសិក្សាក្រោមប្រធានបទ "សុបិនខ្ញុំ" នៅក្នុងបរិវេណអនុវិទ្យាល័យអនុវត្តន៍ ខេត្តបាត់ដំបង។ សិក្ខាសិលានេះបានរៀបចំឡើងដើម្បីជួយដល់កុមារ និងយុវជនឲ្យមានជីវិតប្រសើរឡើង និងផ្ដល់ឱកាសឲ្យកុមារទទួលបានការអប់រំប្រកបដោយគុណភាព និងវិធីសាស្ត្រដ៏ត្រឹមត្រូវ។ កុមារគ្រប់រូបរមែងមានក្ដីសុបិនរៀងៗខ្លួន ការគាំទ្រតែម្ខាងពីឪពុកម្ដាយមិនគ្រប់គ្រាន់ទេ យុវជនត្រូវមានការស្មារតីនិងឆន្ទៈក្នុងការតស៊ូសម្រាប់ជីវិត។ វីសិនហ្វាន់ ក៏បានប្រគល់សៀវភៅសរសេរសរុបចំនួន 3,000ក្បាល ដល់សិស្សានុសិ្សតដោយផ្ទាល់ ហើយយើងក៏បានឧបត្ថម្ភថវិការ ដើម្បីជួសជុលអគារថ្នាក់រៀនជូនដល់អនុវិទ្យាល័យអនុវត្តន៍ ខេត្តបាត់ដំបង។




រូបថតជុំគ្នា ឯកឧត្ដម ច័ន្ទ សុផល អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងអគ្គនាយិការប្រតិបត្តិការ វីសិនហ្វាន់ ក្នុងសិក្ខាសាលា "សុបិនខ្ញុំ"

# វីសិនហ្វាន់ ចាប់ដៃគូជាមួយ វិទ្យាស្ថានសិក្សាដើម្បីជោគជ័យ

ពិធីចុះហត្ថលេខា លើអនុសារណៈយោគយល់គ្នាមួយរវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ និងវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ត្រូវបានប្រារព្ធធ្វើឡើង នាថ្ងៃទី 27 ខែតុលាឆ្នាំ2014 នៅក្នុងបរិវេណវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ ក្នុងគោលបំណងរួមគ្នាគាំទ្រដល់ការសិក្សារបស់យុវជនកម្ពុជា។



ពិធីចុះហត្ថលេខារវាង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ និងវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ




រូបថតជុំគ្នារវាងបុគ្គលិក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ និងវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ

# វីសិនហ្វាន់ លើកកម្ពស់ការសិក្សារបស់កុមារនៅតាមសហគមន៍

វីសិនហ្វាន់ តែងតែយកចិត្តទុកដាក់លើចន្លោះខ្វះខាតនៃការអប់រំរបស់កុមារ និងយុវជនក្នុងសហគមន៍ក្រីក្រ។ ឆ្នាំនេះ វីសិនហ្វាន់ បានផ្តល់អាហារូបករណ៍ជាច្រើនតាមរូបភាពខុសៗគ្នាដើម្បីទ្រទង់ការសិក្សា។ អាហារូបករណ៍មានដូចជា អាហារូបករណ៍សម្រាប់ការសិក្សាដល់ថ្នាក់ទី 12 ដល់កូនរបស់អតិថិជនឆ្នើម អាហារូបករណ៍បីឆ្នាំដល់កុមារក្រីក្រ និងអាហារូបករណ៍សម្រាប់សិស្សដែលគ្មានថវិកាក្នុងការបន្តថ្នាក់មហាវិទ្យាល័យ។

ជារៀងរាល់ឆ្នាំ វីសិនហ្វាន់ តែងតែបន្តចូលរួមចំណែកក្នុងការលើកកំពស់ការសិក្សារបស់កុមារ និងយុវជនក្រីក្រតាមរយៈការផ្តល់ដើមទុនសិក្សាដល់ពួកគេ ក៏ដូចជាផ្តល់កម្ចីសិក្សាដែលមានការប្រាក់សមរម្យ ។




មិថុនា និយាយទាំងត្រេកអរថា "បើគ្មានអាហារូបករណ៍វីសិនហ្វាន់ ខ្ញុំក៏មិនអាចបន្តការសិក្សានៅភ្នំពេញបានដែរ"។

ប្អូនប្រុស ភឿន មិថុនា អាយុ 18ឆ្នាំ ជានិស្សិតឆ្នាំទី1 ជំនាញធនាគារ នៅសាកលវិទ្យាល័យមេគង្គកម្ពុជា។ មិថុនា មកពីខេត្តកណ្តាល ដែលមានបងប្អូន6នាក់នៅក្នុងគ្រួសារ។ មិថុនារស់នៅក្នុងគ្រួសារដែលមានជីវភាពលំបាកនិងខ្វះខាត។ មិថុនាបានបន្តថា បងស្រីរបស់ប្អូនមិនបានរៀនបន្តព្រោះឪពុកម្តាយគ្មានលទ្ធភាពបង់ថ្លៃសិក្សា និងត្រូវធ្វើការរោងចក្របន្ទាប់ពីរៀនចប់។សម្រាប់មិថុនា អាហារូបករណ៍វីសិនហ្វាន់ មានសារៈសំខាន់ណាស់ ព្រោះនេះជា ឱកាសតែមួយគត់សម្រាប់បន្តការសិក្សាដោយមិនបង់ថ្លៃនៅថ្នាក់បរិញ្ញាប័ត្រ បើមិនដូច្នោះទេ ប្អូនប្រុសមិថុនានឹងត្រូវទៅធ្វើការរោងចក្របន្ទាប់ពីរៀនចប់ដូចបងស្រីរបស់ខ្លួនជាមិនខាន។



កុមារអាយុ 12 ឆ្នាំ ឈ្មោះ សឹម សុភក្រ្ត័ គឺជាកូនប្រុស របស់អតិថិជនផ្ញើម វីសិនហ្វាន់។ សុភក្រ្ត័ ទទួលបានការ ឧបត្ថម្ភសម្រាប់ការសិក្សារហូតដល់ថ្នាក់ទី12។

សុភក្រ្ត័ បានប្រាប់យើងថា ប្អូនមានចិត្តសប្បាយរីករាយប្អូន អាចទៅសាលារៀនបានដោយសេរី ដោយមិនដាក់បន្ទុក ទៅលើម្តាយរបស់ប្អូន។ ប្អូនមានកងថ្មីមួយសម្រាប់ជិះទៅ សាលារៀន មានសម្ភារៈសិក្សាល្អ និងឯកសណ្ឋានសិក្សាថ្មី ជារៀងរាល់ឆ្នាំ។



កុមារី អាយុ 13 ឆ្នាំ ឈ្មោះ លាង ចាន់ណា គឺ ជាកូនស្រី របស់អតិថិជនផ្ញើម វីសិនហ្វាន់។

ចាន់ ណា ទទួលបានអាហារូបករណ៍ វីសិនហ្វាន់ ទ្រទ្រង់ការសិក្សា រហូតដល់បញ្ចប់ថ្នាក់ទី 12 ឥឡូវនេះ ចាន់ ណា មានសម្ភារៈសិក្សាគ្រប់គ្រាន់ ដែល ចាន់ ណា ត្រូវការ ដូចជា ឯកសណ្ឋានសាលា និងប្រាក់សន្សំមួយចំនួន សម្រាប់បន្តការសិក្សានាពេលអនាគត ។



កុមារា អាយុ 12 ឆ្នាំ ឈ្មោះ ចាន់ ធីន គឺជាកូនទី5 របស់ អតិថិជនវីសិនហ្វាន់ ឈ្មោះ ចាន់ ធី គឺកំពុងត្រៀមខ្លួនចូល រៀនថ្នាក់ទី6 នាឆ្នាំក្រោយនេះ។

ចាន់ ធីន បាននិយាយថា “ខ្ញុំដើរទៅសាលា ហើយមិត្ត របស់ខ្ញុំជិះកង់ទៅសាលារៀន។ ឥឡូវ ខ្ញុំមានកង់ថ្មីមួយ ជិះទៅសាលារៀនដូចពួកគេដែរ”។

# ទិន្នន័យស្តីពីបរិស្ថាន និងទិន្នន័យបុគ្គលិក

| | 2014 | 2013 | 2012 |
|---|---|---|---|
| **សូចនាករទៅលើសកម្មភាពបរិស្ថាន** | | | |
| សម្ភារៈ | | | |
| ក្រដាស គិតជា គ.ក/FTE[9] | 34.55 | 36.31 | 28.84 |
| ទម្រង់ប្រាក់កម្ចី គិតជា គ.ក/FTE | 20.91 | 20.98 | 13.92 |
| ក្រដាសប្រើប្រាស់ក្នុងការិយាល័យ គិតជា គ.ក/FTE | 13.65 | 15.34 | 14.92 |
| កាកសំណល់ | | | |
| ក្រដាសដែលលែងប្រើប្រាស់ គិតជា គ.ក/FTE | 1.24 | 1.74 | 1.37 |
| ថាមពល | | | |
| ថាមពល គិតជា គីឡូវ៉ាត់/FTE | 420.43 | 412.20 | 480.36 |
| ប្រេងឥន្ធនៈ គិតជាលីត្រ/FTE | 238.62 | 251.63 | 267.26 |
| ប្រេងម៉ាស៊ូត គិតជាលីត្រ/FTE | 50.10 | 63.43 | 65.55 |
| ការបញ្ចេញសារធាតុពុលនៃកាបូនឌីអុកស៊ីត (គិតជា មួយពាន់គីឡូក្រាម)[២] | | | |
| ភ្លើងអគ្គិសនី | 256.44 | 207.67 | 206.34 |
| ប្រេងឥន្ធនៈ | 635.12 | 553.17 | 500.95 |
| ប្រេងម៉ាស៊ូត | 152.80 | 159.79 | 140.79 |
| ទឹក | | | |
| ទឹក គិតជាម៉ែត្រគូប/FTE | 23.14 | 23.48 | 26.08 |
| ការចុះបេសកកម្ម | | | |
| តាមរយៈយានយន្ត គិតជាគីឡូម៉ែត្រ/FTE | 568.94 | 655.53 | 644.44 |
| តាមរយៈទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ/FTE | 8,900.54 | 9,491.58 | 9,964.97 |
| | | | |
| **សូចនាករបុគ្គលិក** | | | |
| ភាពមានការងារធ្វើ | | | |
| ចំនួនបុគ្គលិក | 1145 | 967 | 820 |
| ស្ត្រី | 373 | 306 | 271 |
| បុរស | 772 | 661 | 549 |
| ចំនួនបុគ្គលិកសរុប (FTE) | 1109 | 916 | 781 |
| ការបណ្តុះបណ្តាល និងការអប់រំ | | | |
| ការបណ្តុះបណ្តាល - ការអភិវឌ្ឍសមត្ថភាពបុគ្គលិក ព្រមទាំងកម្មវិធីរំលឹកការសិក្សា | 10,133 | 9782 | 6384 |
| បណ្តុះបណ្តាលបុគ្គលិកថ្មី - កម្មវិធីណែនាំ | 308 | 220 | 317 |
| ផ្តល់ការចុះកម្មសិក្សាដល់និស្សិតក្នុងស្រុក | 53 | 80 | 61 |

[៩] FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុង១ឆ្នាំ

[២] សមមូលឧស្ម័នកាបូនិកត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol ។

# តំបន់ប្រតិបត្តិការ

បច្ចុប្បន្ន វីសិនហ្វាន់ បានផ្ដល់សេវាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ទៅដល់ប្រជាជនដែលមានចំណូលទាបនៅទូទាំងខេត្ត និងរាជធានី ។



# ព័ត៌មានហិរញ្ញវត្ថុ

## ភាពរឹងប៉ឹងផ្នែកហិរញ្ញវត្ថុរបស់ វីសិនហ្វាន់ បានធ្វើឲ្យវីសិនហ្វាន់ អាចរក្សាតំណែងល្អ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលល្បីៗ ។

សម្រាប់ឆ្នាំ 2014 នេះ ប្រាក់ចំណេញទទួលបានគឺ 2.58 លានដុល្លារអាមេរិកសរុបទ្រព្យសកម្ម មានចំនួនប្រមាណជា 106 លានដុល្លារអាមេរិក និងសរុបមូលធនប្រមាណជា 21.69 លានដុល្លារអាមេរិក ជាមួយនិងនិរន្តរភាពហិរញ្ញវត្ថុ 107% ហើយនិរន្តភាពប្រតិបត្តិការ 114% ។



# និន្នាការកំណើន

## ចំនួនអតិថិជនសកម្ម
## ពីខែធ្នូ ឆ្នាំ 2009 ដល់ ខែធ្នូ ឆ្នាំ 2014




## ផលប័ត្រឥណទាន
## ពីខែធ្នូ ឆ្នាំ 2009 ដល់ ខែធ្នូ ឆ្នាំ 2014



## ចំនួនអតិថិជនបញ្ញើសន្សំ
## ពីខែធ្នូ ឆ្នាំ 2011 ដល់ ខែធ្នូ ឆ្នាំ 2014




## សមតុល្យប្រាក់បញ្ញើសន្សំ
## ពីខែធ្នូ ឆ្នាំ 2011 ដល់ ខែធ្នូ ឆ្នាំ 2014




## សរុបទ្រព្យសកម្ម
## ពីខែធ្នូ ឆ្នាំ 2009 ដល់ ខែធ្នូ ឆ្នាំ 2014



## ចំនួនបុគ្គលិក
## ពីខែធ្នូ ឆ្នាំ 2009 ដល់ ខែធ្នូ ឆ្នាំ 2014




## អនុបាតនិរន្តរភាពប្រតិបត្តិការ
## ពីខែធ្នូ ឆ្នាំ 2009 ដល់ ខែធ្នូ ឆ្នាំ 2014



# របាយការណ៍របស់សវនករឯករាជ្យ

## ( ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ 2014 ដែលបានធ្វើសវនកម្មរួច )

### ជូនចំពោះភាគទុនិក
### វីសិនហ្វាន់ ( ខេមបូឌា ) អិលធីឌី

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី ហៅ កាត់ថា ("ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 និងរបាយការណ៍លទ្ធផលរបាយការណ៍ស្តីពីបម្រែបម្រួល មូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមានសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័របន្ទាប់ ។

### ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃ កម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

### ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំគឺការបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃ កម្ពុជា ។ ស្តង់ដារទាំងនោះ តម្រូវឱ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការនៃក្រមសីលធម៌ និងគ្រោង និងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុពុំមានការបង្ហាញខុសជាសារវន្តឡើយ ។
ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានីតិវិធីត្រួតពិនិត្យដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទង ទៅនឹងចំនួនទឹកប្រាក់ និងការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធី ទាំងនេះ គឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យដែលមាន ផលប៉ះពាល់ដល់ការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ បណ្តាលមកពីការក្លែងបន្លំ ឬកំហុស ឆ្គង ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធ្វើសវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិទៅ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។ ការធ្វើសវនកម្មក៏រួមមានការវាយតម្លៃទៅ លើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការ បង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។
យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

### មតិសវនកម្ម

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនវីសិនហ្វាន់ (ខេមបូឌា) អិលធីឌី នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់




រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 30 ខែ មីនា ឆ្នាំ 2015

# តារាងតុល្យការ
# នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2014 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លាអាមេរិក (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) | ពាន់រៀល | ដុល្លាអាមេរិក (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | 2,043,900 | 501,571 | 929,817 | 232,745 |
| ប្រាក់បញ្ញើនៅធនាគារនានា | 37,613,636 | 9,230,340 | 27,563,895 | 6,899,598 |
| ឥណទានផ្តល់ដល់អតិថិជនសុទ្ធ | 367,247,955 | 90,122,198 | 244,394,289 | 61,175,041 |
| គណនីត្រូវទទួលផ្សេងៗ | 7,699,009 | 1,889,326 | 6,801,361 | 1,702,467 |
| គណនីត្រូវទទួលពីសម្ព័ន្ធញាតិ | 8,295 | 2,036 | 9,680 | 2,423 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 8,936,001 | 2,192,884 | 5,438,044 | 1,361,213 |
| ការវិនិយោគ | 62,563 | 15,353 | 61,336 | 15,353 |
| ទ្រព្យ និងបរិក្ខារ | 4,993,269 | 1,225,342 | 3,714,950 | 929,900 |
| ទ្រព្យសកម្មអរូបិយ | 2,227,633 | 546,659 | 2,583,542 | 646,694 |
| ទ្រព្យសកម្មជាពន្ធពន្យាសុទ្ធ | 639,437 | 156,917 | 398,346 | 99,711 |
| សរុបទ្រព្យសកម្ម | 431,471,698 | 105,882,626 | 291,895,260 | 73,065,145 |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 60,043,629 | 14,734,633 | 19,203,476 | 4,806,878 |
| គណនីត្រូវទូទាត់ឱ្យសម្ព័ន្ធញាតិ | 47,608,145 | 11,682,980 | 43,976,917 | 11,007,989 |
| បំណុលផ្សេងៗ | 14,387,407 | 3,530,653 | 9,834,873 | 2,461,795 |
| សំវិធានធនសំរាប់ពន្ធលើប្រាក់ចំណេញ | 2,264,896 | 555,803 | 2,007,759 | 502,568 |
| ប្រាក់កម្ចី | 218,752,374 | 53,681,564 | 142,983,763 | 35,790,679 |
| **សរុបបំណុល** | 343,056,451 | 84,185,633 | 218,006,788 | 54,569,909 |
| **មូលធន** | | | | |
| ដើមទុន | 40,362,700 | 9,904,957 | 40,362,700 | 10,103,304 |
| ដើមទុនបន្ថែម | 4,002,700 | 982,258 | | |
| ប្រាក់ចំណេញរក្សាទុក | 44,049,847 | 10,809,778 | 33,525,772 | 8,391,932 |
| សរុបមូលធន | 88,415,247 | 21,696,993 | 73,888,472 | 18,495,236 |
| សរុបបំណុល និងមូលធន | 431,471,698 | 105,882,626 | 291,895,260 | 73,065,145 |

# របាយការណ៍លទ្ធផល
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2014 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2013 | |
|---|---|---|---|---|
| | ពាន់រៀល (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) | ដុល្លាអាមេរិក | ពាន់រៀល (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) | ដុល្លាអាមេរិក |
| ចំណូលពីការប្រាក់ | 85,284,906 | 20,928,811 | 63,727,969 | 15,951,932 |
| ចំណាយលើការប្រាក់ | (20,986,934) | (5,150,168) | (14,863,482) | (3,720,521) |
| ចំណូលពីការប្រាក់សុទ្ធ | 64,297,972 | 15,778,643 | 48,864,487 | 12,231,411 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 1,269,736 | 311,592 | 1,438,357 | 360,039 |
| ចំណូលប្រតិបត្តិការ | 65,567,708 | 16,090,235 | 50,302,844 | 12,591,450 |
| សំវិធានធនសម្រាប់គណនីទានអាក្រក់ និងជាប់សង្ស័យ | (2,207,352) | (541,681) | (1,166,929) | (292,097) |
| ចំណាយប្រតិបត្តិការ និងចំណាយផ្សេងៗ | (50,056,537) | (12,283,813) | (35,943,778) | (8,997,191) |
| ចំណេញពីប្រតិបត្តិការ | 13,303,819 | 3,264,741 | 13,192,137 | 3,302,162 |
| ប្រាក់ជំនួយ | 20,806 | 5,106 | 119,850 | 30,000 |
| ចំណេញមុនដកពន្ធ | 13,324,625 | 3,269,847 | 13,311,987 | 3,332,162 |
| ពន្ធលើប្រាក់ចំណេញ | (2,800,550) | (687,252) | (2,762,697) | (691,539) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 10,524,075 | 2,582,595 | 10,549,290 | 2,640,623 |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | ដើមទុន ពាន់រៀល | ដើមទុន បន្ថែម | ប្រាក់ចំណេញ រក្សាទុក ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|
| សមតុល្យ ថ្ងៃទី 1 ខែ មករា ឆ្នាំ 2013 | 40,362,700 | - | 22,976,482 | 63,339,182 |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 10,549,290 | 10,549,290 |
| សមតុល្យ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 | 40,362,700 | - | 33,525,772 | 73,888,472 |
| ( សមតុល្យជាដុល្លារអាមេរិក - កំណត់សំគាល់ទី 4 ) | 10,103,304 | - | 8,391,932 | 18,495,236 |
| សមតុល្យ ថ្ងៃទី 1 ខែ មករា ឆ្នាំ 2014 | 40,362,700 | - | 33,525,772 | 73,888,472 |
| ការផ្ទេរពីប្រាក់កម្ចី | - | 4,002,700 | - | 4,002,700 |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 10,524,075 | 10,524,075 |
| សមតុល្យ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 | 40,362,700 | 4,002,700 | 44,049,847 | 88,415,247 |
| ( សមតុល្យជាដុល្លារអាមេរិក - កំណត់សំគាល់ទី 4 ) | 9,904,957 | 982,258 | 10,809,778 | 21,696,993 |

( តាមអត្រាប្តូរប្រាក់ចុងឆ្នាំ )

# របាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2014 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2013 | |
|---|---|---|---|---|
| | ពាន់រៀល (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) | ដុល្លាអាមេរិក | ពាន់រៀល (តាមអត្រាប្តូរប្រាក់នៅចុងឆ្នាំ) | ដុល្លាអាមេរិក |
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (66,786,544) | (16,389,335) | (30,991,511) | (7,757,574) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខា | (2,081,016) | (510,679) | (1,808,718) | (452,745) |
| ការទិញទ្រព្យសកម្មអរូបិយ | (508,267) | (124,728) | (1,703,279) | (426,353) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខា | - | - | 27,695 | 6,932 |
| ការវិនិយោគ | (1,227) | (301) | - | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (2,590,510) | (635,708) | (3,484,302) | (872,166) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីសម្ព័ន្ធញាតិ | 33,250,873 | 8,159,723 | 35,054,045 | 8,774,479 |
| ការទូទាត់សងសម្ព័ន្ធញាតិ | (26,748,578) | (6,564,068) | (21,886,542) | (5,478,484) |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 104,015,165 | 25,525,194 | 68,763,317 | 17,212,345 |
| ការទូទាត់សងប្រាក់កម្ចី | (30,445,082) | (7,471,186) | (36,455,605) | (9,125,308) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 80,072,378 | 19,649,663 | 45,475,215 | 11,383,032 |
| កើនឡើងសុទ្ធ/(ការថយចុះ)នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | 10,695,324 | 2,624,620 | 10,999,402 | 2,753,292 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | 25,697,212 | 6,306,064 | 14,697,810 | 3,679,051 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ | 36,392,536 | 8,930,684 | 25,697,212 | 6,432,343 |



# បណ្ដាញវើសិនហ្វាន់អន្តរជាតិ

## អាមេរិកឡាទីន និងការ៉ាប៊ីន

បូលីវី
សាធារណរដ្ឋ ដូមីនីកែន
សាធារណរដ្ឋអេក្វាឌ័រ
អែលសាល់វ៉ាឌ័រ
ហ្គាតេម៉ាឡា
ហុងឌូរ៉ាស់
មិកស៊ិក
នីការ៉ាហ្គ័រ
ប៉េរូ

ផលប័ត្រឥណទានក្នុងតំបន់សរុប : 99,151,247 ដុល្លារអាមេរិក
ចំនួនអតិថិជនសរុប : 161,741
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់កុមារសរុបចំនួន : 372,821
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់ការងារសរុបចំនួន : 221,631
ចំនួនអតិថិជនជាស្ត្រីគិតជាភាគរយសរុបចំនួន : 71%
ចំនួនអតិថិជននៅក្នុង ADPs គិតជាភាគរយសរុបចំនួន : 66%

## អាហ្វ្រិក

អេត្យូ
ហ្គាណា
កេនយ៉ា
ម៉ាឡាវី
ម៉ាលី
រវ៉ាន់ដា
សេណេហ្គាល់
តង់ហ្សានី
អ៊ូហ្គង់ដា
ហ្សំប៊ី

ផលប័ត្រឥណទានក្នុងតំបន់សរុប : 52,004,718 ដុល្លារអាមេរិក
ចំនួនអតិថិជនសរុប : 235,697
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់កុមារសរុបចំនួន : 1,291,137
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់ការងារសរុបចំនួន : 292,373
ចំនួនអតិថិជនជាស្ត្រីគិតជាភាគរយសរុបចំនួន : 62%
ចំនួនអតិថិជននៅក្នុង ADPs គិតជាភាគរយសរុបចំនួន : 65%




## អឺរ៉ុបកណ្ដាល និងអឺរ៉ុបខាងកើត

- អាល់បានី
- អាមេនី
- អាហ្សែបៃសង់
- ហ្សកហ្ស៊ី
- កូសូវ៉ូ
- ស៊ែប៊ី
- ម៉ុងតេណេហ្គ្រូ

ផលប័ត្រឥណទានក្នុងតំបន់សរុប : 341,932,652 ដុល្លារអាមេរិក
ចំនួនអតិថិជនសរុប : 315,555
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់កុមារសរុបចំនួន : 550,611
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់ការងារសរុបចំនួន : 319,783
ចំនួនអតិថិជនជាស្ត្រីគិតជាភាគរយសរុបចំនួន : 41%
ចំនួនអតិថិជននៅក្នុង ADPs គិតជាភាគរយសរុបចំនួន : 88%

## អាស៊ីប៉ាស៊ីហ្វិក

- កម្ពុជា
- ឥណ្ឌា
- ម៉ុងហ្គោលី
- ភូមា
- ហ្វីលីពីន
- ស្រីលង្កា
- វៀតណាម

ផលប័ត្រឥណទានក្នុងតំបន់សរុប : 112,927,537 ដុល្លារអាមេរិក
ចំនួនអតិថិជនសរុប : 387,225
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់កុមារសរុបចំនួន : 1,121,892
ផ្ដល់ផលប៉ះពាល់ជាវិជ្ជមានដល់ការងារសរុបចំនួន : 1,534,481
ចំនួនអតិថិជនជាស្ត្រីគិតជាភាគរយសរុបចំនួន :92%
ចំនួនអតិថិជននៅក្នុង ADPs គិតជាភាគរយសរុបចំនួន : 86%

*តួលេខនៃផលប័ត្រឥណទានសរុប និងចំនួនអតិថិជនសរុប ត្រូវបានដកស្រង់ចេញពីគេហទំព័រ វីសិនហ្វាន់អន្តរជាតិ គិតត្រឹម ថ្ងៃទី31 ខែធ្នូ ឆ្នាំ 2014 សូមទៅកាន់ គេហទំព័រ www.visionfund.org*

រចនា និងថតរូបដោយ ផ្នែកផលិតសម្ភារៈផ្សព្វផ្សាយ វីសិនហ្វាន់ ©2014

របាយការណ៍នេះអាចទាញយកបានជាលក្ខណៈអេឡិចត្រូនិច តាមរយៈ
គេហទំព័រ **www.visionfund.com.kh** ឬជាសៀវភៅតាមរយៈ

**E-mail: vfc_information@wvi.org**
អាគារលេខ 20 សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ 47
ទូរស័ព្ទលេខ (885) 23 963 333, (855) 23 216 052